


5.93
3
៦

895-9323
MARYKNOLL
Date 2004
HUN SEN LIBRARY
R.U.P.P.
12521

# មេហោរកំបុតក

តែងដោយលោក

**ឡាំង-ប៉េងសៀក**

**បោះពុម្ពផ្សាយជាថ្មីដោយ ស្រី ប៊ុនជន**

រក្សាសិទ្ធិ

ព.ស. ២៥៤៤ គ.ស. ២០០១

# អារម្ភកថា

នេះពុំមែនជាប្រលោមលោកផ្អែកគុននិយម យុទ្ធសាស្ត្រ យុទ្ធសិល្ប៍ ឬអាថ៌កំបាំងអ្វីឡើយ ។ គឺកម្រងរឿង ដែលខ្ញុំសរសេរឡើងរំលឹកនូវអតីតកាលដ៏ឈឺចាប់មួយ ដែលមានយ៉ាងជាក់ស្តែងនៅដើមសតវត្សទី ១៨ ដើម្បីជាកញ្ចក់បញ្ចាំងឱ្យកូនខ្មែរនាបច្ចុប្បន្ននេះបានដឹងថាក្នុងកាលកន្លងជាយូរលង់ណាស់មកហើយនោះ ក៏មានកូនខ្មែរចាប់ផ្តើមធ្វើបដិវត្តិ រំលំរាជបល្លង្កដែរ ។

ធ្វើបដិវត្តិ ... តែបើទុកមនុស្សពុករលួយនៅកាន់ការដដែល គឺនៅតែឥតន័យ ...

« **មេចោរកំបុតក** » នេះជូនកាលសកម្មភាពនៃតួប៉ះទៅលើវរជនភាគខ្លះ នៅនាបច្ចុប្បន្ននេះ ហើយដែលអ្នកនិពន្ធសូមខាកស្តោះ ចំអកឡកឡឺយយ៉ាងអាមាស ទោះអ្នកនោះឯង ជាវរជនដល់មេយណាក៏ដោយ. ទោះនៅក្នុងវណ្ណៈណាក៏ដោយ ។

ដើម្បីសាងសង្គមមួយថ្មី គឺគេត្រូវហ៊ានអារកាត់. ត្រូវហ៊ានប្រហារជីវិតជនភាគតិចដែលចង់សម្លាប់ជនភាគច្រើន ។ ធ្វើដូច្នេះទើបរាស្ត្រដែលជាម្ចាស់អំណាចពិតៗ នោះអស់ចិត្ត ហើយទើបដំណើរការរៀបចំស្រុកទេសអាចមានប្រសិទ្ធិភាព ។ ... បើនៅតែតេមតូមស្ទេញស្ទូញ សម្លកកូរទេ គឺប្រាកដជាធ្លាក់ទឹកមិនខានឡើយ ។

... ខ្ញុំប្រឌិតរឿងនេះឡើង ខ្ញុំមានមនោសញ្ចេតនាមួយដ៏ជ្រាល ជ្រៅ នឹកដល់ខ្មែរទាំងរាប់លាននាក់ ដែលកំពុងរងគ្រោះដោយអំពើឈ្លានពានរបស់យួនឥតសាសនា. · នឹកដល់ខ្មែរអភ័ព្វខ្លះទៀតដែលក្បួតឈាមដោយសារតែខ្មែរភាគតិចដែលចចើងធ្វើមាន ... ដោយបឺតឈាម បឺតខ្ទុះអ្នកក្រ ...

សូមបងប្អូនខេមរជនទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រដ្ឋធានីភ្នំពេញថ្ងៃ ១១ កក្កដា ១៩៧១

**ឡាំង-ប៉េងសៀក**

# អ្នកទោសអនាមិក

មនុស្សម្នាក់បំផាយអាជានេយ្យលឿនស្លុងស្លៅ កាត់ព្រៃធំតូចនៃនគរទ្រាស [១] សំដៅទិសខាងលិច ។

ព្រៃនេះលាតសន្ធឹងទៅឆ្ងាយ ខៀវស្រងាត់ ប្រកបដោយផ្លូវដើង រសាំខ្វាត់ខ្វែងដូចក្រឡាសំបុកពីងពាង ។

សេះដែលផាយមើលទៅឃើញភ្លិបភ្លែតកំបាំងកម្ពោតព្រៃ ផ្លោះគូរុក្ខជាតិតូចៗ កាត់តាមផ្លូវរទេះ ... ហុយដីទ្រលោមពីក្រោយ ។ ក្នុងជន្មាយុមិនហួសពីសាមសិបឆ្នាំ ពនេចរចម្លែកមានរូបរាងមាំមួន ទឹកមុខញញឹមស្រស់ ... ថ្គាមខ្លា លុះក្នុងក្តីក្លាហានមោះមុត ទ្រង់គ្រឿងចម្បាំងដ៏វិចិត្រ មានទាំងដាវប្រកបដោយស្រោមដាំខ្សងភ្លឺផ្លេកៗ ។ ឆ្នូតក្បាលធ្វើអំពីជតិក្រហមរលើបរលង មានជាយរយោលប៉ើងត្រឡប់ចុះត្រឡប់ឡើងសំពោងតាមខ្យល់បក់ ។

គេទៅណា ? ...

ពីខាងក្រោយ កងសេះប្រមាណដប់បំផាយតាមដោយវាយគ្នាគ្រប់ច្រកល្ហកព័ទ្ធចាប់មនុស្សចម្លែក ។ កងពលខាងក្រោយនេះមានសំលៀកបំពាក់ពណ៌លឿង ពាក់មួយកំពូលស្រួច កាន់ខែលនិងដាវច្រងាងៗ គ្រប់ដៃសមជាទាហានវាំងនាសម័យព្រេងនាយ ។

លោកអព្ភរជាមេបញ្ជាការ មានវ័យប្រមាណហាសិបឆ្នាំហើយ ។

---

[១] សព្វថ្ងៃក្លាយជាឃុំតូចនៅក្នុងខេត្តបាត់ដំបង

ត្រូវគ្រឿងឥស្សរិយយសចិញ្ចាចតាមបែបសម័យបុរាណនោះ គ្រាន់តែឃើញ យើងក៏កើតមានចិត្តស្ញប់ស្ញែងក្រៃលែង ។ ភ្នែកមុត ចិញ្ចើមក្រាស រាងដំបង គឺជាមេមួយដែលមានបញ្ញាវ័យឆ្លាតរកនរណាប្រដូចគ្មាន ។ របៀបបញ្ជា ទ័ព របៀបចាត់ការចាប់ខ្មាំងឃើញថា មេទ័ពអម្ពរយើងថ្នឹកក្នុងរឿងចម្បាំង ជាពន់ពេក ។

យើងអាចដឹងបានថា ខាងក្រោយជាទ័ពរាជការ. ដេញតាមចាប់ បុរសម្នាក់ដែលបំផាយសេះរត់គេចខ្លួន ។ រីឯមាណពដែលត្រូវគេដេញចាប់ វាយសេះខ្ទាប់ៗ ... អាជានេយ្យសម្បុរត្នោតស្ទុះលឿនទៅមុខដូចខ្យល់ ។ មាណពងាកមកស៊ើចដាក់កងរាជការខាងក្រោយ ។

អុញ! ... ព្រួស ...

សេះមាណពទាក់ជើងនឹងខ្សែមួយចងកាត់ទទឹងផ្លូវ ធ្វើឱ្យដួល រមៀល បីត្រលប់ទាំងអ្នកជិះ ។ ដៃមនុស្សប្រមាណដប់សង្កត់អ្នកជាប់រកវើខ្លួនមិន រួច ។ ខ្នងដល់ដីមែនពិតតែបុរសរើទធាក់ ក្បៀកទាហានម្នាក់នោះ ប្រកាច់ ទៅក្រោយ ... ធ្វើឱ្យកងយោធាបែកញើសរហាមគ្រប់គ្នា ។

អម្ពរជាមេទ័ពមកដល់ដកកាំបិតស្នៀតភ្ជង់ទ្រូងមាណព ។

— ឬមួយស្លាប់ ! ... ហាំ ! ហាំ ! អាចោរពានវាំង. ឯង គ្មានជើងឯណាសម្រាប់រត់ទៀតទេ ... ឬមួយអញចាក់កណ្ដាលទ្រូងស្លាប់ ឥឡូវ ។

បុរសកំសត់រើកញ្ជ្រោលម្ដងទៀត

— អាខ្ញុំគេ ! អាខ្ញុំគេ ! មួយពេលនេះមានតែរស់និងស្លាប់ ។ ពេល នេះឯងចាប់អញបាន ថ្ងៃក្រោយ អញប្រាកដជាចាប់ ឯងវិញមិនខាន ...

ចាំចុះ ...

មេទ័ព អម្ពរសើចខ្ជ័រព្រៃ

— ហាំ ! ហាំ ! មានជាការអី ! មានជាការអី ។ អញចាប់ឯងយកទៅថ្វាយព្រះនាងពេជ្រនារី ដែលត្រូវការឈាមឯងទាំងស្រស់ ដែលត្រូវការជីវិតឯង ... ទាហាន ! ទាហាន ! ចងវាឱ្យជាប់ដាក់លើខ្នងសេះទៅថ្វាយព្រះនាងជាប្រញាប់ ។

គេចាប់សង្កត់បុរសម្តងទៀត យ៉ាងអស់ទំហឹង ។ គេយកខ្សែចង ជើង ... តែបុរសរើទីងណាត់ទីងណែង ធ្វើឱ្យដួលត្រឡប់ត្រឡិនទាំងអ្នក ចង ។ បុរសក្រោកឡើងរួច ... ដាល់កងពលសេនាដួលរេល ឥតប្រណី ។ ដំបងមួយវាត់ពីក្រោយឮភូស១ ផ្ទួនគ្នាចំកញ្ចឹងក ... រួចបុរសទន់ខ្លួនស្រិបមួយរំពេច ... ។

លោកអម្ពរ បញ្ជាឱ្យទាហានលើកជនចម្លែកដាក់លើខ្នងសេះ ហើយបំជាយសំដៅព្រះរាជវាំងក្រុងនគរទ្រាស ដែលនៅពេលព្រលប់នេះ គេមើលទៅឃើញស្កុង១ ដំបូលខ្ពស់ត្រដែតចាក់អាកាស ...

តើបុរសក្លាហានដែលនៅក្នុងកណ្តាប់ដៃខ្មាំងនេះជានរណា ? ហេតុអីក៏កងរាជការដេញចាប់ ? ...

# ឧប្បត្តិហេតុក្នុងវាំងហ្លួង

វិសេសភក្តិ ... នេះហើយជានាមបុរសកំសត់ដែលត្រូវក្រុមទ័ពហ្លួងចាប់មក ...

ប្រាំឆ្នាំមុន បុរសយើងជាមេទ័ពធំរក្សាព្រំដែនខាងលិចនៃក្រុងនគរទ្រាស ។ និស្ស័យជាអ្នកក្លាហាននិងជាអ្នកស្រឡាញ់ការងារ លោកវិសេសភក្តិ យើងបានខំផ្ចិតផ្ចង់បំរើផែនដីដោយស្មោះអស់ពីចិត្ត ។ ជាមេទ័ពមានថ្វីដៃយ៉ាងសំបើម ដែលខ្មាំងរាប់ម៉ឺននាក់ ត្រូវតែអោនក្បាលចុះពីមុខនាមដ៏ខ្ពង់ខ្ពស់នេះ ។

មួយឆ្នាំមកហើយ ដែលព្រះបាននិរន្តវង្សព្រះចៅក្រុងនគរទ្រាសដកវិសេសភក្តិពីប្រទល់ដែន តែងតាំងលោកជាមេបញ្ជាការលើកងទ័ពរក្សាព្រះអង្គ ជំនួសលោកមេទ័ពអម្ពរ ដែលព្រះចៅត្រាស់យល់ថា មានថ្វីដៃចាញ់មេទ័ពវិសេសភក្តិយើង ។

រឿងនេះបណ្តាលឱ្យអម្ពរ កើតក្តីតូចចិត្តច្រណែននិន្ទាឈ្នានីសគ្រប់ពេលវេលា ។

រយៈពេលមួយឆ្នាំ ដែលអ្នករស់នៅក្នុងប្រាសាទនោះ វិសេសភក្តិបានប្រទះអំពើអយុត្តិធម៌, បរិយាកាសចុកឈាមជីវិតច្របូកច្របល់ ។ល។ ... នៅក្នុងវាំង បញ្ហារាស្ត្រត្រូវគេកប់ចោលយ៉ាងជិត ពុំមាននរណានឹកនាដល់សោះឡើយ ។ គឺមានតែបញ្ហាស្រីស្នំ, បញ្ហាបន្ទុបកូន បន្ទុបចៅឱ្យពាក់មកុដរាជ្យនោះទេ ជាបញ្ហាពិស្តារដែលគេត្រូវយកមកដោះស្រាយរៀបរាល់ ថ្ងៃរៀងរាល់ពេល ។

គឺដោយបរិយាកាសអាប់អួរក្នុងព្រះរាជវាំងនោះហើយ ដែលនាំចិត្តវិសេសភក្តិឱ្យរវាតចេញពីព្រះរាជាបន្តិចម្តងៗ ជាលំដាប់ ។ បុរសនឹកជាឃោមរាស្ត្រដែលហូរនៅសមរភូមិញើសរាស្ត្រ ដែលស្រក់ខ្ចាយលើធរណីគឺបានហូរ បានស្រក់ដើម្បីតែសេចក្តីសុខរបស់មនុស្សមួយចំនួនតូចពោលគឺឈាមនិងញើសរបស់រាស្ត្រចូលគ្នា ផ្តុំកើតជាបល្ល័ង្ករាជ្យ ... សម្រាប់តែក្រសែពូជពង្សស្តេចប៉ុណ្ណោះ ។

បញ្ហាបីដែលត្រូវដោះស្រាយ ជាបន្ទាន់ គឺ ÷

១ — ឬមួយជាតិខ្មែររលាយ

២ — ឬមួយ នគរទ្រាស. ខេត្តបាត់ដំបង. សេរីសោភ័ណ. ម្លូព្រៃ. ទន្លេពៅ ត្រូវបានទៅសៀម. ស្រុកខ្មែរ ធ្លាក់ទៅនៅខ្ញុំគេ ។

៣ — ឬមួយរាស្ត្រខ្មែរធ្លាក់ទៅស្ថាននរកមួយជាន់ទៀត ។

មេទ័ពយើងលួចបានឯកសារសម្ងាត់ ដែលព្រះរាជាផ្តាច់ខេត្ត បាត់-ដំបង. ម្លូព្រៃ ទន្លេពៅ ទៅឱ្យសៀម ដោយគ្រាន់តែសុំឱ្យព្រះចៅសៀមបញ្ជូនពលយោធាមកជួយកំចាត់ជនមួយក្រុម ដែលប៉ងរំលំរាជបល្ល័ង្ក ។ ម្យ៉ាងទៀតអម្រែកមួយធ្ងន់ដែលធ្លាក់មកលើស្មាប្រជារាស្ត្រនោះ គឺព្រះចៅបានរៀបចំចុតហ្មាយទៅគ្រប់ចៅហ្វាយខេត្តដើម្បី តម្លើងពន្ធដារពីរាស្ត្រ. បញ្ជាឱ្យរាស្ត្ររកពេជ្រសុទ្ធទាំងគ្រាប់ខ្នាតធំចំនួន ២០គ្រាប់. មាសចំនួនបីហាប. ភ្លុកដំរីប្រវែងពីព្យាមចំនួនប្រាំគូ. សាច់ប្រាក់សុទ្ធដប់ហាប ... ។ល។ ព្រះចៅដាក់កំហិតឱ្យចៅហ្វាយខេត្ត ទាររបស់ទាំងនេះពីរាស្ត្រឱ្យបានគ្រប់ចំនួនមុនថ្ងៃ ៣រោចចែត្រនេះ. ហើយទោសកំបុតក បើនរណារឹងទទឹងប្រកែកប្រណាំងនឹងបញ្ជានេះ ។

គឺចំនួនកន្លះខែមកហើយ ដែលក្នុងព្រះនគរកើតកលយុគព្រោះតែបញ្ហាដាច់ណោត់នេះ ដោយខ្លះប្រជុំគ្នាតាមផ្សារតាមផ្ទះតៀម តាមទីប្រជុំជនស្រុចុះស្រឡើង ចោលការចោលងារបះបោររពើតរពើងឡើងរុញ វាសនានរគទ្រាសឱ្យធ្លាក់ជ្រៅទៅក្នុងវិបត្តិនយោបាយមួយដ៏គួរឱ្យខ្លាច ។

ចំពោះការដាក់កំហិតឱ្យរាស្ត្រកមាសពេជ្យនេះមតិពីផ្ទុយគ្នា ។ គឺជនមួយពួកបានយល់ថាការធ្វើនេះត្រូវតាមកាលៈទេសៈហើយ ព្រោះកម្លាំងទ័ពខ្មែរទន់ ត្រូវតែចងមេត្រីភាពជាមួយប្រទេសជិតខាង ពង្រឹងស្ថានភាពនគរ ។ ជនមួយជំពូកទៀតសំដែងអាការៈកើតទុក្ខមិនសុខចិត្ត ជជែកវែកញែករួចសម្រេចសេចក្តីថា "គឺពិតជាជាន់ករាស្ត្រពេកហើយ រាស្ត្រក្រហេមរហាម រកបាយទានមិនចង់បានផង ថែមបន្ទុកមកលើរាស្ត្រទៀត ... មើលទៅរាស្ត្រដាច់ដង្ហើម គ្មានបានរស់ជីវិតទេ" ។

ដូច្នេះក្នុងចំណោមរាស្ត្រ រាស្ត្របែកបាក់គ្នា មានបក្សមានពួករួចប្រឆាំងគ្នា ។ ក្នុងចំនោមនាម៉ឺន១ ខ្វែងគំនិតគ្នា. សង្គមជាតិក៏ប្រេះឆា នាំឱ្យក្តីងងឹតមួយបោកបក់មកលើវាសនានគរទ្រាស ឱ្យរកផ្លូវចំរើនមិនឃើញ ។

គឺកាលនោះហើយ ដែលវិសេសភក្តីចេញមុខការពារសិទ្ធិរាស្ត្រ ដោយម៉ឺងម៉ាត់ធ្វើឱ្យព្រះរាជាកើតក្តីវិកវរតេងតាងបន្តិច ។ ដោយព្រះអង្គទ្រង់ជ្រាបថាព្រះនាងពេជ្រនារីជាបុត្រី ឈ្លក់ក្នុងសមុទ្រស្នេហា ... ព្រោះតែវិសេសភក្តី. តែវិសេសភក្តីពុំបានបំពេញតាមបំណងម្ចាស់ក្សត្រីឡើយ ។ ក្តៅណាស់ ព្រះនាងប្រឹងអង្វរលោមស្នេហ៍ពីគេ គេឥតទទួលតបវិញសោះ ។ ព្រះនាងត្រិះរិះកែសាហួសចិត្តថា បើព្រះនាងមានរូបអាក្រក់ទៅចុះក៏មិនថា ដែរ

ចុះនេះរូបស្រីស្មើទេវតា ហើយកើតក្នុងត្រកូលស្ដេចទៀត គួរអីក៏វិសេសភក្ដី ដាច់ក្ដីមេត្តាដល់ម្ល៉េះ ?

ភ្លើងស្នេហា ក្លាយជាភ្លើងកំហឹង ...

ធិតាដ៏ថ្កើងយសនឹងថាត្រូវលុបប្រុសម្នាក់នេះឱ្យបាត់ពីផែនដី — ព្រោះថ្ងៃក្រោយទៅប្រុសនេះអាចមើលងាយដល់ព្រះនាងមិនខាន ដោយហេតុក្ដីព្រះនាងប្រាប់គេឯងឯទៀតមិនលែងឡើយ ។ ការសម្លាប់បំបាត់មុខបុរសនេះមួយ អាចធ្វើឱ្យកិត្តិយសព្រះនាង មានរស្មីចិញ្ចាចឡើងវិញ ។

ក្នុងវេលាយប់នោះ ព្រះនាងជំនុំជាមួយព្រះបិតារកវិធីសម្លាប់មេទ័ពវិសេសភក្ដីដោយអាថ៌កំបាំង. តែវិសេសភក្ដីដឹងជើងការទាន់ក៏ភៀសខ្លួនរត់ ... រត់ពុំរួចទាល់តែគេចាប់បានមកវិញ ដូចយើងបានឃើញនៅវគ្គទីមួយនោះស្រាប់ ។

កាលបើដឹងថា មេទ័ពអម្ពរចាប់បានវិសេសភក្ដីនោះបានហើយ ព្រះនាងដើរតួង។ ចូលទៅក្នុងបន្ទប់ឃុំឃាំងដែលគេចងទុកនៅទីនោះ ។

វិសេសភក្ដី វាត់ជើងឆ្វេងដាក់លើគ្រែ សម្លឹងឥតព្រិចទៅព្រះនាងដែលចុះមក ។ ព្រះនាងយកហត្ថាភើចជាយពស្ត្រាទម្លាក់ជំហានយ៉ាងញាប់ ... មកទល់មុខនឹងវិសេសភក្ដី ដោយមានទាហានដប់នាក់អមមកជាប់ ។ ព្រះនាងមានភក្ត្រាក្រហមដោយទោសៈ ... យារព្រះហស្តទះកំភ្លៀងវិសេសភក្ដីម៉ាំង។ ...

— ទីបំផុតឯងអស់លក្ខណ៍ហើយ...

វិសេសភក្ដីដែលរង់ចាំសំដីព្រះនាងដំបូងនោះ. ក៏ពេបមាត់ ញញឹមយ៉ាងខែង

— សួស្តីអូនសម្លាញ់

— ហ៊ឹះ ! ហ៊ឹះ ! អ្នកឯងហៅខ្ញុំអូនសម្លាញ់ផង. តើខ្ញុំប្អូនអ្នកឯងពីកាលណា. ទោសអ្នកឯងពេលនេះគឺទោសកំបុតកស្ដាប់បានទេ ?

— ហាំ ! ហាំ ! មានជាការអី មានជាការអីអូនសម្លាញ់បង អូនដាច់ចិត្តសម្លាប់ប្រុសម្នាក់ដែលអូនស្រឡាញ់នោះឬ ? ប្រសើរមែន. ចិត្តអូនដាច់ខាតណាស់ហ្ន៎ ?

ដោយខ្លាចពលសេនាដឹងរឿងអាថ៌កំបាំងនេះ ធីតាទន្រ្ទាំជើងស្រែកបន្ទប់ថា ÷

— ឈប់និយាយ ដៃជើងជាប់ខ្នោះហើយឯងនៅតែនិយាយលែបខាយទៀត ។

— ហាំ ! ហាំ ! ... ដៃជើងជាប់ខ្នោះ តែចិត្តបងពុំមានជាប់ខ្នោះអីទេ ចិត្តបងហោះហើរជានិច្ច ផុតពីទីឃុំឃាំងនេះ ។

— រួចខ្លួនពីទីឃុំឃាំង ? កុំដក់ចិត្តសង្ឃឹមនោះគឺជាការស្រមៃទេ។

— ចុះគេថាជីវិតត្រូវតែមានសង្ឃឹមនោះអីមែនទេ ម្ចាស់អូនជាទីស្នេហា ។ ហាំ ! ហាំ ! ម្ចាស់អូនជាស្រីសាងតែអំពើអយុត្តិធម៌. ចង់មានចង់ថ្កើងដោយឥតមូលហេតុ ។ ដោយអនុគ្រោះ ម្ចាស់បងគ្រាន់តែសុំទូលព្រះនាងថាថ្ងៃនេះម្ចាស់ងួត. ហែលលេង ក្នុងញើសឈាមរាស្ត្រ. ថ្ងៃក្រោយអូននឹងឈ្លក់លិចលង់ស្លាប់ដោយញើសឈាមនេះចិញមិនខាន ។ រូបព្រះនាងនៅក្មេង ... រូបព្រះនាងល្អ តោងអូនធ្វើដូចជាស្រីធម្មតាទៅអូនមុខជាសុខមិនខាន ។ អូនសាងតែសេចក្ដីស្នេហាស្មោះស្ម័គ្រ ព្រោះសេចក្ដីស្នេហា

នេះជាលំអរបស់ស្រីទូទៅ ទោះជាស្រីក្នុងត្រកូលអ្វីក៏ដោយ មិនថាជាតិសាសន៍ខ្មែរ យួន ចិន សៀម លាវ អ្វីទេ ...

ព្រះនាងប្រឹងទប់នឹងសំដីដ៏ទ្រគោះឡកឡើយនេះ រួចសម្លេងតឹងស្មើរច្រាលដើមទ្រូងបន្លឺមកថា ÷

— ហ៊ឺះ ! ហ៊ឺះ ... ចាំមើលចុះ ព្រះបិតាចង់ធ្វើទារុណកម្មនោះមិនជាសំបើមទេ ទុកឱ្យពេជ្រនារី ខ្ញុំធ្វើវិញទើបអស្ចារ្យមែនៗ ...

រាជធីតាគ្រញែងកាយ ចាប់លើកសំពត់ឡើងជណ្តើរទៅលើវិញទាំងក្តីឈឺចាប់ និងពោរពេញទៅដោយចិត្តសងសឹក ។

វិសេសភក្តីសើចនិយាយខ្លាំងៗ ថា ÷

វត្ថុនៅលើលោកនេះ តែងប្រែប្រួលជានិច្ច ស្រុកទេសក៏ត្រូវមានការប្រែប្រួលដែរ ... សុំព្រះនាងអូនកុំប្រញាប់គិតថា អូនរស់លើរាជ្យបល្ល័ង្ករហូតអស់កប្បអស់កល្បជានិច្ចនោះ ... ហាំ! ហាំ! ...

# អ្នកទោសពានវាំង

ម៉ៃថ្ងៃក្រោយមក ...

មនុស្សម្នាមហាជន ទាំងឡាយនៅក្រុងនគរទ្រាសផ្អើលឆោឡោ ទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រីអ៊ូ អរជ្រួលចុះជ្រួលឡើង មកមើលពិធីហែអាក្រោស ដែលគេវាយបណ្ដើរតាមផ្លូវថ្នល់ ... នូវអ្នកទោសពានវាំង វិសេសភក្ដីយើង ។

បុរសរងទុក្ខវេទនា រកអ្វីប្រៀបផ្ទឹមពុំបាន ។

អ្នកខ្លះដែលពុំដឹងរឿង អ្នកត្រចៀកស្រាល ជនដែលរស់រណបនៅជើងកំផែងព្រះបាទនរិន្ទវង្ស បានជេរប្រទេចផ្ដាសា ជួយស្អប់ថែមទៅលើទាតុណកម្មនោះ ។ ដូច្នេះរឿងវិសេសភក្ដីក៏ផ្ទុះឡើងខ្ចរខ្ចារ សុះសាយពេញទាំងក្រុងនគរទ្រាស ហើយអ្នកផងរត់មាត់ថាជា "អ្នកទោសពានវាំង" ។

រួចពីនោះមក អ្នកទោសយើង ត្រូវគេយកមកដាក់នៅគុកទោសឧក្រិដ្ឋ ដោយបង្ខំឱ្យធ្វើការជាទម្ងន់ ក្រោមរំពាត់ខ្សែតីនៃតម្រួតគុក ។

រាល់ថ្ងៃ គេអាចមើលពីលើថ្នាក់ជាន់ទីពីរនៃមហាប្រាសាទទៅឃើញវិសេសភក្ដី អូសរទេះដឹកថ្មម្នាក់ឯងរហាមតាំងពីព្រឹកដល់ថ្ងៃត្រង់ តាំងពីថ្ងៃត្រង់ដល់ពេលព្រលប់ ពុំមានសំរាកមួយនាទីណាសោះឡើយ ។ មនុស្សជាដៃជើងវិសេសភក្ដីទាំងប៉ុន្មាន ក៏គេចាប់មកដាក់គុកធ្វើការជាទម្ងន់ ជាមួយគ្នាដោយឥតត្រាប្រណីឡើយ ។ អគ្គី រាហុល និងចន្ទា ជាសិស្សជំនិតរបស់វិសេសភក្ដី ក៏មកនៅជាប់គុកនេះដែរ ដែលថ្ងៃនេះអ្នកទាំងបីខំត្រដាបត្រដួសទាញរទេះដឹកថ្មឡើងទួល ។ ដោយអស់កម្លាំងពេក រទេះថ្មរអិលរូ

ចុះពីទីទួលនោះ ធ្វើឱ្យដួលច្រងាប់ច្រងិលទាំងអ្នកអូស ។ តម្រួតគុកដ៏ឥត ត្រាប្រណី ដែលចាំត្រួតការ ស្ទុះទៅវាយអ្នកទោសនឹងរំពាត់ខ្សែតីខ្វាប់ៗ ។

អគ្គីក្រោកឈរយ៉ាងស្វាហាប់ ខាំធ្មេញក្រឹតៗ ក្តាប់ដៃនិយាយស្ទើរស្ទុះដើមទ្រូងថា ÷

— អារមិលគុណ អាបំរុង. អាឈាមឈ្លើង

នាយបំរុងជាតម្រួតគុក ស្ទុះមក ... បើកភ្នែកធំៗ

— ថាម៉េច ? ថាម៉េច ? និយាយម្តងទៀតមកមើល ! និយាយទៀតមក

— ហ៊ុះ ! អាឈាមឈ្លើង ! ...

នាយបំរុងយាររំពាត់វាយអគ្គីខ្វាប់ៗ. ឈាមហូរតាមស្នាមខ្សែតីនោះចុកចាប់ក្រៃពេក ។ អគ្គីដួលច្រងាប់ច្រងិល ។ វិសេសភក្តិស្ទុះមកលើកមិត្តរបស់ខ្លួនដោយក្តីខ្លោចផ្សា ...

— បងគី ! ... បងគី !

— លោកគ្រូ ! ...

នាយបំរុងនិយាយថា ÷

— លោកគ្រូចង់ជួយវា ... ហាំ ! ហាំ ! មានជាការអី ... លោកគ្រូពូកែតែពេលមុន. ពេលនេះត្រូវដឹងថាលោកគ្រូជាខ្លាបាក់ចង្កូម

ថាហើយខ្សែតីក៏វាត់មកលើជនឈ្មោះលោកគ្រូ ឬវិសេសភក្តិនេះទៀត ។ អគ្គីប្រឹងគំហកស្ទើរច្រាលឈាមពីបំពង់កថា ÷

— អាក្រពើ ...

អគ្គីចាប់ចុងខ្សែតីរបស់នាយបំរុង ហើយទាញកញ្ឆក់យ៉ាងខ្លាំងធ្វើឱ្យ

នាយតម្រួតជ្រុលតតាក់តតើតមក ។ អគ្គីច្បត់រំពាត់នោះក្បេបកនាយបំរុង ជាប់. ចន្ទាដែលនៅក្បែរនោះលើកដង្កត់ឈើវាយក្បាលនាយបំរុងម៉ាង ១ ... ខ្លាកំណាចដួលស្តូកស្តឹងក្នុងថ្លុកឈាម ។ រាហុលស្ទុះមកពីក្រោមលើកព្យោម កអាវនាយបំរុង ហើយដាល់មុខផាច់ៗ ... របស់មួយរឹងៗ នៅហោប៉ៅ អាវបុគ្គល រាហុលរហ័សដៃលូកទៅ ... ជយោ គឺសោមួយចង្កោម ។ អ្នកបោះទៅឱ្យអគ្គី អគ្គីទទួលហើយ លាក់ទុកក្នុងខោបាត់មួយរំពេច. ហើយ លំដាប់នោះ តម្រួតទាំងឡាយ ស្ទុះភ្លែតៗ មកដល់កន្លែងកើតហេតុ ។

អ្នកទោសទាំងបួនឈរយ៉ាងក្រទា ... ។ នាយបុរីជាចាងហ្វាងគុក ដើរមកជិត បញ្ចេញនូវប្ញទ្ធានុភាពសាហាវមួយ ។

— ហ៊ឹះលោកគ្រូ! ជាប់គុកហើយនៅបង្ខំបង្កហេតុទៀត ?

បុរីលើកដង្កត់ឈើវាយវិសេសភក្តិម៉ាំងៗ ។ អ្នកបញ្ជាឱ្យទាហានចាប់ ចងអ្នកទោសទាំងបួនយកទៅដាក់គុកសរិទ្ធ ហើយឱ្យពលសេនាយកខ្មោច បំរុងទៅកប់ ។

ដៃជាប់ខ្នោះ អគ្គីឆ្មៀតអង្អែលសោឃើញថានៅពុំទាន់ជ្រុះបង់នៅ ឡើយ. ចន្ទានិងរាហុល មើលកាយវិការនេះដោយងក់ក្បាលលួចញញឹម កណ្តាលសមុទ្រទុក្ខនិងទារុណកម្មដ៏សាហាវនេះ ។

គឺជាគុកមួយថ្មី ដែលគេយកអ្នកទោសយើងមកដាក់ ។ ជាគុកងងឹត ហើយហាក់ដូចជានៅក្នុងរូងក្រោមដី ។ គឺបន្ទប់តូចហប់ តែរងា. ធុំក្លិន អាចម៍ប្រជៀវ ស្ទើរដកដង្ហើមពុំបាន ...

ពេលព្រលប់ ...

ក្នុងប្រាសាទព្រះបាទនរិន្ទវង្សក្រុងនគរប្រាស ដែលយើងមើលទៅ

ឃើញ ខ្ពស់ត្រដែតយ៉ាងក្រអឺតនោះ គេឮតែស្នូរដូរ្យដន្ត្រីរងំ រួចយូរៗ សម្លេងស្រី អ្នកច្រៀងលាន់ក្រអៅចេញមក ធ្វើឱ្យអ្នកដំណើរទាំងឡាយឈប់ចាំស្ដាប់យ៉ាងកកកុញ ។

ព្រះនរិន្ទវង្ស លក់ក្នុងក្ដីសប្បាយនេះឯង ។

ចូលទៅខាងក្នុង គេអាចឃើញព្រះនរិន្ទវង្ស គង់លើអសនៈដ៏ថ្កើងថ្កាន មានអស់ស្រីស្នំ ភិលៀង បរិវា ដប់នាក់ម្ខាង បក់ផ្លិតថ្វាយ និងប្រាំនាក់ទៀតដុតឈើខ្លឹមចន្ទក្រអូបល្ងឹងល្ងើយ ។

ខាងស្ដាំគឺព្រះទេពីទ្រង់មកុដដាំពេជ្រភ្លឺរន្ទាល ហើយក្បែរនោះ ព្រះនាងពេជ្រនារី ជាបុត្រីកំពុងទតរបាំដ៏អស្ចារ្យ ។ តែព្រះភក្ត្រព្រះនាងហាក់ស្ងួតស្ងប់យ៉ាងក្រៃលែង ។ ក្បែរព្រះនាង គឺមនុស្សម្នាក់ដ៏ចម្លែក ... ។ មើលឱ្យជាក់ទៅ គឺប្រាកដជាក្សត្រានៃព្រះចៅណាមួយហើយ ។ មនុស្សនេះពិតជាភ្ញៀវកិត្តិយស ព្រោះទាំងកាយវិការ ទាំងព្រះបន្ទូលព្រះបាទហរិវង្សរួសរាយជាងមនុស្សនេះជាខ្លាំង ។

ខាងនោះ គឺភរិយាអស់លោកមន្ត្រីសេនាបតី ដែលពាក់ពេជ្រហៀរចិញ្ចាចតាំងពីចុងសក់ដល់កែងជើង ក៏កំពុងជក់អារម្មណ៍ជាមួយរបាំនោះដែរ ។

ព្រះចៅក្រុងនគរទ្រាសមានព្រះភក្ត្ររីករាយ ដោយសម្រួលយ៉ាងក្អាកក្អាយ ។ នៅក្បែរនោះគឺអស់លោកមេទ័ពអម្ពរនិងបុរីដែលអង្គុយគាល់យ៉ាងស្ងៀមស្ងាត់ ។

លោកអម្ពរចម្លែកក្នុងចិត្តជាខ្លាំង ព្រោះអម្បាញ់មិញអ្នកបានឃើញភក្ត្រាព្រះចៅរីករាយសប្បាយហើយឥឡូវ ប្រែជាស្រគត់ស្រគំក្រៀមស្រពោនទៅវិញ តែអ្នកពុំហ៊ានសួរនាំអ្វីឡើយ ។ ... ព្រះចៅបែរមក

លោកអម្ចរ មានព្រះបន្ទូលថា ÷

— នឹកទៅខ្ញុំមិនអស់ចិត្តនឹងអាវិសេសភក្តិ ដែលខ្ញុំខំស្រឡាញ់ទុកចិត្តវា ហើយវាបែរជាក្បត់ខ្ញុំទៅវិញ

អម្ចរក្រួញក្រាបថា ÷

— ក្រាបទូលគាត់ជាគ្រូខ្ញុំ បង្ហាត់បង្រៀនទូលព្រះបង្គំឱ្យចេះវិជ្ជាចម្បាំង ។ គាត់ជាអ្នកមានថ្វីដៃលើសគេឯងក្នុងនគរទ្រាសនេះ តែចិត្តពុំដូចទូលព្រះបង្គំសោះ ។ ទីបំផុតដោយតេជៈបារមីព្រះរាជបល្ល័ង្ក គាត់ក៏រត់មិនរួចពីកណ្ដាប់ ដៃព្រះអង្គ ...

— ហាំ ! ហាំ ! វាដេកក្ដុងទ្រុងហើយ. វាសាហាវដូចខ្លាត្រូវរបូសទោះនៅក្នុងកណ្ដាប់ដៃយើងហើយវានៅតែបង្កកលិយុគទៀត ។ តោងលោកឃ្លាំវាឱ្យម៉ឹងម៉ាត់ ប្រយ័ត្នវារត់រួច ។

— ក្រាបទូល ! ទោះទេវតាចុះពីលើមេឃក៏មិនអាចជួយបានដែរ. ទូលបង្គំយកវាទៅឃុំក្នុងគុកងងឹតនៅបាតដីទម្រាំមានឱកាសសម្លាប់ចោល ។

— អើ អើ ! ... ខ្ញុំក៏ចង់សម្លាប់វាភ្លាម១ ទៅដែរ. តែតោងឱ្យវាឆ្លើយប្រាប់កន្លែងលាក់ឯកសារសម្ងាត់ដែលវាបានលួចយកទៅ ។ សព្វថ្ងៃកុំតែនៅទាក់ទាមរឿងឯកសារនេះកុំអីខ្ញុំបញ្ជាឱ្យសម្លាប់ បាត់ទៅហើយ ។ ឯកសារនោះ អាចធ្វើឱ្យរលាយស្រុកទេស ឬអាចឱ្យសម្ពន្ធមេត្រីភាពរវាងព្រះចៅក្រុងអយុធ្យានឹងនគរយើងមានប្រេះឆា ...

តមកព្រះអង្គនៅស្ងៀម ។ ទ្រង់នឹកបារម្ភដល់ផែនការណ៍របស់វិសេសភក្តិ ដែលអាចរំលាយរាជបល្ល័ង្កបានទៅថ្ងៃមុខ បើមនុស្សដ៏សាហាវនេះរួចចេញពីគុក ។ ... ស្នូរភ្លេង. ក្បាច់របាំ. ស្រីល្អ១ ក៏ក្លាយជាវត្ថុឥត

ព្រលឹងអស់រលីង ។ ព្រះអង្គកើតក្ដីតប់ប្រមល់វិលវល់ជាខ្លាំង ... ។

ទ្រង់នឹកដល់ថ្ងៃដ៏គួរឱ្យស្ញើចរបស់លោកអម្ពរ ដែលតាមចាប់មនុស្សកំណាចនេះមកវិញបាន ។ ទ្រង់ភ្ញាក់នឹកឃើញថា អម្ពរជាមនុស្សស្មោះត្រង់នឹងរាជបល្ល័ង្កមែន. ចាំចប់ពិធីនេះ នឹងប្រកាសលើកលោកអម្ពរជាមេទ័ពធំនៅនគរទ្រាសនេះ ។ នឹកឃើញដូច្នេះ. តែព្រះអង្គទុកក្នុងចិត្ត ។

របាំចប់ ...

ព្រះនរិន្ទវង្ស ក្រោកឡើងឈានបាទាមួយៗ មកជិតមនុស្សចម្លែក និងព្រះរាជបុត្រី ដោយមានបន្ទូលថា ÷

— ថ្ងៃដ៏ពិសេសនេះ ធ្វើឡើងថ្វាយជាកិត្តិយសដល់ទ្រង់ ដែលយាងមកចងសម្ពន្ធមេត្រីជាមួយទូលបង្គំ ។ នេះគឺរាជបុត្រីខ្ញុំ ដែលជាអនាគតអគ្គមហេសីរបស់ទ្រង់នោះ ។

ព្រះនាងបើកព្រះនេត្រធំៗ មើលភក្ត្រអនាគតភស្ដាទាំងរំភើបចិត្ត ។ ឯព្រះអង្គម្ចាស់ដែលយើងពុំទាន់ស្គាល់នាម ក៏តាំងស្មារតីនៅពេលនោះដែរ ។ ព្រះរាជាបន្តសព្ទទៀតថា ÷

— កូនស្រី ! នេះជាព្រះដារាវង្សរាជបុត្រព្រះចៅក្រុងអយុធ្យាហើយ ...

ព្រះនាងបន្ទន់កាយគោរពអនាគតភស្ដារ ។ រាជបុត្រក្រុងអយុធ្យាស្ទុះទៅចាប់ហត្ថព្រះនាង

— ជាព្រេងសំណាងខ្ពស់ណាស់ដែល យើងទាំងពីរបានជួបគ្នា ។ ទូលបង្គំជឿថា សម្ពន្ធមិត្តនេះអាចឱ្យនគរយើងទាំងពីររឹងរឹតតែមានអានុភាពឡើង

— ទូលបង្គំសូមអគុណដល់វត្ថុសក្ដិសិទ្ធិទាំងឡាយ ដែលដឹកនាំឱ្យ

យើងបានជួបគ្នា

ព្រះនរិន្ទវង្សទតមើលក្សត្រទាំងពីរយ៉ាងរីករាយ ។ ទ្រង់មានបន្ទូលថា ÷

— អើ ! ... តោងរាប់អានគ្នាឱ្យហើយចុះ ...

បន្ទាប់មក គឺការបង្ហាញរាជបុត្រក្រុងអយុធ្យាដល់អស់មន្ត្រី សេនាបតីទាំងឡាយ ធ្វើឱ្យបរិយាកាសនេះរីងរឹតតែមានភាពអធឹកអាធមឡើង ។

... តែ ! តែពេលនោះហេតុចម្លែកមួយកើតឡើង នៅខាងក្រៅកំផែងវាំង ។

ព្រះរាជា. ព្រះរាជទេពី. រាជបុត្រី. មន្ត្រីនាម៉ឺន ជំទាវ ខុនណាងទាំងឡាយឡេឡាជ្រួលច្របល់ដោយឥតដឹងរឿង ។ លោកអម្ពរស្ទុះភ្លែតទៅក្រៅ ឈរមើលឃើញភ្លើងភ្លឺរន្ទាល ព្រមទាំងស្នូរដាវប៉ៃស១ ព្រមដោយសម្លេងហ៊ោកញ្ជ្រៀវ ។

ព្រះនរិន្ទវង្សស្ទុះមកឈរពីក្រោយលោកអម្ពរហើយសួរថា ÷

— មែនទេលោកមេទ័ព. គឺប្រាកដជាមានទ័ពបះបោរហើយ

— ក្រាបទូល ទ្វារគុករបើក. អ្នកទោសមិនដឹងជាយ៉ាងណាទេ ...

ព្រះរាជាភ្ញាក់ ដូចធ្លាក់ពីលើមេឃ

— អី ? អីអ្នកទោសរត់រួច ?

— ក្រាបទូល ...

ថាហើយអម្ពររត់ចុះពីរាជដំណាក់ទៅក្រោម ប្រញាប់ប្រញាល់ចាត់ចែងឱ្យអស់ពលយោធា ប្រុងប្រៀបទប់ទល់ ។ តែទាហានមួយចំនួនស្រវឹងស្រាដេកដួលរណែល ។ រត់ទៅមើលទ្វារគុក គុកចំហធ្លុងទទេស្អាត ។ ក្តៅ

ក្របាយជាខ្លាំង លោកអម្ពរស្រែករ៉ូងរ៉ាង ស្ទុះស្ទារចុះឡើងពេញកំផែងវាំង ។ អ្នកទៅដល់គ្រប់ច្រកទ្វារបញ្ជាទប់ទ្វារកុំឱ្យរបើក ។ ក្នុងទ្វារមួយទាហានមួយរយនាក់ចំកោងខ្នងប្រឹងទប់បែកញើសរហាម ។

ការរៀបចំជើងទ័ពក្នុងពេលមានអាសន្ននោះ យើងសង្កេតឃើញថាលោកអម្ពរថ្មឹកក្នុងរឿងចំបាំងនោះជាពន់ពេក ។ ទុំលើខ្នងសេះ លោកត្រួតមើលអស់ពលយោធាគ្រប់ទីកន្លែង. បញ្ជាឱ្យរៀបចំកាំភ្លើងធំ. បញ្ជាឱ្យមេៗទាំងឡាយផ្គុំកូនក្រុមរបស់ខ្លួនដោយចាត់ ប្រាំក្រុមទៅចាំការពារព្រះរាជដំណាក់ ការពារមាត់រូងសម្ងាត់មួយ ដែលនៅខាងក្រោមព្រះរាជដំណាក់នោះ ។

មកដល់ដើមគគីមួយធំកៀនកំផែនវាំង អម្ពរឃើញខ្សែពួរមួយចងសំយុង

...អ្នកនឹកថាវិសេសភក្តិនិងអ្នកទោសបីនាក់ចេញទៅក្រៅរួចដោយសារខ្សែពួរនេះ ។ ការឆ្ងល់មួយកើតមានក្នុងអារម្មណ៍មាណព. អ្នកឆ្ងល់ថាតើហេតុយ៉ាងណាទើបក្រុមរបស់វិសេសភក្តិនោះ អាចចេញពីទីឃុំឃាំងបាន ? បើទ្វាគុកនោះមានទៅដល់ប្រាំពីរជាន់ ។

វិសេសភក្តិចេញរួចទៅបាន បើសិនជាមនុស្សនេះទៅកទ័ពមកវាយក្រុងនគរទ្រាសនោះ គឺជាការមួយគួរឱ្យបារម្ភខ្លាំងណាស់ ព្រោះនៅលើលោកនេះ វិសេសភក្តិជាគ្រូកាន់អាវុធ លើគ្រូទាំងអស់ក្នុងប្រទេសកម្ពុជាហើយពូកែខាងល្បិចកិច្ចកលចម្បាំងរកនរណាប្រៀបប្រដូចពុំបាន ។ ណាមួយទៀតនៅក្រៅក្រុង បក្សពួកជាសិស្សរបស់វិសេសភក្តិក៏ច្រើន. ហើយប្រជាជនភាគច្រើននៅនគរទ្រាសនេះ ស្រឡាញ់រាប់អានវិសេសភក្តិនេះណាស់.

បើមនុស្សនេះទៅបំបះបំបោររាស្ត្រ ឃើញថារាជវាំងក្រុងទ្រាសនេះ ត្រូវរលាយជាផេះក្នុងរយៈពេលយ៉ាងខ្លី ។

យប់ក៏ងងឹត ភ្លៀងក៏រោយស្រិប ៗ ...

នៅក្នុងព្រះរាជវាំងគេពន្លត់ភ្លើងអស់រលីង ហើយស្ថានការណ៍នៅខាងក្នុងក៏ស្ងប់ស្ងាត់ ធ្វើឱ្យអ្នកព័ទ្ធខាងក្រៅនឹកថា ប្រាកដជាគេកំពុងជំនុំគ្នារកវិធីបំបែកក្រុមបះបោរ នៅខាងក្រៅនោះ ។

ក្រៅពីការបាញ់ព្រួញភ្លើងទៅ ក្រុមបះបោរពុំអាចលុកចូលក្នុងបរិវេណវាំងបានឡើយ ។

ប៉ឹម ! ...

ស្នូរកាំភ្លើងលាន់ដូចរន្ទះទាំងប្រាំបីទិសបាញ់រួមគ្នា ផ្ទុះចេញពីដំបូលប្រាសាទ ជះអានុភាពមកលើក្រុមអ្នកព័ទ្ធ ។ គេឮសូរតែអ្នកបញ្ជា ខាងក្រៅអកកន្ទែងការពារខ្លួន, នាយជាមេ ស្រែកបញ្ជាក្នុងទីងងឹតនោះថា ÷

— ព្រឹកស្អែកវាយផ្តាច់ព្រាត់ ... កនយើង ... យប់នេះទាំងអ្នកខាងក្នុង ទាំងអ្នកខាងក្រៅបាញ់តគ្នាយូរៗ មួយក្តួង ឆ្លើយឆ្លងយ៉ាងក្បោះក្បាយ ... ទម្រាំព្រឹកស្អែកវាយផ្តាច់ព្រាត់ ...

# រដ្ឋប្រហារ

ព្រលឹមស្រាងៗ ...

ទ័ពពួកឡោមវាំងក្រុងនគរទ្រាស នៅអែបគ្រប់ទ្វារ កំផែងវាំង ធ្វើឱ្យពួកនៅខាងក្នុងជ្រួលច្របល់ចុះឡើង ព្រោះមិនអាចរកច្រកចេញរួច ។

នៅក្បែរមាត់ច្រកទ្វារនេះ ស្នូរកាំភ្លើងកិបខាងទាហានហ្លួងជះអានុភាពមក កក្រើកអស់ពសុធាតែពុំមានត្រូវកងពលក្រុមឡោមវាំងម្នាក់ណាឡើយ ។ ហើយស្នូរកាំភ្លើងធំតូចឱ្យសូរក្ដុងៗ នៅឆ្លើយឆ្លងគ្នាយ៉ាងក្បោះក្បាយ ... ផ្សែងហុយងងឹតមេឃ ។

បុរីជាមេទ័ព បែកញើសរហាមទាំងព្រលឹមអុរ ដើរត្រួតអស់ពលយោធាគ្រប់ច្រកទ្វារ. រួចរៀបចំតាំងកាំភ្លើងធំតម្រង់ទិសដៅទៅរកខ្មាំង ។

ផាំងៗ ១ ១ គឺស្នូរកាំភ្លើងខាងទាហានហ្លួងផ្ទុះចេញពីលើកំផែងវាំងយ៉ាងខ្ទរខ្ទារ ។

ស្នូរនេះបន្លឺឡើងហាក់សែនពីរោះ ធ្វើឱ្យជនដែលក្លាហានក្នុងសង្គ្រាមចង់តែស្ដាប់ ចង់តែបាញ់ព្រោះជាភារៈធម្មតារបស់ជនទាំងនោះ ។

ផាំង ១ ១ ១

ទោះឃើញខ្មាំងឬពុំឃើញក៏ដោយ ទាហានខាងកងពលរបស់លោកអម្ពរច្រកគ្រាប់គាស់កៃទៅដែរ ។ ក្ដុង ! ក្ដុង ! ក្ដុង ! បាញ់ បាញ់ ទោះគ្រាប់ដែលចេញពីមាត់ត្រៃទៅនោះត្រូវមនុស្សឬពុំត្រូវ ក៏គ្មានជាការអ្វី

ប៉ុន្មានដែរ. បាញ់តែពាសវាលខាតគ្រាប់ឥតប្រយោជន៍ ។

លោកមេទ័ពអម្ពរ. បុរី ព្រមទាំងអស់អាមាត្រមហាតលិកក្នុងវាំងខ្វែងដៃខ្វែងជើងម្នាក់ៗ ។ បុរីបែរមកនិយាយជាមួយនាយពលរងម្នាក់នោះថា ÷

មើលទំនងយើងមានស្ថានភាពរឹងប៉ឹងជាងពួកវា តែទឹកដៃយើងហាក់ដូចជាចាញ់ពួកវាសំបើមណាស់ ព្រោះពួកវាព័ទ្ធយើងរកតែច្រកមួយ ចេញទៅណាក៏ពុំបាន. មើលទៅយើងស្លាប់នៅក្នុងក្រុងនេះឬយ៉ាងណា ព្រោះម្ហូបអាហារយើងតែត្រឹមបីថ្ងៃទៀតគឺអស់រលីងហើយ ។ មើលបំរុងឯង ប្រើទាហានម្នាក់ឱ្យទៅលើកជណ្តើនោះ មកដាក់ឡើងទៅលើដំបូល ប្រាសាទរួចមើលទៅក្រៅ សង្កេតមើលស្ថានភាពទ័ពខ្មាំង

មិនយូរប៉ុន្មាន ជណ្តើរមួយលើកស្ការមកមួយរំពេច ។ ទាហានម្នាក់ឡើងភ្លែតៗ ទៅលើ ។ សូរក្តុង ... ណែនរួចទាហាននោះធ្លាក់មកដីភឹងដាច់ខ្យល់ស្លាប់ឥតបង្អង់ ។ នាយរងឈ្មោះបំរុងស្ទុះទៅជិត

— ពួកវាព័ទ្ធយើង ហើយឃាមល្បាតដោយម៉ត់ចត់ផង ។ ពួកយើងបានតែក្រញោនក្នុងប្រាសាទប៉ុណ្ណោះ ព្រោះបើនរណាអើតក្បាលតែបន្តិចក៏ត្រូវស្លាប់ ។ យើងសម្ងំស្លាប់ម្តងមួយម្តងពីរដូច្នេះមិនបានទេ ។

ព្រះរាជាយាងមកដល់ទីនោះដែរ. ស្តេចទ្រង់ពស្ត្រាសឹក មើលទៅគួរឱ្យសំបើមយ៉ាងក្រៃលែង ។ ព្រះជន្មចូលក្នុងខ្ទង់សែសិបប្លាយទៅហើយ តែព្រះកាយព្រះអង្គនៅរឹងប៉ឹងដូចក្មេងអាយុម្ភៃឆ្នាំ ។ ទ្រង់មានបារម្ភជាខ្លាំងព្រោះព្រះអង្គទ្រង់ជ្រាបថា ក្រុមទ័ពឡោមវាំងនេះ ជាទ័ពរបស់សិស្សវិសេសភក្តិ គឺជាទ័ពប្រជាជន ដឹកនាំដោយប្រជាជន ។ ទ័ពនេះមានកម្លាំង

ខ្លាំងណាស់. ផ្ទុយស្រឡះពីទ័ពទាហានរក្សាព្រះអង្គដែលភ័យស្លន់ រញ៉ីរញ៉ូរ ក្នុងពេលមានសង្គ្រាម ។

ទ្រង់បញ្ជាឱ្យគេយកជណ្ដើមកដាក់គងកន្លែងមួយផ្សេងដែលទីនោះ អាចឡើងទៅដល់កំពូលស្រួចខ្ពស់បំផុត នៃព្រះរាជវាំង ។ មែន ! ទីនោះ គួរឱ្យទុកចិត្ត ព្រោះខ្មាំងពុំអាចមើលពីក្រោមកឃើញឡើយ ដែលបុរីឡើង ទៅដល់លើអាចមើលឃើញទៅឆ្ងាយ ។ មិនយូប៉ុន្មាន ព្រះនរិន្ទវង្សព្រម ទាំងអស់មេទ័ពក៏ឡើងទៅដល់ ប្រជុំគ្នាពិនិត្យហេតុការណ៍ ។

ព្រះរាជាបាំងព្រះហស្ដសម្លឹងព្រិច១ ទៅ ...

— នោះ ! ដែលមើលឃើញលឹម១ លើក្បាលដំបូកនោះ គឺប្រាកដ ជាវិសេសភក្ដិហើយ ។ ចេញពីគុកមិនបានប៉ុន្មានម៉ោងផង កទ័ពមកវាយឯង ព្រងើយ ។ មើលអម្ពរជួយសម្លឹងឱ្យច្បាស់ តើវិសេសភក្ដិមែនឬមិន មែន ?

អ្នកទាំងអស់ដែលនៅលើដំបូលប្រាសាទ ខំជួយសង្កេត ។ អម្ពរ ក្រាបទូលថា ÷

— គឺប្រាកដវិសេសភក្ដិមែន១ តែមិនអីទេ នងចាត់ការឱ្យទាហាន សែងកាំភ្លើងធំមកដាក់លើដំបូលនេះ ...

ទាហានឈ្មោះនងគំនាប់ផូង ថយទៅចាត់តាមបញ្ជាឥតបង្អង់យូរ ។

ខាងណោះ ...

វិសេសភក្ដិ ប្រមូលអស់មេទាហានទាំងឡាយ រួចលាតផែនទី បញ្ជាក់ពីចំណុចសំខាន់១ ដែលត្រូវវាយលុករហូតទាល់តែចូលក្នុងវាំងបាន ។ គេអាចស្ដាប់បានថា ÷

— ... ពេលមានហេតុដូច្នេះ ព្រះញាតិវង្សបានភៀសខ្លួនទៅក្រុងអយុធ្យាអស់ទៅហើយ ។ ស្តាយណាស់ ដោយយើងចាត់ការនេះមិនទាន់. បំណងខ្ញុំគឺកាត់កក្រុមស្តេចចោលឱ្យអស់ ...

រាហុលដែលមុខមាត់ក្រឡាក់ធូលីស្រមក និយាយកាត់យ៉ាងប្រញាប់ថា ÷

— ទ័ពយើងដែលព័ទ្ធវាំងនេះ គឺជិតស្លុងដូចគេខ្ទប់ត្រចៀកដូច្នោះ ។ ខ្ញុំជឿថា ក្រុមស្តេចទាំងនោះប្រាកដជាពុំទាន់រត់ទៅណារួចទេ ...

— ទេ ! ទេ ! ប្រាកដជាទៅរួច ។ ការនេះសម្ងាត់ណាស់ រួចគ្មាននរណាដឹងឡើយ គឺមានតែខ្ញុំទេដែលដឹង ។ នៅក្នុងប្រាសាទ ក្រោមបន្ទប់ម្ចាស់ក្សត្រីមានបន្ទប់សម្ងាត់មួយដើរដោយគ្រឿងយន្ត. គឺថា គេគ្រាន់តែចុចគន្លឹះមួយទៅ ផ្ទាំងថ្មកម្រាលនោះរបើកឡើង. គេចុះតាមជណ្តើរមួយទៅក្រោម ដែលមានពន្លឺថ្លើមថ្មចាំងមកដូចគេដុតភ្លើង ។ ក្នុងបន្ទប់នោះ មានតោមួយធ្វើពីសម្រិទ្ធ. ខ្លាធ្វើពីសម្រិទ្ធច្រើនដេរដាស ធំៗ ដែលគេអាចជិះបានពីរឬបីនាក់ ។ កាលណាគេយកដៃទៅពាល់ខ្នងតោនោះតែបន្តិច. តោគ្រហឹមងិលឡើង (១) បន្ទាបខ្លួនស្រឹតៗ មកឱ្យយើងជិះបាន ។ គន្លឹះមួយទៀតនៅកន្ទុយកាលណាគេចុចទៅ ធ្វើឱ្យខ្សែពានវិល. សត្វតោក៏វិលតាមខ្សែពាន ហោះលឿនក្នុងរូងសម្ងាត់ ... រហូតទៅដល់ទល់ដែន ក្នុងរយៈពេលកន្លះថ្ងៃ ...

---

(១) សូមអាន "ទោសពានវាំង" របស់លោក ឡាំង-បេងសៀក

រាហុលភ្លាត់មាត់ថា ÷

— រឿងនេះ ... ចំជាអស្ចារ្យមែន

វិសេសភក្តិសើច

— ហ្នឹងហើយ ជារឿងសម្ងាត់អស្ចារ្យ រួចមានតែមេទ័ពធំៗ ទេដែលដឹង ។ រូងនេះគេឱ្យអ្នកទោសជីកអស់រយៈពេលបីឆ្នាំមកហើយៗ យ៉ាងសម្ងាត់បំផុត ។ ជីករួចគេយកអ្នកទោសទៅសម្លាប់ចោល ដើម្បីកុំឱ្យខ្ចរខ្ចាយទៅណាទៀត ស្តាប់បានទេ ?

បុរីនិយាយឡើងថា ÷

— ... ដូច្នេះយើងព័ទ្ធវាំងនេះ ឥតប្រយោជន៍សោះព្រោះរឿងធំគឺត្រូវសម្លាប់ក្រុមស្តេចចោល ។

— ទេ ! ទេ ! សំខាន់ណាស់. ត្រូវដឹងថាភោគទ្រព្យខ្មែរ. មាសពេជ្រ កែវកងខ្មែរ គឺមកនៅគរកកកុញឥតប្រយោជន៍ក្នុងរាជវាំង គ្មានចែកចាយប្រើការជាប្រយោជន៍រាស្ត្រអ្វីសោះ ។ គិតមើលគ្រាន់តែគ្រែដេកស្តេចក៏ជាមាសដែរ. គ្រាន់តែស្រែកជើងស្តេចក៏ជាមាសដែរ ។ ហ៊ុ ! រឿងអីត្រូវថ្កើងដល់ម្លឹង ក្នុងពេលដែលខ្មែរទាំងអស់ កើតក្តីក្រក្សត់អត់ឃ្លានបែបហ្នឹង ។ នែ ! ខ្ញុំដឹងបន្ទប់សម្ងាត់មួយទៀត គឺបន្ទប់លាក់មាសពេជ្សរបស់ស្តេច ។ កាលនោះព្រះនាងជាបុត្រីចាញ់នយោបាយខ្ញុំ. ខ្ញុំនិយាយបន្ទន់ចិត្តព្រះនាង. ខ្ញុំហែកបេះដូងបង្ហាញព្រះនាង. ខ្ញុំធ្វើឱ្យព្រះនាងជឿជាក់ថា ខ្ញុំស្រឡាញ់ព្រះនាងមែន ទីបំផុតព្រះនាងនាំខ្ញុំទៅមើលមាសពេជ្សនោះ ។ ខ្ញុំសង្កេតអស់គ្រប់ទីកន្លែង ដើម្បីចំណាំ ទីបំផុតខ្ញុំស្គាល់អ្នកកាន់សោរបន្ទប់

ពិសេសនោះទៀត ។ ពេលកើតកលិយុគ ខ្ញុំឆ្លៀតទៅសម្លាប់អ្នកកាន់សោរ ហើយយកបានសោរពិសេសនោះ ... ហ៎ា ! យើងបានសោរ យើងអាចយកមាសពេជ្យរាប់រយហាប ធ្វើសោហ៊ុយច្បាំងតទៅទៀត ឬ យកទៅចែកចាយឱ្យរាស្ត្រវិញ ... ព្រោះមានពេជ្រនោះជាមាសពេជ្ររបស់ រាស្ត្រ ... ឥឡូវចប់ការហើយ. មេៗ ទាំងអស់ចាត់ ការតាមក្រុម តាមពួក តាមបញ្ជារបស់ខ្ញុំចុះ ។

នាយពលម្នាក់ក្រោកឡើងសួរថា ÷

— ហេតុយ៉ាងណាបានជាលោកគ្រូ អាចចេញពីទីឃុំឃាំងនោះបាន? វិសេសភក្តិសើច

— ហ៎ា ! ហ៎ា ! រឿងនោះ ...

ប៉ឹម ! ... រួចស្នូរស្រាលៗ បន្ទរយ៉ាងយូរតទៅទៀត ...

គឺស្នូរកាំភ្លើងធំខាងទ័ពអម្ពរ បាញ់មកដូចរន្ទះទាំងប្រាំបីទិស ។ ដំបូក មួយដែលនៅត្រង់កន្លែងមេទ័ពយើងជុំនំគ្នា ត្រូវលើងខ្ទាយហុយដីធ្លុប រួចគេ ឃើញអស់មេទ័ពទាំងឡាយ ដួលត្មោលៗ ... ហើយងើបឡើងច្រូងទាំងអស់ គ្នាយកដៃទះខោអាវ បោសធូលី លើកដៃបញ្ឈឺចិត្តអ្នកបាញ់ថែមទៀត ...

ព្រះរាជារអ៊ូរថា ÷

— ប៉ុណ្ណឹងហើយនៅតែវាមិនត្រូវគ្រាប់ស្លាប់ទៀត

មេទ័ពយើងទាំងប៉ុន្មាន ដែលនៅលើក្បាលដំបូកអម្បាញ់មិញ ដើរ អង់អាចចុះឡើង កាត់ព្រួញ និងគ្រាប់ដែលជះអនុភាពដ៏ខ្លាំងក្លាមក ។

បុរិខំធ្មេញ រេចុងកាំភ្លើងតាមវិសេសភក្តិ ដែលដើរចុះដើរឡើង ចាត់

បញ្ជាទ័ព ។ មិនយូរប៉ុន្មាន សូរក្អួងពីដំបូលប្រាសាទ. ត្រូវចំកន្លែងដែលគេតម្រង់... ហ៊ុយដីដូចមុន តែបុរសដែលគេចង់បាញ់ ដើរយ៉ាងព្រងើយរួចធ្វើការដូចមុនដដែល ។

គួរឱ្យរំភើបចិត្តជាពន់ពេក ព្រោះពេលនោះយើងបានប្រទះឃើញអ្នកស្រុក ដែលយល់ការស្រុកទេសជាក់លាក់ក៏បានកាន់អាវុធ មករួមតស៊ូជាមួយក្រុមបដិវត្តន៍យើងនេះដែរ ។ ស្រី១ លូនលបយកទឹកទាំងក្អម១យកបាយទាំងល្អី១ មកចែកជូនដល់កងទ័ពយើង ដែលយើងគ្មានដាក់កំហិត ឬអំពាវនាវទាមទាអ្វីឡើយ ។

ពួកយើងចែកវេនគ្នាបាញ់. មួយក្រុមបរិភោគបាយក្នុងជម្រក មួយក្រុមត្រូវបាញ់តតតឈប់ឈរ ។ ពេលបរិភោគបាយ ថ្វីបើខាងក្រៅឮសូរតែស្នូរដាវ ឬស្នូរគ្រាប់កាំភ្លើង តែយើងមានពេលរីករាយ គួរកត់ទុកជាអនុស្សាវរីយ៍ក្នុងក្រអៅបេះដូង ។ ស្រី១ ដែលយកបាយមកឱ្យក្រុមទាហានតស៊ូយើង មើលមុខអ្នកតយុទ្ធដោយក្ដីមេត្តារាប់អាន ។ ពួកយើងអរគុណទៅនារីទាំងនោះវិញ ខ្លះបង្កបង្កើតបរិយាកាសរីករាយ បន្លប់ចិត្តមេត្តាធម៌ដែលនារីសប្បុរសទាំងឡាយចោលមកយើង ។

ឱ ! អាកប្បកិរិយាប្រជាជនខ្មែរយើង ... ! ប្រជាជនខ្មែរគឺលេខមួយហើយខាងមនោសញ្ចេតនាច្រើន . ស្អប់សង្គ្រាម. ស្អប់ការព្រាត់ប្រាស់ ... ហើយពាក្យទាំងពីរនេះខ្មែរយើងមិនចង់ឮ មិនចង់ឃើញទាល់តែសោះ តែខ្មែរមិនអាចនៅស្ងៀម ឱ្យគេសម្លាប់ ដោយងាយ១នោះឡើយ ។ ឈាមខ្មែរជាឈាមតស៊ូ. ហើយខ្មែរទាំងអស់ កត់សំគាល់ក្នុងចិត្តថា ពេល

តស៊ូ ជាពិសេសនេះគឺតស៊ូរំដោះខ្លួនជាអ្នកជា ។ អស់លោកដែលយល់ចិត្តខ្មែរច្បាស់ លោកអ្នកអាចសន្មតបានថា ខ្មែរជាមនុស្សមួយបែប ដែលមានសុភនិច្ឆ័យប្លែកពីជាតិសាសន៍ដទៃនៅលើលោកនេះ ។

សង្គ្រាមបន្តរហូតដល់ថ្ងៃរសៀល ...

វិសេសភក្តីនិងរាហុល ជិះសេះយ៉ាងត្រដែតកាត់គ្រាប់ កាត់ព្រួញ ត្រួតអស់ពលយោធា ។ អ្នកស្រែកបញ្ជាឱ្យចូល ឱ្យគេច ឱ្យពួន ធ្វើសញ្ញាឱ្យវាយចូល ដើម្បីសម្រុក កំទេចវាំងឱ្យទាន់ពេលមុនថ្ងៃលិច ។

នៅទិសខាងលិច មានសម្លេងហ៊ោរ ស្ទើរកក្រើកអស់ដែនដី ។ វិសេសភក្តីងើបមើលទៅ សើចត្រេកអរជាខ្លាំង ព្រោះក្រុមទ័ពនេះ គឺទ័ពមហាកាល(១) . អរុណ(១) . នភា(១) និង មហាឫទ្ធិ(១) នាំមកពីក្រុងតាឃិលដែលមានចំនួនទាំងអស់ពីរម៉ឺនសែសិបប្រាំនាក់ ។

— មនុស្សម្នាក់មាឌមាំ ដូចអស្សតរឡើងសារ. ទ្រង់គ្រឿងចម្បាំងប្រកបដោយដាវវែងស្ពាយនៅចង្កេះ បំផាយអាជានេយ្យ យ៉ាងស្វាហាប់សំដៅមកវិសេសភក្តី។ ញញឹមមើលទៅបុរសនេះ ។ គឺមហាកាល ។ មហាកាលមកដល់ វិសេសភក្តីរហ័ស សួរមុនទៅថា ÷

— ម៉េចទៅកាល រឿងមាសនោះ ...

---

(១) សូមមើលឈ្មោះនេះក្នុងរឿង "ទោសពានវាំង"

(២) វិសេសភក្តីនេះ ជាមិត្តរបស់ កំហែងពេជ្រ កាលរៀនវិជ្ជាចម្បាំងជាមួយគ្នានៅឯក្រុងឧត្តុងមានជ័យ ។ ត្រូវជាគ្រូមហាកាល. នភា. មហាឫទ្ធិ. អរុណ. រាហុលផងដែរ ។ សូមមើលឈ្មោះនេះក្នុងរឿង "កំហែងរាជ្យ" របស់លោក ឡាំង ប៉េងសៀក

មហាកាលឆ្លើយដោយរីករាយថា ÷

— ហាំ ! ហាំ ! បីថ្ងៃទៀតមាសនោះទៅដល់សេរីសោភ័ណជាស្រេច ។ ក្រុមទ័ពខ្ញុំបានចូលទៅលួចទ្រព្យសម្បត្តិ ព្រះនរិន្ទវង្សរលីង ... បានមាសប្រមាណប្រាំបីហាប. បានពេជ្រ. បានសាច់ប្រាក់ដប់ហាប ។ ហាំ! ហាំ ! គួរជាទីអស្ចារ្យមែន. ឥឡូវមាសនៅក្នុងកណ្ដាប់ដៃយើងហើយ. រូចម្កុដរាជ្រនិងប្រាសាទរបស់ព្រះនរិន្ទវង្សនឹងក្លាយជាផេះ នៅពេលខាងមុខនេះ ។ ព្រះនរិន្ទវង្សជាក្សត្រវង្វេងរាជ្យ ក្សត្រដែលធ្លាក់ខ្លួនក្រ ចាំតែពេលស្លាប់ប៉ុណ្ណោះ ។

— យី ! កាល ឯងចំជាមនុស្សពូកែមែន

— បាទ ខ្ញុំបានដំណឹងពីនភាភ្លាម. ខ្ញុំចាត់ការជាបន្ទាន់ ឥតបង្អង់យូរ

— គ្នាយើងប្រមូលបានគ្រប់គ្នាទេ ?

— បាទ ! បាត់ លលកពូន[១] ដំបូកពេជ្រ[១] និងនាងសោភ័ណទេវីដែល គេនាំគ្នាចុះទៅទន្លេសាបបាត់

— ចុះឪពុកខ្ញុំ ? ប្អូនស្រីខ្ញុំ ? គ្រួសារខ្ញុំ កាលឯងមានចាប់បានទេ ?

— ... បាទ លោកគ្រូ ! ជូនជាបន្ទាន់ពេកក្នុងរឿងមាស ពេជ្រ

---

[១] សូមមើលឈ្មោះអ្នកទាំងនេះក្នុងរឿង "សេនាកំហែង" ឬ "ទោសពានរាំង" របស់លោក ឡាំង-ប៉េងសៀក

[២] វិសេសភក្ដីនេះ ជាកូនរបស់លោកឧបរាជនៃនគរទ្រាសនេះត្រូវជាក្មួយព្រះបាទនរិន្ទវង្ស ខាងក្រសែព្រះរាជអគ្គមហេសី ។ សូមអាន "កំហែងរាជ្យ" របស់លោក ឡាំង-ប៉េងសៀក ដែលមានថែងយ៉ាងពិស្ដាររបស់មនុស្សនេះ ។

បណ្ដាលឱ្យក្រុមគ្រួសារលោកគ្រូភៀសខ្លួន ចូលស្រុកសៀមបាត់ ជាមួយញាតិវង្ស ...

— គួរឱ្យស្ដាយណាស់ បិសាចនោះវាទៅកទ័ពមកវាយខ្មែរទៀតហើយ. វាទៅសំពះបាតជើងបរទេស ឱ្យលើកទ័ពមកវាយកំទេចស្រុកខ្មែរ ។ គ្រោងការខ្ញុំ គឺត្រូវសម្លាប់ក្រុមស្ដេច និងក្រុមគ្រួសារខ្ញុំចោលទាំងអស់ ...

មហាកាល សម្លឹងមុខវិសេសភក្ដីដោយក្រសែភ្នែកស្ងើចនឹងទឹកនេះ។ វិសេសភក្ដី មើលឃើញក្រសែភ្នែកនោះ និយាយថា ÷

— ទៅធ្វល់អីកាល កិច្ចការផែនដី ជាកិច្ចការផែនដី ឪពុកជាឪពុក គ្រួសារជាគ្រួសារ ។ ឥឡូវចប់ការហើយ រៀបទ័ពចូលកំទេចវាំងឱ្យរលាយជាផេះ ... ទៅចុះ ។

ប៉ុន្មានម៉ោងក្រោយមក សង្គ្រាមក៏ឮឹងឡើងខ្លាំងជាងមុន ដែលធ្វើឱ្យទ័ពព្រះរាជាមានបារម្ភជាខ្លាំង ។ មែន ! អ្នកនៅខាងក្នុងអន្ទះអន្ទែង មិនខុសពីសត្វត្រីដែលជាប់ទ្រូអ្នកនេសាទនោះទេ ។ ក្រុមទ័ពអ្នកខាងក្នុង វេចុះវេឡើង បីដូចដីរសា ដែលស្លូខ្យល់មុនពេលស្លាប់ ។

ល្ងាចត្រជាក់មកដល់ ...

ក្រុមទ័ពវិសេសភក្ដី វាយទម្លាយកំផែងវាំងបាន ធ្វើឱ្យទ័ពព្រះរាជារត់ខ្ចាយចោលកន្លែងទាំងជួរៗ រប៉ាត់រប៉ាយយ៉ាងឥតសណ្ដាប់ធ្នាប់ យកតែព្រះអាយុរៀងខ្លួន ។ គឺបរាជ័យ ។

ទាហានខាងវិសេសភក្ដី ក៏បោលចូលកាប់ចាក់ឥតសំចៃ ដេញពួកទាហានហ្លួងដូចឆ្កែដេញទន្សាយ ។

# ក្បត្រូវខ្ទេចរាជ្យ

កលិយុគនៅរាជធានីក្រុងនគរទ្រាស ដែលមានមកចំនួនបីថ្ងៃមក ហើយនោះ ទើបតែរលត់ទៅថ្មី១ ដោយជ័យជំនះទាំងស្រុងធ្លាក់មកលើទ័ពក្រុមបដិវត្តន៍ ដែលអ្នកផ្ដើមទាំងអស់ សុទ្ធជាមេទ័ពធ្លាប់ទទួលការអប់រំពីរឿងជាតិ. រឿងនគរ ... ពីវិសេសភក្ដីជាគ្រូ ។

ជ័យជំនះនេះ ធ្វើឱ្យស្គរកាំភ្លើងស្ងប់. ដាវទាំងឡាយចូលទៅក្នុងស្រោមវិញ. ឈាមរាស្ត្រក៏លែងហូរ. ជីវិតរាស្ត្រក៏ឈប់បង់ ។ វិបត្តិសង្គមត្រូវគេយកមកដោះស្រាយជាបន្ដបន្ទាប់ ។ បញ្ហាសិទ្ធិ សេរីភាព សមភាពដែលជាឆន្ទៈ ពិស្ដាររបស់រាស្ត្រ ត្រូវបើកលែងឱ្យរាស្ត្រប្រើដោយសេរី ។ គេប្រមូលមេទ័ពទាំងអស់ មកជួយចាត់ចែងរៀបចំស្រុកទេស តាមឆន្ទៈប្រជារាស្ត្រ. គឺរាស្ត្រអាចរៀបចំវាសនាខ្លួនបានតាមចិត្ត ។ គេលើកវិសេសភក្ដីជាមេទ័ពធំទទួលការខុសត្រូវលើវាសនានគរក្រុងទ្រាស ។ វិសេសភក្ដីបានអញ្ជើញលោក ឧកញ៉ាក្រឡាហោមវង្សា[១]. ឧកញ៉ាវិធូភក្ដីយុត[១] និងកំហែងពេជ្រ[១] មកកាន់ក្រុងនគរទ្រាសជាផ្លូវការ ពិភាក្សាការរួបរួមសាមគ្គីរវាងនគរទាំងពីរ ដើម្បីឫទ្ធានុភាពខ្មែរយើង ។

សូមជម្រាបថា នៅចុងសតវត្សទី ១៧ នគរកម្ពុជាត្រូវបែងចែកជា

---

[១] សូមមើលឈ្មោះនេះក្នុងរឿង "ទោសពានរាំង" របស់លោក ឡាំង-ប៉េងសៀក

រដ្ឋតូវ១ ជាច្រើនដោយមានស្ដេចក្រាញ់មួយអង្គ១ ឡើងសោយរាជ្យ ។ គឺនៅឱកាសបែងចែកអំណាចក្នុងរដ្ឋតូច១ នោះហើយដែលបណ្ដាលឱ្យខ្មែរចុះអនុភាពរៀង១ មករហូតទល់ពេលយើងនិទានរឿងនេះ គឺនៅដើមសតវត្ស ទី ១៨ ។

បញ្ហាធំដែលត្រូវបិភាក្សានោះគឺរួមទាំងនគរតាឃិល និងនគរទ្រាសជារដ្ឋតែមួយ ព្រោះរាស្ត្រនៅនគរតាឃិលក៏មានឈាមជាខ្មែរ រាស្ត្រនៅក្នុងនគរទ្រាសក៏មានឈាមជាខ្មែរ. តើប្រយោជន៍អីឱ្យនៅបែកខ្ញែកគ្នាហាក់ដូចជាកុលសម្ពន្ធនោះ ?

នគរក្រុងទ្រាសទើបនឹងរួចផុតពីកណ្ដាប់ដៃស្ដេចក្រាញ់ថ្មី១ ត្រូវពឹងពាក់លើសន្ដានចិត្តខ្មែរ ស្រឡាញ់ខ្មែរ. ចាប់អនុវត្តតាមគោលការណ៍នយោបាយនគរតាឃិលដែលកាលពីដប់ឆ្នាំមុន បានរើផុតពីកណ្ដាប់ដៃស្ដេចក្រាញ់នោះដែរ (១) ។ ដូច្នេះបញ្ហាពិភាក្សារួមគ្នារវាងនគរទាំងពីរ អាចជម្រុញក្ដីសង្ឃឹមឱ្យដល់កម្រិត ក្នុងការបង្រួមជាតិខ្មែរនេះ ។

គេរៀបចំច្បាប់គ្រប់អន្លើតាម ខ តាមខណ្ឌក្នុងនោះចែងតែពីសេរីភាពរបស់រាស្ត្រដែលវត្ថុទាំងនេះ ហាក់ជាទឹកអម្រិតស្រោចឱ្យរាស្ត្របានលូតទៅមុខ ។ រួមមក ឆន្ទៈរបស់អ្នកគ្រប់គ្រងរដ្ឋទាំងពីរមានយោបល់ស្របគ្នាគឺគិតប្រយោជន៍សាធារណៈមុនប្រយោជន៍វណ្ណៈ ។ គឺឆន្ទៈនេះហើយ ដែលនាំឱ្យមេទ័ព. ពលទាហាន. មន្ត្រីគ្រប់ក្រសួង រាស្ត្រគ្រប់វណ្ណៈ ចូលគ្នាជាធ្លុង

---

(១) សូមមើលព្រឹត្តិការណ៍នេះក្នុងរឿង "ទោសពានវាំង"

មួយក្នុងការបំរើជាតិ ។ ឆន្ទៈនេះនាំឱ្យវិសេសភក្តិ ដែលជាមនុស្សសេរី ដក់ចិត្តស្រឡាញ់ជាតិ ស្រឡាញ់ខ្មែរជាពន់ប្រមាណលើសពីជីវិតខ្លួនទៅទៀត នោះ រិតតែមានកម្លាំងចិត្តក្នុងការតស៊ូ ដើម្បីមាតុភូមិ ។

ខែមួយ ... ខែពីរ ... កន្លងទៅ ...

ចូលអម្លុងខែទីបី ព្រឹត្តិការណ៍គ្រប់គ្រងនៅនគរក្រុងទ្រាសយើងចាប់ប្រែប្រួលបន្តិចម្តង១ ។ នាម៉ឺន មន្ត្រីធំ១ ទាំងឡាយខ្លះ ដែលជាមនុស្សរបស់ព្រះនរិន្ទវង្ស ហើយដែលក្នុងឱកាសផ្លាស់របបគ្រប់គ្រងនេះ វិសេសភក្តិពុំបានធ្វើទុក្ខទោសសោះនោះ បានធ្វើការមួយបណ្តាលឱ្យមានពពកស្មាប់ក្នុងនយោបាយរៀបចំ ស្រុកទេសតាមបែបថ្មីរបស់យើង ។

មានចិត្តបដិវត្តកែប្រែរបបគ្រប់គ្រង តែវិសេសភក្តិ សិស្សជំនិតព្រមទាំងប្រជាជនភាគច្រើន តែនាម៉ឺនភាគច្រើនជាអ្នកចាត់ចែងការនៅក្នុងនគរនោះ សុទ្ធតែជាមនុស្សក្បាលចាស់ជ្រុលហួសសម័យទៅហើយ តើអង្គការបដិវត្តន៍យើងអាចឈានទៅបានស្រួលឬទេ ?

នៅក្នុងសង្គមនេះ គឺមន្ត្រីមួយជំពូកខាងក្រោយនោះហើយ ដែលលូកដៃកកូរកកាយធ្វើឱ្យមានវិបត្តិនយោបាយមួយ ផ្គុំគ្រឿង ប្រទាញគ្នាជាលំដាប់បន្តបន្ទាប់ បណ្តាលឱ្យនាវានគរក្រុងទ្រាសយើងស្ថិតនៅក្នុងស្ថានភាពដ៏លំបាកជាច្រើនខែ ។

រឿងនេះបណ្តាលឱ្យវិសេសភក្តិ កើតទុក្ខជាខ្លាំង ... ។

ថ្ងៃនោះ ...

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

អំពីបន្ទាយក្រុងនគរទ្រាស. គេឮសូរតែភ្លេងរងុំនៅខាងក្នុង ហើយយូរ ឮសូរសម្លេងស្រីច្រៀងពីរោះគ្រលួច កាត់ខ្សែរាត្រី ។ អ្នកផង កាលបើបានដើរកាត់បន្ទាយដែលកាលដើមជារាជវាំងក្រុងនគរទ្រាសនោះហើយ ក៏តែងឈប់ផ្ទៀងត្រចៀកស្តាប់ រួចដណ្តឹងសួរក្នុងចិត្តថា តើគេធ្វើអ្វីក្នុងប្រាសាទនោះ ?

បើចូលទៅខាងក្នុង គេក៏អាចដឹងបានថា គឺជាពិធីសមរបាំបុរាណខ្មែរ ដែលចាប់ពីបានកាន់កាប់ការរដ្ឋនោះមក វិសេសភក្តិ ព្រមទាំងនាម៉ឺនចាស់ទុំខ្លះ បានប្រមូលស្រីរបាំទាំងអស់មកឱ្យហាត់ ដោយត្រឹមត្រូវវិញ ។ កាលពីក្នុងរាជ្យមុន ស្រីរបាំង គឺជាស្រីកំណាន់របស់ស្តេច. ជាស្រីដែលក្រុមស្តេចសម្រាំងទុកដើម្បីតែសេចក្តីសប្បាយផ្ទាល់ខ្លួន ហើយការរាំល្អ មិនល្អ ចំតួជាសិល្បៈខ្មែរមែនឬមិនមែននោះ គឺគេពុំបាននឹកនាដល់សោះទេ [១] ។

នារីដ៏ល្អៗ កំពុងរេរាំតាមចង្វាក់ភ្លេងដ៏សមឥតខ្ចោះ ។ សូរភ្លេងដែលបន្លឺឡើងធ្វើឱ្យយើងអ្នកស្តាប់ កើតចិត្តស្រឡាញ់សិល្បៈខ្មែរ. ស្រឡាញ់ព្រលឹងខ្មែរអ្វីម្ល៉េះទេ !

ឱខ្មែរ ! ... មិនត្រឹមតែទឹកមុខ សំដីសម្តៅប៉ុណ្ណោះទេ ដែលបង្ហាញថាខ្មែរជាមនុស្សស្លូតត្រង់ សូម្បីតែសិល្បៈភ្លេងដែលរងំ. ដែលទន់ភ្លន់ ដែលស្លូត មិនតូងតាង ក៏គេអាចមើលធ្លុះដល់ចិត្តខ្មែរខាងក្នុងនោះបានដែរ ។ ជើងដែលដើរ. ចង្កេះដែលកាច់ ដៃដែលលើក នាំចិត្តយើងឱ្យនឹកទៅដល់

---

[១] សូមមើលព្រឹត្តិការណ៍នេះដែលអ្នកនិពន្ធថៃងយ៉ាងពិស្តារ ក្នុងរឿង "កំហែងរាជ្យ"

[library stamp, partly legible: ... SEN LIBRA...]

សិល្បៈបុរាណសម័យអង្គរ ក្នុងសតវត្សទី១២ ដែលឆ្លាក់ជាប់លើជញ្ជាំង ប្រាសាទអង្គរវត្ត រូចយើងមានតែក្តីរំភើប ញាប់ញ័រ កោតសរសើរស្នាដៃ ដ៏ណែលចាស់បុរាណក្រៃពេក. នឹកស្ញើចដល់កិត្យានុភាពខ្មែរពីព្រេងនាយ នោះមិនចេះអស់មិនចេះហើយ ។

ឱសិល្បៈខ្មែរ ... គឺជាសញ្ញាដួងព្រលឹងខ្មែរ មិនត្រឹមតែជាសិល្បៈ ត្រឹមត្រូវប៉ុណ្ណោះទេ សិល្បៈយើងនេះគឺជាសិល្បៈសម្រាប់ជនមិន រើសវណ្ណៈ. ហើយមិនអាចជាតិណាមកក្រឡេលួចចម្លងឱ្យដូចបានឡើយ ។ បានទស្សនា សិល្បៈខ្មែរ យើងក៏កើតចិត្តរីករាយ សរសើរសំណាងយើងដែល បានកើត មកជាខ្មែរ ហើយមានសិល្បៈ មួយដ៏ល្អប្រចាំជាតិ ។

នៅកៅអីជួរខាងមុខ គឺអស់មន្ត្រីធំៗ ដែលមានលោកឧកញ៉ាក្រឡាហោមវង្ស[១]. លោកវិចូភក្តីយុត[១]. កំហែងពេជ្រ[១]. នាងសោភ័ណទេវី[១] អង្គុយមើលកញ្ញារាំយ៉ាងថ្មើងថ្កាន ។ នៅក្បៀនក្បែរៗសសរ គឺជា ស្រីចំណាស់ពាក់កណ្តាលមនុស្សបីនាក់ និងនារីក្មេងស្រស់ចំណាប់ម្នាក់កំពុង ធ្វើសញ្ញាដល់អ្នករាំ ... ។ គឺជាគ្រូរបាំង ។ ... ឃ្លាតពីនេះប្រហែលបី ម៉ែត្រ ក្បែរបង្អួច គេសង្កេតឃើញវិសេសភក្តី ចន្ថា. រាហុល. មហាកាល ។ វិសេសភក្តីមានទឹកមុខរីករាយ. យូរៗគេឃើញលោកសើចយ៉ាងក្អាកក្អាយ

---

[១] ជាតស្សរជនដ៏មានថ្វីដៃក្នុងសង្គ្រាមជ័យ ដែលក្នុងពេលនេះគេចាត់ទុកជាទី ប្រឹក្សារដ្ឋ ។ សូមមើលឈ្មោះនេះក្នុងរឿង "កំហែងរាជ្យ" ឬ "ទោសពានវាំង" របស់ ឡាំង-ប៉េងសៀក

រួចលើកដៃជាសញ្ញាដល់ស្រីគ្រូរបាំដ៏ក្មេង ...ធ្វើឱ្យយើងដឹងថាគេទាំងពីរជាគូកំណាន់និងគ្នាជាប្រាកដ ។

តែ ... មិនយូរប៉ុន្មានទឹកមុខវិសេសភក្តីយើងប្រែជាស្រពោនទៅវិញ ។ សូរភ្លេង ក្បាច់រាំនារីកំណាន់ ក៏ក្លាយទៅជាវត្ថុអត់វិញ្ញាណអស់ ។ អ្នកឈប់និយាយទៅរកនរណាទាំងអស់ ។ ភ្លេងនៅតែលេង របាំនៅតែបន្ត។

រាហុលដែលឃើញមុនវិសេសភក្តី ស្រគត់ស្រគំបែបនេះក៏ហារមាត់សួរទៅថា ÷

— អម្បាញ់មិញ. ខ្ញុំបាទសង្កេតឃើញថាលោកគ្រូសើចសប្បាយ ចុះហេតុយ៉ាងណាបានជាឥឡូវប្រែជាយ៉ាងដូច្នេះទៅវិញ ទានប្រោស

វិសេសភក្តីដកដង្ហើមធំ ឆ្លើយតិចៗ ទៅថា ÷

— ខ្ញុំនឹកឃើញរឿងមួយគួរឱ្យព្រួយខ្លាំងណាស់ បងអើយ ជម្ងឺព្រួយរបស់ខ្ញុំនេះ ជាក់ជាគ្មានឱសថណាមកកែបានទេ ។

រាហុលនៅស្ងៀម ឯមហាកាលដែលនៅជិតនោះក៏ប្រឹងសម្លឹងទឹកមុខវិសេសភក្តីព្រេចៗ ហាក់ដូចគ្រូពេទ្យមើលទឹកមុខអ្នកជម្ងឺ ដើម្បីរកមេរោគដ៏សាហាវមួយ ។ កាយវិការនេះធ្វើឱ្យយើងដឹងថាអ្នកទាំងនេះ មានសេចក្តីគោរពស្រឡាញ់មួយយ៉ាងខ្ជាប់ខ្ជួន ដល់វិសេសភក្តីជាគ្រូ ។ ចន្ថាដែលនៅពីក្រោយខ្នងរាហុល ក៏បញ្ចូលសម្លេងមួយទៅថា ÷

— ខ្ញុំចឹងដឹងថា តើរឿងអីទៅដែលនាំឱ្យលោកគ្រូព្រួយចិត្តដល់ម្លឹង

វិសេសភក្តី ងាកមើលមុខចន្ថាប្រកបដោយក្រសែភ្នែកស្រឡាញ់រាប់អាន

— កុំចង់ដឹងអីចន្ទា ព្រោះជារឿងមួយផ្សេង

— ទេលោកគ្រូ ! ខ្ញុំចង់ដឹងណាស់

— ... ជារឿងដែលគេពុំអាចនឹកនាដល់. ហើយជារឿងដែលផ្សេង ព្រេងហួសប្រមាណ ។ ណ្ហើយ ! ទាំងរាហុល ទាំងបងកាល. ទាំងចន្ទាឯង តោងកុំចង់ដឹងធ្វើអី ។

អ្នកទាំងបីដូចមានឈ្មោះខាងលើនេះ ចង់ដឹងជាខ្លាំងព្រោះរឿង របស់វិសេសភក្តី សូម្បីតែតូចមួយក៏ហាក់មានប្រយោជន៍ក្រៃលែងចំពោះ អ្នក ឱ្យតែវិសេសភក្តីព្រមនិយាយឱ្យស្តាប់ ។ អ្នកទាំងបីស្រឡាញ់វិសេស ភក្តីនោះគឺស្រឡាញ់ពេក ។

រាហុលសួរទៅដោយស្លូតស្ងប់ថា ÷

— បែបលោកគ្រូមិនទុកចិត្តខ្ញុំទាំងបីនេះហើយ បានជាលាក់រឿង កង្វល់នោះ តែលោកគ្រូមានគុណមកលើខ្ញុំទាំងបីនេះណាស់ ដោយបណ្តុះ បណ្តាលឱ្យខ្ញុំមានចិត្តនិងថ្មីដៃ និងចិត្តស្នេហាជាតិដូចសព្វថ្ងៃ ...

ពាក្យនេះមានសំនួនដ៏ខ្លាំងក្លាមែន ព្រោះពេលនោះ វិសេសភក្តី ទាញស្មាអ្នកទាំងបី ឱ្យត្រចៀកនៅជិតមាត់អ្នកហើយខ្សិបថា ÷

— ខ្ញុំចង់ចេញពីទីនេះ ... ទៅឆ្ងាយ ...

អ្នកទាំងបីស្រឡាំងកាំង ។ មហាកាល ភ្ញាត់មាត់ថា ÷

— ... លោកគ្រូ ...

វិសេសភក្តី ខ្ទប់មាត់មហាកាល

— កុំមាត់ ... កុំឱ្យនរណាដឹងទាំងអស់ ព្រោះជារឿងសម្ងាត់បំផុត ។ មក ! មកតាមខ្ញុំ. ខ្ញុំនិយាយរឿងមួយដ៏ចម្លែកប្រាប់ ... ទៅ ... ទៅបន្ទប់សម្ងាត់របស់ខ្ញុំ ...

វិសេសភក្តិ. មហាកាល. រាហុល និង ចន្ថា ក៏ក្រោកដើរចេញពីកន្លែងរាំ ទៅកាន់បន្ទប់មួយនៅអគារខាងកើត ដែលជាអតីតបន្ទប់ជុំនំការរបស់រាជាក្នុងរាជ្យមុន ។

សិស្សទាំងបីអង្គុយនៅខាងក្បែន ... ឯវិសេសភក្តិដើរចុះ ដើរឡើងក្រឡឹងតែក្នុងបន្ទប់នោះដោយនិយាយថា ÷

— ... ខ្ញុំស្គាល់អាមនុស្សក្បាលអាក្រក់ទាំងអស់ក្នុងនគរ ហើយមានព្រះជាប្រធាន ខ្ញុំសច្ចាថានឹងការពារយុត្តិធម៌ជូនប្រជារាស្ត្រ យើងក្នុងពេលខាងមុខនេះ ទោះជាជីវិតខ្ញុំត្រូវរលត់ក៏ខ្ញុំឥតរួញរាដែរ ។ ពួកវាទាំងនោះជានាម៉ឺនធំ តូច ធ្លាប់រកស៊ីរកចុកបានក្នុងរាជ្យមុន ដែលខ្ញុំពុំបានធ្វើទុក្ខធ្វើទោសវាឡើយ ដោយគិតថាទុកឱ្យវាប្រែចិត្តគំនិតចេញ ។ រហូតមកទល់ពេលនេះ ឃើញថាវាឥតប្រែប្រួលបន្តិចសោះទេ ធ្វើឱ្យខ្ញុំមានកង្វល់ជាខ្លាំង ...។ រឿងនេះបណ្តាលឱ្យខ្ញុំនិងលោកក្រឡាហោម ដែលជាអ្នកទទួលខុសត្រូវធំក្នុងរឿងរំលំក្រុមស្តេចនេះ ខូចឈ្មោះដោយតែអំពើក្បត់របស់ពួកវា ...

វាចាខាងលើនេះធ្វើឱ្យរាហុល មហាកាល និងចន្ថាភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ អ្នកឃើញជាប់នឹងភ្នែកថា នាម៉ឺនមួយភាគយ៉ាងធំក្នុងនគរទ្រាស គឺមានគំនិតអាក្រក់ពុករលួយដូចវិសេសភក្តិថានោះមែន តែអ្នកពុំអាចនិយាយ

ពីតទូលឱ្យដឹងដល់វិសេសភក្តិនោះឡើយ ដោយចៀសវាងពាក្យគេថាជាមនុស្សអុជអាល ។ ចាប់ពីមានការប្រែផ្លាស់នៅនគរទ្រាសមក ថ្ងៃនេះគឺថ្ងៃទីមួយហើយដែលអ្នកទាំងបីបានជួបវិសេសភក្តិជាគ្រូ ព្រោះមានសំបុត្រ មួយ ទៅហៅអ្នកមកដើម្បីជុំនំការ ... ។

រាហុលងើបឡើងបញ្ចេញយោបល់ថា

— ក្នុងការរៀបរាប់ដ៏វែងឆ្ងាយនោះ ខ្ញុំបាទចាប់បានចំណុចព្រួយរបស់លោកគ្រូ គឺមានមនុស្សអាក្រក់ក្នុងរដ្ឋាភិបាលលោកគ្រូនោះហើយ ។

— មែន ! មែន ! រាហុលថាន៎ះត្រូវហើយ. រាហុលឯងមើលសូម្បីតែមន្ត្រីខ្លះដែលសច្ចានៅចំពោះមុខខ្ញុំថា ស្មោះត្រង់នឹងរាស្ត្រទៅហើយនោះ បែរជាកន្ទុយខ្មៀនអស់រលីងទៅ ។ អាំ ពួកវាគ្មានចេះជួយធុរៈខ្ញុំទេ. វាជិះខ្ញុំ. នៅមុខខ្ញុំវាធ្វើជាស្មោះត្រង់ នៅក្រោយខ្នងខ្ញុំវាក្បត់ខ្ញុំវាដណ្តើមអំណាចគ្នា. ដណ្តើមគ្នាធ្វើអ្នកមាន ក្នុងឱកាសដែលខ្មែរពេញមួយនគរទ្រាសនេះមានទុក្ខ ... ឃើញទេវាហុតឈាមរាស្ត្រជាក់ស្តែងណាស់ ។ ហឺស ! ខ្ញុំធុញទ្រាន់ណាស់ទៅហើយសព្វថ្ងៃនេះ ហើយលែងចង់បៀត លែងចង់ឃើញ លែងចង់និយាយរកនរណាទាំងអស់ ។ ហ៊ឺ ! មានមួយថ្ងៃនោះខ្ញុំនឹកថាលាលែងពីអ្វីៗ ទាំងអស់ សូមរស់នៅតែជាខ្មែរធម្មតាដោយធ្វើស្រែចិញ្ចឹមសត្វ ឬពុំនោះសោតទេខ្ញុំ នឹងទៅបួសតែម្តង តែដោយនឹកឃើញថាបើខ្ញុំថយខ្លួនទៅហាក់ដូចជាខ្លួនខ្ញុំនេះ រកសុខតែម្នាក់ឯង ហើយអាចនឹងមានពាក្យ ... មានពាក្យគេតិះដៀលខ្ញុំច្រើនណាស់ វាសនាថ្មីនៃនគរទ្រាសដែលខ្ញុំនាំអាទិធ្វើការប្រែផ្លាស់ របបគ្រប់គ្រងនោះមិនដឹងជាយ៉ាងណា

ទៀត ។ គួរឱ្យធុញណាស់សព្វថ្ងៃ ធុញដោយរវល់និយាយ រវល់ដើរកុហក់ដើរលួងលោមគេគ្រប់គ្នា រវល់សរសេរមិនចេះឈប់មិនចេះឈរ ដែលមានជួនកាលពេលខ្លះនោះគេជេរគេស្អប់ទៀតផង រួចដល់ពេលស្លាប់ គឺស្លាប់ដូចតែគេឯង...

អ្នកទាំងបីនៅស្ងាត់ស្ងៀមឈឹង ។ វិសេសភក្តីដើរចុះឡើងៗ

— ខ្ញុំមានបំណងមួយយ៉ាងមាំ ដោយចង់ផ្លាស់ការរស់នៅថ្មី គឺខ្ញុំចង់ចេញទៅនៅតាមភូមិ តាមស្រុក តាមខុម តាមផ្ទះអ្នកស្រុក ដើរពន្យល់ពីសិទ្ធិសេរីភាព និងជួយឃិតឃៀងអ្នកស្រុកយើងតាមកម្លាំងកាយ និងកម្លាំងប្រាជ្ញា. ដើរសាងវាំងថ្មីមួយសម្រាប់ប្រជាជន សម្រាប់រាស្ត្រ សម្រាប់ខ្មែរ ដែលនៅក្នុងវាំងនោះ មានតែមនុស្សចេះ មនុស្សយល់ខុសត្រូវ មនុស្សគ្មានល្បិចអាក្រក់ ជាមនុស្សមានសំដីសំដៅ អាកប្បកិរិយាជាខ្មែរ ... ហើយ ... ហើយខ្ញុំនឹងក្លែងខ្លួនធ្វើជាមនុស្សចម្លែកម្នាក់ ដើរសម្លាប់នរណាដែលក្បត់ខ្មែរ. ដែលព្យាយាមប្រមូលញើសឈាមរាស្ត្រ មកគរផ្តុំធ្វើអ្នកមានម្នាក់ឯង ... អូ ! ... ខ្ញុំលែងគិតបាបបុណ្យអីទាំងអស់ហើយពេលនោះ គឺធ្វើយ៉ាងណាឱ្យតែខ្មែរបានសុខតែប៉ុណ្ណោះ! បងកាលឯងស្តាប់បានទេ ?

មហាកាល ដែលកំពុងជក់ក្នុងការរៀបរាប់ដ៏វែងនោះ ភ្ញាក់ខ្លួនរួចតបថា ÷

— បើលោកគ្រូអញ្ជើញទៅតាមគ្រប់ច្រកល្ហក នៃស្រុកស្រែចំការនោះ ជីវភាពខ្សត់ខ្សោយនៃប្រជារាស្ត្រ យើងអាចបង្ហាញលោកគ្រូឱ្យឃើញតែ

មានគំនិតវែងឆ្ងាយទៅទៀត តែជីវិតដែលដើរសិក្សាពីព្រលឹងខ្មែរ ពីចិត្តខ្មែរ ពីជីវភាពខ្មែរ នោះជាការមួយវេទនាណាស់ . . .

— ទេ ! ទេ ! ខ្ញុំមិនខ្លាចការលំបាកវេទនាអ្វីទាំងអស់. ខ្ញុំហ៊ានចាកចោលបុណ្យសក្តិហើយ គឺខ្ញុំអាចទ្រាំទ្រការវេទនានោះបានទាំងអស់ ធ្វើយ៉ាងណាឱ្យតែរាស្ត្រយើងបានសុខគឺខ្ញុំត្រេកអរណាស់ទៅហើយ. ត្រូវចាំជាក់ថាខ្ញុំទៅនេះគឺខ្ញុំផ្តាច់ចំណងអស់ហើយ មានចំណងស្នេហាជាដើម ។ កាលឯងដឹងទេ នាងមាលា[១] និងខ្ញុំកំសត់កម្រនឹងគ្នាណាស់ ហើយខ្ញុំអាចនឹងទៅចោលនាងបាន ប្រសិនជាការជាតិនោះមានជាចាំបាច់ . . .

ចន្ទានិយាយស្ទើរយំថា ÷

— លោកគ្រូគិតអញ្ជើញទៅមែនឬអីទានប្រោស

— ខ្ញុំមិនចេះនិយាយលេងទេចន្ទា ខ្ញុំគិតទុកយូរហើយ រង់ចាំតែឱកាសប៉ុណ្ណោះ. តែខ្ញុំមានបំណងទៅតែបូននាក់គ្នាយើងនេះឯង ព្រោះសង្កេតឃើញថា គ្នាយើងទាំងបីនេះមានថ្មីដែងកគ្រាន់បើ. ឯអត្ថ. លលកពូន. មហាឫទ្ធិ. នភា និងអ្នកឯទៀតនេះឱ្យនៅការពារក្រុងសិនចុះ. ហើយខ្ញុំក៏បានផ្ញើចុតហ្មាយទៅអញ្ជើញកំហែងពេជ្យ និងលោកគ្រូវិធូភក្តីយុត មកជួយរៀបចំស្រុកទេសនៅនគរទ្រាសនេះដែរ . . . អុំះនែ់ ! ខ្ញុំភ្លេចប្រាប់ទៅពេលមុនធ្វើរដ្ឋប្រហារមុននេះ ខ្ញុំបានលួចយកឯកសារច្រើនណាស់ពីព្រះ

---

[១] សូមមើលឈ្មោះនេះក្នុងរឿង "កំហែងរាជ្យ" របស់លោក ឡាំង-ប៉េងសៀក ។ ជាបុត្រីលោកនរាយណ៍កាឡាគ្រូរបស់វិសេសភក្តី ។ នាងជាស្រីរបាំ . . .

នរិន្ទវង្ស និងឪពុកខ្ញុំដែលសុំគ្រលំជាមួយព្រះចៅក្រុងអយុធ្យា ក្នុងការប្រគល់ខេត្តបាត់ដំបង. ពោធិសាត់. មង្គលបុរី. ទន្លេពៅទៅស្រុកសៀម ... ឃើញទេ ! ចិត្តស្ដេចអាក្រក់អាក្រីខ្លាំងណាស់. ទទួលខ្ញុំដឹងការទាន់ក៏លួចត្រាអាជ្ញាសឹកនិងសំបុត្រស្នាមទាំងអស់នោះមក ព្រមទាំងបានមាសជាច្រើនផង ធ្វើឱ្យពួកវាធ្វើការអីពុំទាន់ ។ តោងដឹងថា ក្នុងរដ្ឋាភិបាលយើងសព្វថ្ងៃនេះក៏មានមនុស្សក្បត់រួមជាមួយព្រះនរិន្ទវង្សនោះច្រើនដែរ តោងប្រយ័ត្នមនុស្សទាំងនេះ ...

មហាកាលលាន់មាត់ថា ÷

— ឃើពួកវាសាហាវណាស់តើ. អីចឹងហើយបានជាមានរាជបុត្រព្រះចៅក្រុងអយុធ្យា មកសុំចងសម្ពន្ធមេត្រីជាមួយព្រះនាង ... ការនោះគួរឱ្យអស្ចារ្យណាស់

— ហ្នឹងហើយ ! គឺព្រះដារាវង្ស ដែលព្រះនរិន្ទវង្សប្រុងរៀបអភិសេកជាមួយប្អូនស្រីខ្ញុំ ដោយមានការដឹកនាំបញ្ចុកបន្សីពីឪពុកខ្ញុំផង ...

ចន្ទាក្រោកសួរថា ÷

— តើពេលណាទើបយើងអាចចេញធ្វើដំណើរផ្សងព្រេងដូច្នេះបាន ?

វិសេសភក្ដិមានភក្ត្រញញឹមឡើងវិញ

— កន្លះខែទៀត. នៅកន្លះខែទៀតនោះ មានចម្បាំងយ៉ាងធំ ព្រោះខ្ញុំបានដំណឹងថាព្រះនរិន្ទវង្ស. ឪពុកខ្ញុំព្រមទាំងព្រះចៅក្រុងអយុធ្យា កំពុងរៀបចំទ័ពមកវាយក្រុងនគរទ្រោសយើងនេះ ។ ពេលនោះខ្ញុំនាំទ័ពទៅតទល់រួចក្លែងខ្លួនជាស្លាប់ក្នុងសង្គ្រាម ... ជយោបងកាល ! ខ្ញុំធ្វើឱ្យគេជឿថាខ្ញុំ

ស្លាប់. រួចខ្ញុំក៏ក្លាយជាមនុស្សសេរី. ទៅណាមកណាបានតាមចិត្ត ។ យើងដើរតាមភូមិនិគមអ្នកស្រុក អប់រំអ្នកស្រុកយើងតាមគោលការណ៍ពលរដ្ឋសេរី ។ ឱបងអើយ ! ត្រូវពន្យល់រាស្ត្រយើងឱ្យជាក់ច្បាស់ពីរឿងឯករាជ្យទេ ព្រោះនគរឯករាជ្យ ហើយមនុស្សមិនឯករាជ្យ. ឯករាជ្យនោះក៏មិនអាចគង់វង្សបានដែរ ។ ឯករាជ្យសេរីភាពមានជំហររឹងប៉ឹងលុះណាតែរាស្ត្រយើងអស់កំអែលខ្ញុំគេពីក្បាល ។ ក្នុងសង្គមដែលនៅជុំវិញខ្ញុំនេះ គឺសង្គមមនុស្សខ្ញុំគេ ពោរពេញទៅដោយខូរអយុត្តិធម៌. មនុស្សជោរ. ស្រវាស្រទេញស្រឡាញ់បុណ្យសក្តិ ឥតមូលហេតុ រួចកៀបកជនទន់ខ្សោយមួយជំពូកទៀត ។ ហឺ ! សង្គមអាក្រក់នេះគ្មានពាក្យអ្វីនិយាយឱ្យស្តាប់បានឡើយ ហើយបើចង់ដោះស្រាយឱ្យបានឆាប់រហ័ស គឺជំរះមនុស្សទាំងនេះចោលចេញ បីដូចជាគេជំរះស្មៅទាំងឫសដូច្នោះ រួចសាងសង្គមមួយថ្មីជូនប្រជាពលរដ្ឋយើងតាមបែបសណ្ឋានខ្មែរពិត១ ។ ទៅ ! ទៅ ! ... បងទាំងបី យើងទៅទាំងអស់គ្នា ទៅចោលបុណ្យចោលសក្តិ ចោលស្រីស្នេហា ចោលអ្វី១ ទាំងអស់ ដើម្បីខ្មែរបានសុខ. ហើយចាំថ្ងៃជ័យសឹមយើងនាំគ្នាត្រឡប់មកវិញ. គឺនៅថ្ងៃដែលរាស្ត្រយើងមានសិទ្ធិសេរីភាព ពេញលេញ ... ទៅបង ! ខ្ញុំប្តេជ្ញាចិត្តថាបើរាស្ត្រយើងពុំបានសុខទេ ខ្ញុំសុខចិត្តស្លាប់ ...

ចាប់និយាយពីព្រះរាជវង្សានុវង្ស ដែលភៀសចេញពីព្រះរាជវាំងក្រុងនគរទ្រាស ...

ថ្ងៃរដ្ឋប្រហារនោះ ដោយមានរាជអង្គរក្សអមព្រះដំណើរផង. អស់ក្សត្រា ក្សត្រី អគ្គមហេសី ជំទាវខុនណាងបានធ្វើដំណើរក្នុងរូងសម្ងាត់ ដែល

មានគ្រឿងយន្តនោះ[១] ហើយកន្លះថ្ងៃក្រោយមក ក្រុមភៀសខ្លួនទាំងនោះបានទៅដល់ក្រុងអាយុធ្យាបានដោយសេរី ។

លោកឧបរាជនៃក្រុងនគរទ្រាស ដែលត្រូវជាឪពុករបស់ វិសេសភក្តី ហើយនិងត្រូវជាមារបស់ព្រះនរិន្ទវង្ស មានចិត្តក្តៅក្រហាយជាខ្លាំង ដោយបុណ្យសក្តិទាំងដុំ ទាំងកំភួនដែលលោកកាន់ខ្ជាប់នឹងដៃ កាលមុននោះរលាយរលត់បាត់បង់អស់ ដោយសារស្នាដៃវិសេសភក្តីជាកូន ។ គួរឱ្យក្តៅណាស់ព្រះអើយ ធ្លាប់ធំ ធ្លាប់មានគេគោរព ធ្លាប់មានសេនាបំរើឆ្វេងស្តាំពុំមានទាស់ក្នុងនាទីណា. រួចឥឡូវបែជាព្រាត់ស្រុកព្រាត់ទេស មកនៅត្រមង់ត្រមោចក្នុងស្រុកឆ្ងាយ ជាតិសាសន៍សំដីសំដៅក៏ខុសគ្នាទៀត. រួចមិនដឹងជាគេស្មោះត្រង់នឹងខ្លួនមួយ ឬក៏គេទទួលខ្លួនឱ្យនៅសំចតនោះ គ្រាន់តែជាកត្តាមួយបំបែកប្រទេសកម្ពុជាទាំងមូលឱ្យក្លាយជារដ្ឋខ្ញុំគេ ?

... តែទោះជាយ៉ាងណាក៏ដោយ ទោះកម្ពុជា. ទោះនគរក្រុងទ្រាស ក្លាយជាអ្វីក៏ដោយ ត្រូវតែដណ្តើមអំណាចនោះមកក្តាប់នៅដៃសិន ... ព្រោះអំណាចនេះធ្វើឱ្យមនុស្សទាំងនគរ អោនកាយគោរព ព្រោះអំណាចនេះអាចខាបមាសខាបប្រាក់ធនធានឱ្យហូរចូលទូរដែកដោយឥតបង្ខំ ។

ព្រះថាណងសក្តិព្រះចៅក្រុងអាយុធ្យា បានទទួលផ្តុងផ្តើមឱ្យក្សត្រ និងអស់នាម៉ឺនវង្វេងវាំងទាំងប៉ុន្មាននោះ ធ្វើនយោបាយបំបែកជាតិខ្មែរ ... ដែលខ្មែរទាំងយើងទាំងគេកើតក្តីឈឺចាប់ពន់ប្រមាណ ។

---

[១] រូងសម្ងាត់នេះវិសេសភក្តីបានដឹងដល់ ហើយបាននិយាយប្រាប់គេឯងក្នុងវគ្គមុន

កាយសិទ្ធិ[១] ជាបុត្រពៅរបស់លោកឧបរាជ និងជាប្អូនរបស់វិសេសភក្តិ ដែលនៅរៀនវិជ្ជាចម្បាំងនៅក្រុងអយុធ្យានោះត្រូវគេតែងតាំងជាអគ្គមេបញ្ជាការធំក្នុងកងទ័ពថ្មីរបស់ព្រះនរិន្ទវង្ស[១] ។

កងពលថ្មីដែលនរិន្ទវង្សរៀបចំបាននៅក្រុងអយុធ្យានោះ មានចំនួនពីរម៉ឺនបីពាន់បួនរយសាមសិបនាក់ ដោយមានកងទ័ពព្រះបាទថាណេងសក្តិមួយចំនួនធំចូលលាយផង ។ គេប្រឹងហាត់វិជ្ជាចម្បាំងរាល់ថ្ងៃរាល់ពេល ឥតស្រាកស្រាន្តក្នុងបំណងកំទេចខ្មែរឱ្យរលាយទៅជាផេះ ដើម្បីតែម្យ៉ាងគឺបំពាក់កម្ពុជរាជលើព្រះនរិន្ទវង្សនេះវិញ ។ ... ដំណឹងថាព្រះនរិន្ទវង្សរៀបចំទ័ពមកវាយក្រុងនគរទ្រាសនេះ បានលេចឮត១ គ្នាមក ធ្វើឱ្យរាស្ត្រយើងនៅទល់ដែន ភ័យ. ព្រួយ. ខ្លះរត់ចោលស្រុក ចោលភូមិ ចោលផ្ទះសម្បែង មកតាំងទីនៅជិតក្រុង ... ។

ថ្ងៃប្រាំកើតខែពិសាខ ...

មានអព្ភូតហេតុឡើងយ៉ាងអស្ចារ្យ ក្នុងរង្វង់មេឃនៃក្រុងទ្រាស ។ គឺផ្កាយដុះកន្ទុយ ។ តាមចាស់ទុំគឺស្រុកកើតសង្គ្រាម ស្រុកក្រ ។ រាស្ត្រដែលម្ចាស់ស្រុកងើយមើលមេឃ ធ្វើទឹកមុខស្រងូតគ្រប់ៗ

គ្នា ។ ពាក្យដែលឮធ្លាយ ពីមាត់មួយទៅមាត់មួយ ជាបន្តបន្ទាប់គ្នា "ស្រុកកើតសង្គ្រាម" អ្នកធំស្លាប់. ស្រុកក្រ. អត់ឃ្លាន ។

---

(១) សូមមើលឈ្មោះនេះក្នុងរឿង "កំហែងរាជ្យ" របស់ឡាំង-ប៉េងសៀក

ពាក្យនេះនិយាយពីមាត់មួយទៅមាត់មួយ បង្កើតបរិយាកាសខ្លាចមួយដល់ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ។

គឺថ្ងៃនោះហើយដែលព្រះនរិន្ទវង្ស ចាប់ផ្ដើមបើកឆាកកក្កូរកកាយក្នុងផ្ទៃនយោបាយក្នុងនគរក្រុងទ្រាស ដែលនៅក្នុងវង្វង់នោះ ព្រះរាជបុត្រី ក៏ជាតួមួយសំខាន់ណាស់ដែរ ។ អ្នកផងដែលត្រចៀកទន់ ក៏កើតចិត្តជឿទៅថា ព្រោះតែព្រះនាងមានរូបឆោមល្អ ហើយព្រះនាងទ្រង់ចង់យកម្កុដរាជ្យវិញនោះហើយ ដែលបណ្ដាលឱ្យទេវតាខ្វាល់ រហូតឱ្យមានអម្ពូតហេតុឱ្យឃើញឱ្យជាក់ស្ដែងទៀតផង ។

តើព្រឹត្តិការណ៍ស្រុកទេស ប្រែប្រួលទៅយ៉ាងណា ? បញ្ហានេះធ្វើឱ្យយើងកើតចិត្តរំជួលយ៉ាងក្រៃលែង ...

# តៀវសខ្ជួន

**ភ្លើង**សង្គ្រាមឆេះឡើងនៅនគរក្រុងទ្រាស ...

ពេលប៉ះនោះវិសេសភក្តិ មានឯកសណ្ឋានជាមេទ័ព មានគ្រឿងអលង្ការដ៏អង់អាច ។ នៅដៃមានកាន់ដាវជ័យមួយធ្វើឱ្យយើងអ្នកមើលមានចិត្តស្ញប់ស្ញែងជាខ្លាំង ។ បុរសឯកជិះលើខ្នងអាជានេយ្យសម្បុរត្នោតកាន់ខែលពណ៌ក្រហមបត់សេះចុះឡើង ត្រួតមើលអស់ពលយោធាដែលតម្រង់ជួរតាមក្រុម តាមពួកណែនណាន់តាន់តាប់ ប្រដាប់ដោយគ្រឿងសស្ត្រាវុធ មានព្រួយ ធ្នូ ស្នា លំពែង ខែលដូចៗគ្នា ។ គេឮសូរតែមាត់មហាកាល អគ្គី រាហុល និងចន្ទា ដែលស្រែកបង្គកបញ្ជាឱ្យពលរេហ៍ សំរាក. ប្រុងរួចតឿនកូនទាហានឱ្យប្រញាប់. រួចពីនោះគឺស្នូងសេះដែលកញ្ជ្រៀវយ៉ាងអង់អាច ធ្វើឱ្យរាត្រីនេះមានសកម្មភាពគួរព្រឺក្បាលក្នុងវេលាស្រុកកើតអាសន្ន ។

កងទ័ពស្រួចដើរយ៉ាងក្លាហានទៅមុខឯណោះទៅហើយ ដែលគេមើលទៅឃើញតែចុងលំពែងច្រូងច្រាង ។ ក្រុមនេះគឺសុទ្ធតែអ្នកស្ម័គ្រចិត្តស្លាប់ ដែលមានមាឌមាំៗ មុខកាចៗ ។ កងឆ្មក់រៀបជាបីកង ដើរជារបៀបតាមបញ្ជាមេម្នាក់ ឥតមាននរណាមួយរហេតរហូតឆ្វេឆ្វាឡើយ ។ បន្ទាប់មកគឺក្រុមសេះ ដែលមានតុបតែងគ្រឿងគួរសំបើម មានលើកទង់ជ័យសង្គ្រាមយ៉ាងត្រដែតក៏ធ្វើដំណើរតិចៗ ទៅដែរ ។ កងពលពិសេសក៏ត្រៀម

ស្រេចតាមសណ្តាប់ធ្នាប់ ។

វិសេសភក្តិក្រឡេកទៅឃើញលោកឧកញ៉ាក្រឡាហោមវង្សា ដែលឈរមើលអ្នកនៅមុខទ្វារដោយមុខញញឹមដោយពេញចិត្តចំពោះសកម្មភាពរៀបទ័ពដ៏អង់អាចនេះ ។ នៅជិតនោះអ្នកឃើញនាង មាលា ស្រីព្រលឹងដែលភ្នែកបាញ់ជានិច្ចលើអ្នក ធ្វើឱ្យអ្នករំជួលចិត្តយ៉ាងក្រៃលែង ។ មើលចុះភ្នែកស្រី ដែលចាំងនឹងពន្លឺចន្លុះ ឃើញថាស្រីមិនចង់ឃ្លាតពីអ្នកសោះ ។ ឱ ! បើសិនជានាងដឹងរឿងសម្ងាត់ក្នុងទ្រូងអ្នកនោះវិញ តើនាងកើតទុក្ខយ៉ាងណា ?

វិសេសភក្តិមើលមុខនាងទាំងក្តីស្រណោះស្រណោក ... "បងទៅនេះ មិនដឹងចារស់ ឬស្លាប់ទេ. គឺទាស់តែខ្មាំងក្នុងស្រុកខ្ចាត់. ខ្មាំងខ្ចាយ ទើបបងមានពេលមកនឹងអូនវិញ ។ ឃើញថាពេលបងបែកអូនទោនេះ ប្រហែលជាបែករហូតក៏ពុំដឹង ... ។ មើលចុះស្រីឥតដឹងរឿងទេ ធ្វើឱ្យបុរសឯករំជួលចិត្តកាន់តែខ្លាំងឡើង ។ វិសេសភក្តិទាញបង្ហៀរសេះទៅជិតធីតាវលក្ខណ៍ ភ្នែកនាង់ឡើងក្រហម វិសេសភក្តិនិយាយថា ÷

— បងសុំឱ្យអូនមានស្មារតីឱ្យរឹងប៉ឹងជានិច្ច ដំបូងបង្អស់ត្រូវអូនគិតទុកជានិច្ចថា ជីវិតមានការប្រែប្រួលរាល់ពេល រាល់នាទី ហើយជីវិតក៏ត្រូវការតយុទ្ធជានិច្ច. បើជីវិតគ្មានការតយុទ្ធទេ គឺជីវិតនោះនៅតែគ្មានន័យរហូត ។ យើងជាអ្នកទទួលខុសត្រូវ ដូច្នេះបន្ទុកការងារធ្លាក់មកលើយើងគឺពេលនេះហើយដែលចំណោទមនុស្សវិលទៅវិលមក ចំពោះតែមុខការងារ ...

មាលាកល្យាណមើលមុខបុរសសង្ឃារតតដាក់ភ្នែក ។ សំលេងប្រុសពួតទៅទៀតថា ÷

— ... ពេលនេះខ្លីពេក បងនិយាយនឹងអូនបានតែប៉ុណ្ណោះទេ. ឥឡូវអូនមានពាក្យអ្វីនិយាយនឹងបង និយាយមកចុះ បងស្តាប់

ភក្ត្រាឡើងក្រហម. នាងខំទប់ចិត្ត ហើយនិយាយទៅថា ÷

— ជាតិត្រូវការបងហើយ ។ ក្នុងកិច្ចការដើម្បីជាតិ ដើម្បីប្រជាជនដើម្បីខ្មែរនេះ ប្អូនសូមជូនពរឱ្យបងបានជោគជ័យគ្រប់ប្រការ ។ ធ្វើជាអ្នកដឹកនាំគេមានផលពីរយ៉ាង គឺល្អនឹងអាក្រក់ ។ សេចក្តីល្អរបស់យើងរាប់ម៉ឺនរាប់សែន ត្រូវគេចាត់ទុកជាធម្មតា ហើយការអាក្រក់របស់យើងតែ បន្តិចអាចនាំគេរាប់ម៉ឺនរាប់សែនធ្លាក់រណ្តៅទុក្ខវេទនា តែអូនជឿជាក់បងជាកំពូលមនុស្ស ជាមេដឹកនាំគេទៅហើយ បងប្រាកដជាពុំអាចឈានទៅតាមផ្លូវខុសនោះទេ ។

នេត្រាស្ទើរបែកដោយស្រឡាញ់សំដីសង្ឃារសម្លាញ់ចិត្ត ។ វិសេសភក្តិខាំធ្មេញសម្លាប់តណ្ហាកាត់ចិត្ត. ហើយទាញបង្ហៀរសេះគេចផាំងទៅកាន់កងទ័ព ។

ពលរេហ៍បោះជើងព្រិប១ ដំណាល១ គ្នា ក្រោមក្រសែភ្នែកអស់នាម៉ឺនចាស់ទុំ និងនាងមាលាដែលនៅមើលពិធីនេះ លុះត្រាតែក្បួនទ័ពទៅបាត់ឆ្ងាយ ...

នៅសមរភូមិ ...

សង្គ្រាមបើកឆាក បញ្ចេញវេទនារម្មណ៍ដ៏ខ្លោចផ្សារ ដល់ភ្នែកមនុស្សគ្រប់គ្នា ។ កងពលដែលព្រះចៅក្រុងអយុធ្យា ចាត់ឱ្យមកតតាំងបាននៅត្រៀមមិរដេរដាសខ្ចាប់ គួរឱ្យរំភើប ។ កងទ័ពនេះមានសម្លៀកបំពាក់ពណ៌លឿង ក្រហម ស ចម្រុះគ្នា មានដាវនិងខែលគួរឱ្យសំបើម ។ ទង់ជ័យប្រចាំកងបក់ត្រដែតក្នុងអាកាស ... ហើយទ័ពនេះ បោះជំហានចូលមួយៗទល់មុខទ័ពយើង ចម្ងាយពីគ្នាប្រហែលមួយរយម៉ែត្រ ។ វិសេសភក្តីជិះសេះខាងមុខដឹកទ័ពយើង. ឯខាងខ្មាំងគឺពញាតាកគ្រងឥស្សរិយយស យ៉ាងរុងរឿង ។ វិសេសភក្តីបំបោលសេះទៅខាងមុខហើយស្រែកថា ÷

— នែលោកមេទ័ព. យើងបានប្ដេជ្ញាថា នឹងកំទេចទ័ពចោរឈ្លានពាននេះឱ្យទាល់តែរលាយជាផេះ បើមេទ័ពក្រុមអយុធ្យាមិនព្រមថយចេញពីដីនគរទ្រាសពេលនេះ

ឥស្សរជនជាមេទ័ពក្រុងអយុធ្យាឆ្លើយថា ÷

— ខ្ញុំពញាតាក សុំប្រកាសសង្គ្រាមជាមួយទ័ពវិសេសភក្តីដែលធ្វើរដ្ឋប្រហារដណ្ដើមរាជ្យព្រះនរិន្ទវង្ស ស្ដេចផែនដីពេញលក្ខណៈ ។ បញ្ហានេះជាបញ្ហាអាជ្ញាសិក ដែលព្រះករុណាក្រុងអយុធ្យាចាត់មក ...

— ការនោះគ្មានអ្វីទាក់ទងដល់ព្រះចៅក្រុងអយុធ្យាទេ

សំដីមេទាំងសងខាងនេះ សូវណែនដូចគេទូងស្គរក្នុងបន្ទប់ដែលបិទទ្វារជិត តែមុតដូចដាវ ...

— ... ឥឡូវកុំនិយាយច្រើន យើងគោងចាត់ការតាមតម្រេះ

រៀងខ្លួន. តែយើងសូមបញ្ជាក់ប្រាប់ថាបើទ័ពនគរទ្រាសយើងចាញ់ យើងសុខចិត្តស្លាប់. តែបើឈ្នះគឺក្រុងអយុធ្យាត្រូវរលាយ ជាផេះ ...

ពញាតាកមេទ័ពព្រះចៅក្រុងសៀម លើកដាវជ័យពណ៌មាសគ្រវីទៅលើឆាល់ ស្រែកផុតសម្លេងថា ÷

— ចូល ! ... ចូល ...

កងពលរត់ចូលឥតបង្អង់ឡើយ ។ ពលសេះដោយពលសេះ ពលថ្មើរជើង ដោយពលថ្មើរជើង. ប្រញ៉ីស៊ីសាច់ហុតឈាមគ្នា ប្រកាប់ប្រចាក់ច្រឡំបល់វីវក់ ។ ទង់ជ័យប្រចាំកងនៅតែបក់ត្រដែតឥតឈប់ឈរ ហើយលើកកាន់បន្តគ្នា កាលបើអ្នកកាន់មុនត្រូវធ្លាយពោះ ឬ ត្រូវដាច់ក ។ ជនអ្នកស្លាប់ក៏ស្លាប់ទៅ ឯអ្នករស់គិតតែពីរកស្មៀតសម្លាប់គ្នា ដោយយូរៗ ឮសូរស្រែកយកជ័យលាន់ឮកងរំពង ។

សង្គ្រាម ! សង្គ្រាម ! ធ្វើឱ្យចិត្តមនុស្សឡើងសាហាវរួចជីវិតក្នុងសង្គ្រាម គឺផុយដូចសសៃអម្បោះ ។ ជីវិតក្នុងសង្គ្រាមគឺមិនអាចគូសបញ្ជាក់ឱ្យច្បាស់បានឡើយ ។ ... យើងជាមនុស្សដែលមានបញ្ញាខ្ពង់ខ្ពស់ជាងសត្វ យើងសូមអំពាវនាវដល់សន្តានចិត្តមនុស្សឱ្យរំលត់សង្គ្រាម. ដើម្បីសន្តិភាព ។

មួយថ្ងៃកន្លងទៅ. មួយអាទិត្យកន្លងផុត. សង្គ្រាមនៅតែឆេះ ...

លើសមរភូមិនាព្រំដែនខាងជើងនៃនគរទ្រាស ពោរពេញទៅដោយសាកសពមនុស្ស ដែលខ្លះរលួយរលះខ្លះហើម ខ្លះទើបស្លាប់ថ្មីៗ នៅគរគ្នាពាសពេញស្ទុយក្រៃលែង ... ហួសនិស្ស័យនឹងពណ៌នា ។

យោធាទាំងសងខាងដែលនៅរស់ ក៏ទន់ដៃទន់ជើងរវើយសព្វប្រាណ យារដាវកាប់ឃីត១ រួចជ្រុលតតាក់តតើតដោយអស់កម្លាំង ។

ចូលសប្តាហ៍ទី៣ ...

គេបានដឹងថាខ្មាំងស្លាប់ជាច្រើនអនេក ។ កងទ័ពនគរក្រុងទ្រាស យើងក៏ចេះតែមានកម្លាំង សន្ទុះទឹកចិត្ត ។ ដូច្នេះនៅក្នុងសប្តាហ៍ទីបីនេះខ្មាំងលែងហ៊ានវាយចេញមុខទៀតហើយ គឺវានៅបន្លំតាមភូមិ តាមទីប្រជុំជនបង្ករកលយុគបន្តិចបន្តួចប៉ុណ្ណោះ ដែលពួកយើងបានប្ដេជ្ញាចិត្តថានឹងវាយកំចាត់ឱ្យអស់កុំឱ្យសល់ម្នាក់ ។

ថ្ងៃនេះវេលារសៀល ...

ជនចម្លែកបីនាក់បំបោលសេះតម្រង់ទៅជិតវិសេសភក្តី ដែលវិសេសភក្តីភ្ញាក់ហើយភ្លាត់មាត់ថា ÷

— ខ្ញុំខំតែភ្ញាក់. ដឹងអីថាបងទាំងបីសោះ ។ ដល់ ពេលហើយ ទៅយើង !

គឺមហាកាល. រាហុល និងចន្ទា ដែលក្លែងខ្លួនជាអ្នកស្រុកដើម្បីភៀសខ្លួន ដូចយើងបានដឹងក្នុងវគ្គមុន ។ វិសេសភក្តីនាំសិស្សទាំងបីទៅក្រោមដើមឈើមួយ ។ អ្នកចុះពីខ្នងសេះ ស្រាតខោស្រាតអាវ រួចទាញឯកសណ្ឋានអ្នកស្រុកមកពាក់ ... ។ បុរសយកឯកសណ្ឋានមេទ័ពទៅបំពាក់លើខ្មោចទាហានម្នាក់ ហើយគាត់ក្បាលខ្មោចនោះ ។ អ្នកជិកដីកប់ក្បាលខ្មោច រួចគេចទៅទីកំបាំង ...

ទៅយើង ! ស្រេចបាច់អស់ហើយ ។ គេទាំងអស់មុខតែស្មានថា សត្រូវសម្លាប់ខ្ញុំ ដោយកាត់ក្បាលយកទៅរូចខ្ញុំក្លាយជាមនុស្សម្នាក់ដែគ្មាន បុណ្យគ្មានសក្តិ ប្រាសចាកចំណងកម្មក្រាស់ ... ទៅយើង ! ទៅតាម ជំនោរដែលបក់មកនោះ ...

សិស្សទាំងបីដែលរំភើបនឹងកាយវិការវិសេសភក្តីជាគ្រូ ពន់ពេកទៅ ទៅជាស្រឡាំងកាំងនៅស្ងៀមឥតស្រដី ។ គេស្ទើរតែទៅលើកទូលបុរសដ៏ ឧត្តុង្គឧត្តមនេះ តែកាយវិការវិសេសភក្តីឥតអើពើអ្វីបន្តិចណាឡើយ ។

ជនទាំងបួនដឹកដៃគ្នារត់តាមផ្លូវកាត់ព្រៃធំតូចឆ្លងអូរឡើងភ្នំ ចុះភ្នំ ... ដើរៗ ទៅឥតត្រើយ ឥតកោះ ឥតទីដៅ ។ គោលបំណងពិតៗ របស់ វិសេសភក្តីនេះ គឺធ្វើដំណើរទៅពង្រីកមនុស្ស បន្ទំមនុស្ស ដឹកនាំមនុស្សឱ្យទៅ កាន់ក្តីចំរើន ពង្រឹងជាតិខ្មែរឱ្យមាំមួនឡើងនៅចំពោះមុខគ្រោះមហន្តរាយ ។ ចិត្តគេត្រូវតែដឹករំលើងជំងឺសង្គមចាស់ ដែលមកខ្ទាស់ដំណើរសង្គមថ្មីនេះ ឱ្យ រលើងរលត់បាត់ទៅ ...

មួយអាទិត្យក្រោយមក

សង្គ្រាមឈ្លានពានទឹកដីដែលខ្មាំងបរទេស បង្កបង្កើតនៅលើទឹកដី នគរក្រុងទ្រាសបានអន់អានុភាព ... គេត្រទះតែការលបវាយឆ្មក់នៅ ដំបន់នេះ ដំបន់នោះនៅភូមិភាគដាច់ស្រយាល ។ ក្រុមស្តេចនិងនាម៉ឺនវាំង មួយចំនួន ដែលគេអាចរាប់អស់នឹងម្រាមដៃ ហើយដែលនៅជាប់ទ្រុងឯ ស្យាមប្រទេស កំពុងរិះរកល្បិចផ្សេងៗ ទៀតដើម្បីបន្តសង្គ្រាម ។

ខ្មែរភាគច្រើនដែលជឿតែលើអានុភាពខ្មែរ ជឿទៅលើតែកម្លាំង

ប្រជាជន កម្លាំងរាស្ត្រនោះ បានគួចគិតហើយនិយាយពីមាត់មួយទៅមាត់មួយថា ខ្មែរប្រាកដជាឈ្នះ ... ការចង់វិលត្រឡប់មកអង្គុយលើបល្លង្គរាជ្យរបស់ក្រុមគ្រួសារព្រះហរិវង្សវិញនោះ គឺជាការយល់សប្តិស្មោះទៅហើយ ។

... តែនៅពីមុខសេចក្តីសង្ឃឹមនេះ. សេចក្តីទុក្ខមួយយ៉ាងធំ សង្កត់លើសន្តានចិត្តប្រជាជន ។ គឺដំណឹងមរណភាពនៃពញាវិសេសភក្តីមេទ័ពឯកនៃក្រុងនគរទ្រាស ។

ដំណឹងដ៏រន្ធត់នេះ ជ្រួតជ្រាបពីខ្មែរម្នាក់ទៅខ្មែរម្នាក់ចាប់តាំងពីទីក្រុងរហូតដល់ស្រុកស្រែនិគមក្រមថ្មទៀតផង ។ ខ្មែរខ្លះដែលធ្លាប់ស្គាល់វិសេសភក្តីច្បាស់ ក៏មានទឹកមុខស្រពោន បែរទៅគៀនជញ្ជាំងជូតទឹកភ្នែក ។ អ្នកខ្លះទៀតពោលដោយសម្លេងនៅចុងច្រមុះថា "ខ្មែរចប់ត្រឹមនេះឯង" ។

គេបានយកសាកសព ដែលនៅតែដងខ្លួនហើយដែលគេស្មានថាជាសាកសពវិសេសភក្តីនោះមកធ្វើបុណ្យប្រាំពីរយប់ប្រាំពីរថ្ងៃ ... ព្រមជាមួយនោះគឺពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធអស់ពលយោធា ដែលស្លាប់ក្នុងសង្គ្រាម ឬឈ្លើយសង្គ្រាម ដែលខ្មាំងចាប់យកទៅ ។ ក្នុងចំណោមនាយពលដែលបាត់ខ្លួន ហើយរកសាកសពពុំឃើញនោះ គេបានរំលឹកដល់ឈ្មោះមហាកាល. រាហុល. និងចន្ទាផងដែរ ។

យើងមិនបាច់និយាយពីក្តីទុក្ខនៃស្រីមាលានោះទេ ។ សង្សារដែលស្គាល់ចិត្តគ្នា ហើយបែកទៅវិញ តើទុក្ខនោះដល់កម្រិតណា ? កែវជាស្រី រថាំដើម្បីសងឈាមសង្សា នាងក៏ចាប់ផ្តើមចូលក្នុងប្រវត្តិតស៊ូ ដោយសូមឱ្យ

នាងសោភ័ណទេវី និងកំហែងពេជ្របង្រៀនទនាងពិរិដ្ឋាចម្បាំង ... ។ ស្រីខំខាត់ចិត្ត ឱ្យជក់ចូលតែក្នុងគន្លងស្នេហាជាតិ តាមគោលគំនិតវិសេសភក្តី ។

ស្រីខ្មែរម្នាក់ចាប់ចូលក្នុងសារតាបដិវត្តន៍បន្ថែមកម្លាំង លើការតស៊ូនេះទៀត ជាគំរូដល់ស្រីខ្មែរគ្រប់សម័យធ្វើឱ្យខ្សែរឿងយើងនេះរឹងរិតតែមានភេទការណ៍ចម្លែក១ រណ្តំគ្នាយ៉ាងជាប់ចិត្តទៅទៀត ... ដូចតទៅ ...

# ឃាតកម្មអនាមិក

**ស្ថាន**ការណ៍សឹកនៅក្រុងនគរទ្រាស ឃើញថាបានធូរស្រាលណាស់ទៅហើយ ... គេប្រទះហេតុចលាចលបន្តិចបន្តួចតាមទីជនបទឆ្ងាយៗ ...

រដ្ឋាភិបាលមួយត្រូវចាត់តាំងឡើង ដើម្បីរៀបចំនយោបាយជាតិឱ្យមានស្ថេរភាពនឹងន់ ឱ្យស្របតាមឆន្ទះរាស្ត្រសុទ្ធសាធដែលជាម្ចាស់អំណាចនិងជាម្ចាស់នៃជ័យជំនះនេះ ។

តែ ... តែ ... បរិយាកាសនយោបាយនៅតែតឹងតែង ឬតឹងតែងលើសមុនទៅទៀត ព្រោះទុក្ខវេទនារបស់រាស្ត្រ វិបត្តិរបស់សង្គម ដែលមានជាដុំ ជាកំភូនពីកាលមុននោះ ឥតត្រូវនរណានឹកនាយកមកដោះស្រាយសោះ ។ ទាំងនេះ ក៏ព្រោះតែគេអាចដឹងបានថា ក្នុងចំណោមអ្នកកាន់ការរដ្ឋគឺមានភាគខ្លះជាមនុស្សរបស់ព្រះហរិវង្ស ខ្លះទៀតកាលដើមជាមនុស្សដែលស្អប់ខ្ពើមអំណាចផ្ដាច់ការដែរ តែរកចោលសម្បត្តិទ្រព្យធនធានពុំរួចក៏លង់ទ្រនេសក្នុងក្ដីលោភលន់នោះទៅ ។ ខ្លះទៀតជាអ្នកនយោបាយក្លែងក្លាយជាជនដែលផ្លូវវាសនាទៅតាមកាលៈទេសៈ ពោលអ្នកនយោបាយដែលវេដូចចុងស្រល់ ។

គេអាចសង្កេតឃើញម្យ៉ាងទៀតនៅក្នុងសង្គមខ្មែរ នាសម័យនោះមនុស្សទាំងឡាយផ្លាស់ប្ដូរជីវភាពបានយ៉ាងឆាប់រហ័ស. គឺជនដែលធ្លាប់មាន

ទៅជាក្រ. ជនអាវ៉ាសែត្រឡប់ទៅជាសេដ្ឋី គួរឱ្យស្ដែងទៅវិញ ។ គឺមនុស្សជាន់កមនុស្សដើម្បីរស់នៅលើគំនរខ្ទុះ. លើសមុទ្រឈាមមនុស្សផងគ្នា ។

លោកអើយ ! បើនាម៉ឺនពុករលួយយ៉ាងនេះ តើសង្គមខ្មែរថ្មីឈានទៅកាន់ក្ដីចំរើននោះបានទេ ?

រឿងនេះ បណ្ដាលឱ្យលោកក្រឡាហោមវង្សានឹងអ្នកទទួលការខុសត្រូវក្នុងនគរក្រុងទ្រាស មានក្ដីព្រួយបារម្ភឥតគណនា ។

ថ្ងៃនោះ ... ឱថ្ងៃនោះ គួរឱ្យអស្ចារ្យណាស់ ...

នៅពេលព្រលឹមព្រាង១ កំហែងពេជ្យដែលត្រូវគេតែងតាំងជាទីប្រឹក្សារដ្ឋប្រចាំក្រុងនគរទ្រាសនោះ. រត់ត្រហេបត្រហប មកជួបនឹងលោកក្រឡាហោមវង្សាដែលទើបភ្ញាក់ពីដំណេក ។ លោកតាក្រឡាហោមវង្សាដែលទើបភ្ញាក់ពីដំណេក ។ លោកតាក្រឡាហោមស្រឡាំងកាំង ...

— យី ! មានហេតុចម្លែកអីហាស ពេជ្រ ? អីក៏ស្លន់ស្លោខ្លាំងម្ល៉េះ ?

ប្របាទ ...! មានសំបុត្រមនាមឹកមួយ ...

— សំបុត្រអនាមឹក ?

— ប្របាទទាន ! ខ្ញុំភ្ញាក់ពីដំណេកទៅឃើញសំបុត្រនេះរុំជាមួយកូនកាំបិត ដែលដោតជាប់ឆ្អឹងនៅលើតុ

— មើល ! ... សំបុត្រនោះមានន័យយ៉ាងណា ...

លោកតាក្រឡាហោម ឆក់ក្រដាសពីដៃកំហែងពេជ្រហើយលាមើល ...

ភាគច្រើនជាមនុស្សមានពុតត្បុតអាក្រក់. ក្រឡេមក្រឡឹម. មនុស្សមិនបានការ. មនុស្សខ្ជិល. មនុស្សជិះជាន់មនុស្ស ។ អាចបង្កើតឱ្យមានការវឹកវរមួយទៀត បើដំណឹងនេះលេចឮជ្រួតជ្រាបទៅ ។ ពេជ្រ ! ពេជ្រឯងជួយគិតខ្ញុំមើល តើយើងត្រូវធ្វើអ្វីទៀត ?

កំហែងពេជ្រ សញ្ជឹងគិតមួយស្របក់ ហើយជូនយោបល់ថា ÷

— ... ត្រូវផ្សាយសេចក្ដីសំបុត្រអនាមិកនេះជាសាធារណៈ ឱ្យនាម៉ឺនអស់មុខមន្ត្រីពុករលួយទាំងឡាយកែប្រែគំនិតឡើង. បើសង្កេតឃើញថាអ្នកខ្លះពុំព្រមប្រែចិត្តគំនិតទេ យើងត្រូវតែហ៊ានអារ ក ... ចំពោះមុខសាធារណជន ...

លោកក្រឡាហោមទីតើបន្តិច

— ធ្វើយ៉ាងនេះ ...

— តាមយោបល់ខ្ញុំ. ធ្វើយ៉ាងនេះ គឺត្រឹមត្រូវណាស់ទានប្រោស ព្រោះបើយើងប្រណីឱ្យជនក្បត់ជាតិ គឺយើងសម្លាប់ជាតិ ។ យើងត្រូវតែហ៊ានសមាប់ខ្មែរខ្ញុំគេម្នាក់ពីរជាជាងឱ្យខ្មែរទូរទាំងប្រទេសស្លាប់ ។

លោកក្រឡាហោមងក់កេសាឃឹត១ តែសំដីដែលចេញមកប្លែក ពីអាកប្បកិរិយានោះទៅវិញ ។

— ... តើសាមគ្គីក្នុងសង្គមជាតិត្រូវប្រេះឆាឬទេ ? រឿងនេះតោងគិតឱ្យម៉ត់ចត់បន្តិចពេជ្យ ។

កំហែងពេជ្រដកដង្ហើមធំ ពន្យល់ថា ÷

— សាមគ្គីក្នុងសង្គមជាតិត្រូវប្រេះឆា ? ... លោកគ្រូនេះគឺជា

សំដីមន្ត្រីពុករលួយមួយក្រុមតូចដែលកែមិនឡើង ។ តោងជ្រាបថាភាស្ត្រមួយនគរកំពុងមើលបំណាំយើង តើយើងហ៊ានវះ ! កាត់ជម្ងឺខ្មែរដែលមានរាប់សតវត្សមកហើយនោះបានទេ ? បើនៅតែស្ទាក់ស្ទើរទៀត ជាតិខ្មែរមុខជាត្រូវរលត់ហើយ ។ ... ខ្មែរសព្វថ្ងៃគ្រាន់តែរលួយ តែមិនទាន់រលាយ. យើងត្រូវខំខាត់រំលោងជាតិខ្មែរ ឱ្យរលើបឡើងវិញ[១] ។

— អឺ ! អឺ ! ពេជឯងថានោះត្រូវ ...

ពេលនោះនាងមាលាគ្រងឯកសណ្ឋានគ្រឿងចម្បាំងដើរចូលមក. ដែលលោកក្រឡាហោមអញ្ជើញថា ÷

— អញ្ជើញនាង ! អញ្ជើញអង្គុយជិតមានេះមក. ក្នុងរយៈពេលមួយខែនេះ មាឃើញក្មួយប្រែបប្លែកសំបើមណាស់ ... ។ អាំ ! ក្មួយស្រីមានការសំខាន់ហើយមើលទៅបានជាមកជួបមានទាំងព្រលឹម យ៉ាងនេះ...

កញ្ញាដើរមួយៗ ទៅក្បែន ...

— ... ខ្ញុំចង់ស៊ីសាច់ ហុតឈាមមនុស្ស ...

កំហែងពេជ្រស្ទើរតែលោត. លោកក្រឡាហោមស្រឡាំងកាំងបើកភ្នែកធំៗ ។ កញ្ញាបន្តថា ÷

— តែខ្ញុំប្រទះ ឃើញគំនិតខ្មែរខ្លះល្អ ហើយដែលនាំឱ្យនាងខ្ញុំចាប់ភ្លឹកពន់ពេក

---

[១] ជប់ឆ្នាំមុនកំហែងពេជ្រនិយាយពាក្យនេះម្តង ជាមួយក្រុមទ័ពពញាគីរីនៅក្នុង រឿង "ទោសពានវាំង" របស់លោក ឡាំង-ប៉េងសៀក

លោកក្រឡាហោមជ្រួញថ្ងាសវិញម្តង

— ឱ ! ទេវតាអើយ ! មើលគំនិតខ្មែរយ៉ាងណាខ្លះ ? សូមក្មួយមានប្រសាសន៍មកមើល ។ អាំ ! មាចាស់ហើយពុំសូវបានទៅណោមកណោឱ្យក្បៀកកិតនឹងខ្មែរ នឹងរាស្ត្រនឹងប្រជាជន. មាធ្លាប់តែឮគេនិយាយខ្លះថាអីចេះ ខ្លះថាអីចុះរកជឿនរណាក៏ពុំទាន់បាន ។ ហ៎ ! មាចង់ដឹងពីហេតុភេទខ្មែរ ដែលក្មួយប្រទះក្នុងនាបច្ចុប្បន្ននេះ ។

— មានខ្មែរខ្លះចិត្តជាកូនខ្មែរពិត១ មានចិត្តក្លាហានដ៏ប្រពៃ ...

— អូ ! អូ ! នៅក្រុងទ្រាសនេះ មានខ្មែរជាខ្មែរពិត១ បែបនេះមែនឬ ?

— ជំរាបប្រសាសន៍មាន ! មានច្រើនពេក ! មានក្រៃលែងទាល់តែរឿងនេះក្លាយជាអាក្រក់ទៅវិញ ។

លោកក្រឡាហោមធ្វើភ្នែកឡឹងឡង់

— អុះ ! អុះ ! ក្មួយចង់និយាយយ៉ាងណានោះ ?

— នាងខ្ញុំសង្កេតឃើញថានៅក្នុងនគរទ្រាសយើងនេះ មានតែខ្មែរដែលភ្លេចខ្លួនថាជាខ្មែរ. ដែលចូលចិត្តមើលងាយតែខ្មែរគ្នាឯង រួចរួញខ្លួនដូចពង្រួលក្នុងរូងនៅពីមុខខ្លាំងពិត១ ។ គឺខ្មែរជំពូកខ្លះ ដែលស្រឡាញ់តែវប្បធម៌គេ. ភាសាគេ. អរិយធម៌គេ ... ។ល។

កំហែងពេជ្រងក់ក្បាលមួយ១ ...

— មែន ! មែន ! ដូចនាងថាមែន ខ្មែរយើងនៅជាប់ក្អែលខ្ញុំតែមែន ។ អីនាង ... សំបុត្រនេះជាតំណាងជនដែលមានឧត្តមគតិដូចនាង

... យើងគោងចាប់អនុវត្តិផែនការណ៍ការពារជាតិខ្មែរ ជាថ្មីចាប់ពីពេលនេះទៅ ...

កំហែងពេជ្រហុចកូនសំបុត្រនោះទៅនាង មាលា នាងមាលា អានហើយ ពេញចិត្តយ៉ាងក្រៃលែង ។ នាងស្ម័គ្រចិត្តចូលរួមក្នុងបេសកកម្ម នេះដែរ ទោះមិនដឹងថាជនម្ចាស់លិខិតអនាមឹកនោះជានរណាក៏ដោយ ។

ពីរថ្ងៃក្រោយមក. សេចក្តីដែលមានក្នុងលិខិតអនាមឹកនោះ ត្រូវគេប្រកាសឡើងជាសាកលធ្វើឱ្យបណ្តាជនរីករាយជាខ្លាំង ហើយបន់ឱ្យតែក្រុមសម្ងាត់ចាប់ធ្វើការនេះ ឡើងដើម្បីស្ជួយប្រទេសជាតិក្នុងពេលមានអាសន្ន ។

នាម៉ឺនមួយភាគដែលមានល្បិចដ៏អស្ចារ្យ ក្នុងការជញ្ជក់ឈាមរាស្ត្រនោះ ហាក់ពុំមានព្រឺរជួលអ្វីបន្តិចណាសោះឡើយ. ព្រោះគេនឹកថាការធ្វើនេះគ្រាន់តែលើកស្ទា បង្ហើរក្អែកប៉ណ្ណោះទេ ហើយហេតុភេទបែបនេះ ធ្លាប់មានច្រើនដងណាស់មកហើយ តែគ្មានបានផលអ្វីសោះ ...

ថ្ងៃប្រាំកើតខែអាសាធ ...

ហេតុការណ៍មួយដ៏សាហាវ កើតមានជាដំបូងនៅកណ្តាលក្រុងនគរទ្រាស ... គឺលោកឧកញ៉ាវិជិតសូគិា មេទ័ពត្រួត ដែនខាងជើងនៃនគរក្រុងទ្រាស បានត្រូវឃាតករអនាមឹកសម្លាប់នៅក្នុងដំណេក ដោយកាត់ក្បាលដាច់ពី ក ។

នេះជាឃាតកម្មដ៏រំភើបនឹងសាហាវ ដែលធ្វើឱ្យរន្ធត់ញាប់ញ័រជាខ្លាំង ។ នៅជងកាំបិតមានធ្លាក់ជារូបខ្លាញ្ចេញធ្មេញ. ហើយនៅជាប់នឹងជងនោះ គឺក្រដាសមួយរមូរ ដែលចារសេចក្តីថា ÷

ជនដែលស្លាប់នេះ ធ្លាប់ឈ្លបដឹកនាំភោគផលខ្មែរទៅលក់ឱ្យខ្មាំងបរទេស ដើម្បីចំណេញធ្វើមានតែម្នាក់ឯង គឺជាជនក្បត់ជាតិពេញទិ ។ ជននេះជាមនុស្សរបស់ព្រះហរិវង្ស ជាប្អូនរបស់អតីតមហាឧបរាជក្រុងនគរទ្រាស. ជាជនបដិវត្តន៍ក្លែងក្លាយ ។

មរណភាពនេះ ទុកជាគំរូដល់ជនពុករលួយឯទៀតៗ ភាគច្រើន ...

ហត្ថលេខា **មនុស្សសម្ងាត់**

ចំពោះសេចក្តីប្រកាសរបស់ឃាតករសម្ងាត់នេះ មតិពីរផ្ទុយគ្នាកើតឡើងក្នុងហ្វូងមហាជនក្រុងនគរទ្រាស ។

អ្នកច្បាប់មួយពួកនោះបានយល់ថា ការធ្វើឃាតកម្ម ដោយអាថ៌កំបាំងមកលើមន្ត្រីជាន់ខ្ពស់នោះ ហាក់ដូចជាអានាធិបតេយ្យពេកហើយ ព្រោះទោះជាយ៉ាងណា ក៏គោងទុកឱ្យតុលាការរកហេតុផលឱ្យបានស្រួលបួលសិនដែរ ។ មនុស្សមួយជំពូកផ្សេងទៀត បានសំដែងសេចក្តីពេញចិត្តហើយនិយាយថា ការធ្វើដូច្នេះ ហៅពេលជាត្រូវតាមកាលៈទេសៈ ព្រោះស្រុកទេសទើបតែប្រែរបបគ្រប់គ្រង នាម៉ឺនត្រូវតែប្រែគំនិតខ្ញុំគេ ... ហើយមុនធ្វើដូច្នេះ ក្រុមឃាតករសម្ងាត់ក៏បានប្រកាសមុនកន្លះខែដែរហើយ ។ ណាមួយទៀតអ្នកផងក៏បានដឹងច្បាស់ថា ឧកញ៉ាវិជិតសួគ៌ាជាម៉ឺនវាំងដ៏ចាស់ទុំមួយ បានបុណ្យបានសក្តិដោយសារតែវាំងបុទាន ហើយរហូតមកទល់ពេល

នេះ លោកឧកញ៉ាវិជិតសូគ៌ា បានប្រព្រឹត្តអំពើពុករលួយបង្ហិនជាតិច្រើនបែបច្រើនយ៉ាងណាស់ ។

បីថ្ងៃកន្លងមក លិខិតសម្ងាត់មួយទៀត ដែលមានចុះហត្ថលេខាឃាតករសម្ងាត់ដដែល បានព្រមានលោកឧត្តមមន្ត្រីបុរាណរាជហ៊ឹង ឱ្យប្រមូលទ្រព្យធនដែលប្លន់ជាតិបានទាំងប៉ុន្មាន ទៅដាក់ឃ្លាំងប្រើការ ជាប្រយោជន៍រាស្ត្រវិញជាប្រញាប់ បើពុំនោះសោតទេហេតុការណ៍អាក្រក់មុខជាកើតឡើងក្នុងគ្រួសារលោកមិនខាន ។

ធ្លាប់ជាវរជនអង់អាច តាំងពីរាជ្យមុនមក មិនដែលមាននរណាមើលងាយលោកដល់ថ្នាក់ហ្នឹងសោះ ... ។ ខឹងណាស់ ! លោកឧត្តមមន្ត្រីសុំពលទាហានប្រាំរយនាក់មកយាមផ្ទះក្នុងរាត្រីនោះ ។

គេហស្ថានលោកឧត្តមមន្ត្រី ស្ថិតនៅចំហៀងខាងត្បូងវាំងចាស់នៃនគរក្រុងទ្រាស ដែលក្នុងវេលាយប់ដូច្នេះ គេមើលឃើញស្កុង១ ខ្ពស់ចាក់អាកាស ។

រាត្រីក៏ងងឹត គ្រឹះស្ថាននេះបតិស្ឋឡើងហាក់បីដូចជាភ្នំមួយ ... គួរឱ្យអស្ចារ្យណាស់ ។ វិមានខ្ពស់ឡើងដោយសារតែញើសឈាមខ្មែរ. ហើយរិតតែខ្ពស់ណាស់ទៅទៀតក្នុងវេលាស្រុកទេសកើតកលិយុគ ដោយម្ចាស់វិមានជាមនុស្សសន្សំទ្រព្យ នៅតាមមាត់ទ្វារនីមួយ១ ទាហានដប់នាក់ យាមប្រចាំការឥតធ្វេសប្រហែស ហើយលើកំពែង លើដើមឈើ លើដំបូលវិមាន ...

តែនៅខាងក្នុង គេឮសូរតែសម្លេងស្រីច្រៀង សម្លេងសើច នឹងស្គរចានស្លាបព្រាដែលទង្គិចគ្នា ធ្វើឱ្យយើងដឹងថា គេកំពុងស៊ីផឹកយ៉ាង

សប្បាយ ។ ... អ្នកផងតែងឆ្ងល់ថា ក្នុងពេលដែលគ្រោះអាក្រក់ កំពុងគម្រាមកំហែងបែបនេះ ហេតុអ្វីក៏លោកឧត្តមមន្ត្រីទៅជារៀបចំពិធីជប់លៀងនោះទៅវិញ ?

ពេលវេលាចេះតែកន្លងផុតទៅ ...

មជ្ឈិមយាមនៃសន្និយាចូលមកដល់ ។ ការស៊ីផឹកដ៏ត្រូវបញ្ចប់ ហើយភ្ញៀវទាំងឡាយក៏អញ្ជើញត្រឡប់ទៅកាន់គេហស្ថានរៀងខ្លួន ។ មិនយូរប៉ុន្មាន ក្នុងអាណាខេត្តលំនៅស្ថានលោកឧត្តមមន្ត្រីនៅតែស្ងាត់ឈឹងឈរជ្រងប់ ក្នុងងងឹត ... ដែលយូរៗ គេឮសូរតែត្រដោកផ្លាស់យាម ។

លោកឧត្តមមន្ត្រីស្ថិតនៅក្នុងវ័យហាសិបប្លាយឆ្នាំហើយ. សក់ស្កូវ តែហាក់នៅមានកម្លាំងមាំមួនដូចក្មេងអាយុម្ភៃឆ្នាំ ។ ទឹកមុខលោក បង្ហាញនូវការព្រួយបារម្ភជាខ្លាំង ព្រោះជីវិតលោក. ភរិយាលោក នឹងកូនស្រីសម្លាញ់ចិត្ត កំពុងមានសត្រូវយាយី ។ លោកដើរមួយៗ ក្រឡឹងចុះឡើងតែក្នុងបន្ទប់នោះ . ហើយនៅខាងក្បែន គឺលោកជំទាវជាភរិយានិងបុត្រី អង្គុយយ៉ាងស្ងៀមស្ងាត់ឥតឮមាត់ ក អ្វីឡើយ ។ ទាហានម្ភៃនាក់នៅអមក្បែរៗលោកជាប់ជានិច្ច ... ។

ប្រាវ ! ...

ទាំងលោកឧត្តមមន្ត្រី ទាំងលោកជំទាវ. ទាំងបុត្រីទាំងអស់ពល សេនាដែលចាំយាម ភ្ញាក់ព្រើត ហើយកាំបិតស្ទៀតម្ភៃ បានហោះទៅជាប់ ឆ្កឹងៗនៅកន្លែងឱ្យសូរនោះជាស្រេច ... ។

លោកឧត្តមមន្ត្រីដែលលោះព្រលឹងអម្បាញមិញបានស្ទុះទៅ រួចសួរថា ÷

— ស្អី ? ស្អី ?

ឆ្មាមួយយំម៉ែវៗ ទាហានម្នាក់ជំរាបថា ÷

— សត្វឆ្មា លោតប៉ះថូផ្កា ធ្លាក់មកទេទានប្រោស ថូរផ្កានោះបែកខ្ទាយទៅហើយ

លោកឧត្តមមន្ត្រីបន្ធូរដង្ហើមធំមកវិញ

— ហ៊ឺះ ! អញស្មានថាវាមកហើយតើ ...

ស្ងួរចុប ... នៅលើក្តារក្រាលក្បែរខ្លួន លោកឧត្តមមន្ត្រី ភ្ញាក់ក្រញាងព្រោះឃើញកាំបិតស្នៀតមួយ ដោតឆ្កឹង មានចងជតីក្រហមមួយបន្ទះតូច ដែលក្នុងនោះមានរូបក្បាលខ្មោច ។ លោកឧត្តមមន្ត្រីស្រែកភ្លាត់មាត់

— វាមកហើយ ! វាមកហើយ. នេះនែវា តោងព័ទ្ធវាឱ្យជាប់

ទាហានម្ភៃនាក់ដែលចាំយាមស្ទុះពីគ្រប់កន្លែងមកស្ទួនស្នៅគ្រប់ៗគ្នា តែសម្លេងសួរគ្រលរៗ ខ្ទរមកថា

— ... ហាំ ! ហាំ ! ពួកឯងរកយើងមិនឃើញទេ. យើងនៅក្បែរៗឯងជានិច្ច. ជីវិតឯងនៅក្បែរយើងគ្រប់នាទី ។ លោកឧត្តមមន្ត្រី ! ខ្ញុំអាចសម្លាប់លោកពេលណាក៏បាន. យើងបានព្រមានលោក ដោយសូមឱ្យលោកកែគំនិតដើម្បីអនុគ្រោះខ្មែររាប់លាន់នាក់នោះផង លោកបែរជាមានចិត្តឫស្យា ឱ្យគេមកយាមលោក ដោយមើលងាយ ម្ចាស់សំបុត្រអនាមឹកនោះ

ថែមទៀត ។ ទាហានមួយសែននាក់ទៀត ក៏មិនអាចជួយលោកឱ្យផុតពីមរណភាពនេះបានដែរ ...

សម្លេងលោកឧត្តមមន្ត្រីញ័រ បន្លឺខ្លាំងៗ ថា ÷

— ឯងជានរណា ?

— ហាំ ! ហាំ ! ជាខ្មែរ, ជាខ្មោច, ជាយមរាជ, ហាំ ! ហាំ ... ខ្ញុំប្ដេជាចិត្តថាដើរសម្លាប់ជនដែលប្រវញ្ចទ្រព្យជាតិ, ចោរប្លន់រាស្ត្រ នាមឺនពុករលួយឱ្យត្រាតែអស់ ពីក្រុងនគរទ្រាសនេះ ។ សល់តែដប់ដង្ហើមទៀតលោក ត្រូវអស់ជីវិតហើយ ដូច្នេះលោកត្រូវងាកទៅផ្ដែរផ្ដាំងប្រពន្ធកូន ទៅ ...

— ឯង ... ឯង ... ឯង ... មើលងាយអញណាស់

— ហាំ ! ហាំ ! ... កុំរញ៊ីរញ៊ូរអីលោកនៅចំពោះក្ដីស្លាប់ដច្នេះ. ចុះជីវិតខ្មែររាប់រយដែលឯងសម្លាប់ដោយឥតហេតុកាលពីមុន ? លោកនឹកឃើញទេ តើគ្នាស្លុតបែបម៉េចខ្លះក្នុងកណ្ដាប់ដៃលោក ? ចុះរាស្ត្រខ្មែររាប់ម៉ឺននាក់ទៀតដែលលោកហុតឈាម ... តើវេទនាបែបណា ? ឃើញទេ បាបគ្រោះនេះមានដល់លោកហើយ ទ្រព្យធនដែលលោកប្លន់ជាតិ មានគរដូចភ្នំលោកស៊ីៗ មិនអស់យកទៅស៊ីចាយ ស្ថាននរកក៏យកទៅពុំរួច ... ហាំ ! នៅសល់តែដង្ហើមទៀតទេលោកឧត្តមមន្ត្រី ...

ទាហាន ! ទាហាន !

— ឥតប្រយោជន៍ទេ ! ឥតប្រយោជន៍ទេ, នៅជិតខ្ញុំគ្មានទាហានអីទេ គ្មានវិសេសយ៉ាងណាទៀតទេ, គ្មានថ្មើងយ៉ាងណាទៀត, នៅជិតខ្ញុំគឺ

យុត្តិធម៌. បើមានមនុស្សអយុត្តិធម៌នៅជិតខ្ញុំ គឺមនុស្សនោះត្រូវស្លាប់ ។ ខ្ញុំហាក់ដូចជាផ្ដើននឹងច្បាប់រដ្ឋពេកហើយ. តែធ្វើពេលនេះខ្ញុំត្រូវលេងដៃក្ដៅដោយអាថ៌កំបាំងដូច្នេះឯង ។ អូ ! ដល់ពេលលោកត្រូវអស់ជីវិតហើយតើ. ... មួយ ... ពីរ ... បី ...

កាំបិតមួយប្រវែងមួយល្ហូក មិនដឹងហោះពីស្ថានណាបានមកផ្ដាច់កេសាលោកឧត្ដមមន្ត្រី ... ឱ្យផុតពីដងខ្លួន គួរឱ្យស្ញែងក្រៃលែង ។ លោកឧត្ដមមន្ត្រីទទួលមរណភាពក្នុងពេលមួយប៉ប្រិចភ្នែក ធ្វើឱ្យលោកជំទាវ. បុត្រី ព្រមទាំងអស់ពលសេនាស្រឡាំងកាំងគ្រប់ៗគ្នា ...

# ជម្រះសង្គមចាស់ ...

ម្រហែលប្រាំដង្ហើមក្រោយមក ...

ដំណឹងឃាតកម្មដ៏សាហាវដែលកើតឡើង ត្រូវផ្សាយតពីមាត់មួយទៅមាត់មួយយ៉ាងឆាប់រហ័ស ធ្វើឱ្យមានការជ្រួលច្របល់យ៉ាងធំ ក្នុងគេហស្ថានលោកមេទ័ពត្រួតដែនខាងជើងនៃនគរក្រុងទ្រាស ។

កងរបៀបចាត់ការ ការពារមិនឱ្យនរណាចូលទៅក្នុងបន្ទប់ដែលកើតអំពើឃាតកម្មនោះ ។ លោកជំទាវនឹងនាងជាបុត្រីសព ត្រូវគេសែងទាំងសន្លប់ស្តូកស្តឹងទៅព្យាបាល ...

នាយពលធំតូចទាំងឡាយ រត់ខ្វៃដៃខ្វៃជើងដើរឆែកគ្រប់ច្រកល្ហកររកឃាតករ. ហើយចាប់ជនដែលគេសង្ស័យបានប្រាំនាក់ចងជាស្រេច ។

មនុស្សជ្រួលទៅខាងក្រោយអស់ ស្រមោលមនុស្សខ្មៅមួយសម្រូតតាមសសរ. លោតព្រិបដល់ក្តារ. អ្នកយាមម្នាក់ស្រែកយ៉ៃឡើង

— ឃាតករ. ឃាតករ

មនុស្សដែលមានសម្លៀកបំពាក់ខ្មៅ. រំមុខដោយក្រណាត់ខ្មៅរត់គេចចុះឡើង ។ អស់ពលយោធាផ្អើលឆោឡោរត់មកកាន់ចន្លោះ. ដាវ. លំពែងច្រងាង១ ។ ទាហានដែលបានឃើញមនុស្សខ្មៅមុនគេ ចង្អុលទាំងញ័រស្លន់ប៉ប្រិបប៉ប៉ុបថា ÷

— នុ៎ះវា!... នុ៎ះ! នុ៎ះ ... វារត់ចូលត្រង់នោះ

ទាហានស្រទៅតាមដៃដែលចង្អុល ។ មនុស្សខ្មៅលោតព្រួសដល់ដី ទាហានឃើញហើយរត់ដេញតាមឥតបង្អង់ ។ មនុស្សខ្មៅរត់ឡើងលើវិមានវិញ ហើយចាប់ឡើងសសរទៅលើដំបូលរហ័សដូចស្វា ។ ឃាតករឡើងដល់ពិតានស្រេច ។ ស្នូរគ្រេវនៃកងពលលាន់ឮឡើងតែពាក្យមួយថា

— វានៅខាងលើ ! វានៅខាងលើ ... ចាប់វា។

មាត់មួយបញ្ជាថា ÷

— ឡើងតាម ! ឡើងតាម ...

ផ្ទៃភូមិស្ថានលោកមេទ័ព ក៏កុះករកងរំពងគ្រប់ច្រកល្ហក មួយរំពេចទាហានកំពុងជ្រួលច្របល់ រកជណ្តើរដាក់ឡើងទៅលើពីដាន ដេញចាប់ឃាតករ ។ ឃាតករឯកសណ្ឋានខ្មៅដែលអស់ច្រករត់ ក៏នៅស្ងៀមក្នុងទីងងឹតវេរារង់ចាំហេតុការណ៍ ។ អស់ពលសេនាចាប់ឡើងសសរ ត។ គ្នា ។ មនុស្សក្រឡេកមើលនាយអាយ ... អីយ៉ា ! មិនស្រួលហើយតើ តើត្រូវធ្វើយ៉ាងណាទៀត ? ងាកទៅម្ខាងគឺចុងដំបូលខ្ពស់បំផុតនៃវិមាន ដែលមើលទៅដីឃើញសន្ធឹម ។ ងើយមើលដំបូល ។ មានក្បឿងពាស. ដៃរណែងក៏ញឹកជិតស្លុង ទៅមិនរួច ។ ណ្ហើយសម្ងំតាមរឿងទៅចុះ ។

ទាហានម្នាក់ឡើងទៅដល់

មនុស្សខ្មៅផាក់ម៉ាំង. ទាហាននោះធ្លាក់ភីងលើក្តារស្រែកបានតែ មួយ "យ៉ៃ" ក៏ក្លាយជាខ្មោចឥតបង្អង់ ។ ទាហានឯទៀតក្រញ៉ែងខ្លួនបះសក់គ្រប់គ្នា ។

— ឡើងសសរខាងណោះ ...

មនុស្សខ្មៅលូនទៅសម្ងំសសរមួយទៀត. ហើយទាហានម្នាក់ក៏ឡើងទើម១ លូកដៃចាប់ជ្រុងពិតាន ។ ឃាតករអនាមឹកឃារជើងបុកពិបមកទៀត. អ្នកឡើងធ្លាក់ខ្លោកប្រកាច់នទៀលដូចមុន ...

— គ្នាវាពីរនាក់ហើយ... ប្រយ័ត្ន...

មាត់មួយទៀតបន្លឺថា ÷

— វាតែម្នាក់ឯងទេ ... វានៅខាងណោះ ឥឡូវយកភ្លើងមកបញ្ចាំង ហើយយកផ្គូរ មកលំពែងមកឆាប់១ ...

ស្នូរមាត់ខាងក្រោយនេះចំជាមិនស្រួលមែន. មនុស្សខ្មៅនឹកថាថ្ងៃអន្សាដល់ហើយមើលទៅ ។ មនុស្សនេះថយ១ ជានិច្ច ។ ជើងខាងក្រោយប៉ះជញ្ជាំង. គិតគេចទៅស្តាំ ខាងឆ្វេង. ខាងលើទៅក្រោម ... មិនបានទេ ទៅមិនផុតជើងព្រោះគ្មានឈើជាន់ ។ ធ្វើយ៉ាងណាទេ ?

មនុស្សខ្មៅហក់ទៅលើដំបូលរោងស្បូវ មួយនៅខាងលិចវិមានធ្លាយដំបូលនោះ ធ្លាក់ដល់រនាបជាស្រេច. រួចលោតទៅលើមាត់បង្អួច ចាប់ផ្ទឹមវាត់ខ្លួនចុះទៅដល់ដី ។ អ្នកផ្អេធ្លាចុះឡើង ។ កងទាហានខ្លះបញ្ចាំងភ្លើង. ខ្លះបាញ់ ... ឃើញថាមិនស្រួល. មនុស្សអនាមឹក រត់ទៅក្បៀនកំផែងក្បែរគល់គគីរមួយ ។ អ្នកក្តោបដៃធ្វើជាបំពងត្រែ ហើយស្រែកថា ÷

— ហេ ! ហេ ! កនយើង. ខ្ញុំនៅឯណោះ

ទាហានរត់ព្រួទៅរកឃាតករ១ ចោលកាំបិតមួយរុំដោយក្រដាសមួយសន្លឹក ... ដោយនឹងនៅលើដី ចុងជើងនាយពលម្នាក់ឈ្មោះកត ។ នាយកតស្រឡាំងកាំង រើសជាប្រញាប់ ហើយឥតរវល់លារមើលអ្វីឡើយ ។

អ្នកបញ្ជាឱ្យតាមឧក្រិដ្ឋជន ... តែ ... តែ ... មនុស្សសម្ងាត់នេះបាត់ស្រមោលឈឹង ។

កងពលរបស់នាយកតមកដល់ទីដែលមនុស្សខ្មៅឈរ អម្បាញ់មិញ ហើយឡើងលើដើមគគីរមើលទៅក្រៅ ... ស្ងាត់សូន្យឥតឃើញអ្វីសោះ ។ គេចែកគ្នារកតាមគម្ពោតឬទីបំបាំងនានាដែលគេសង្ស័យ. តែនៅតែរកមិនឃើញ. បាត់មនុស្សចម្លែកនេះឈឹង បីដូចជាទេពតាអារុក្ខអារក្ខលាក់បំពួនដូច្នោះ ។

នាយកតដកដង្ហើមធំ ផ្លុំខ្យល់បញ្ចូលក្នុងអាវរអ៊ូរថា.

— វាទៅឆ្ងាយហើយ ! ...

នាយកតភ្ញាក់ព្រើត ព្រោះដៃទាហានរបស់ខ្លួនម្នាក់កេះ ហើយនិយាយថា ÷

— លោកនាយមើលនោះ ... នរណាជិះសេះបួនប្រាំនាក់ទាំងយប់អាធ្រាតដូច្នេះ ?

នាយកតសម្លឹងក្នុងទីងងឹត ។ សេះដែលរៀបមកដល់ កញ្ជ្រៀវឡើងយ៉ាងអង់អាចក្នុងទីងងឹត ។ នាយកតពោលថា ÷

— ក្រុមនេះមានគ្នាប្រាំនាក់ ហើយសំដៅទៅមាត់ទ្វារធំនោះផង ។ វិន ! វិនឯងទៅប្រាប់អ្នកយាមទ្វារថា កុំឱ្យនរណាចូលឱ្យសោះ ព្រោះក្នុងគេហស្ថានលោកមេទ័ពកំពុងមានហេតុមិនស្រួល ឮទេ ?

— បាទទទួលបញ្ជា

ទាហានឈ្មោះ វិន រត់វឹងទៅមាត់ទ្វារ ឥតបង្អង់យូរ ។ នាយកតក៏ដើរទៅកាន់មាត់ទ្វារនោះដែរ ។ អ្នកជិះសេះមកដល់ដែលនាយកត ឮមាត់ស្រីនិយាយថា ÷

— ហេតុការណ៍ធ្ងន់ធ្ងរដល់ថ្នាក់ហ្នឹង ពួកឯងនៅតែមិនដឹងថាជាគ្នា គេជាគ្នាឯងទៀតឬ ? ... កំសាកណាស់គ្នាមួយហ្វូង ព័ទ្ធចាប់មនុស្សម្នាក់មិនបានគួរឱ្យខ្មាស់ខ្មោចណាស់លោកអើយ ...

អ្នកយាមបន្ទប់កាយថា ÷

— តាមបញ្ជាលោកនាយ ... យាមមិនឱ្យនរណាចូលទាំងអស់ទាន !

នាយកតមកដល់ ស្ទុះទៅជិត ...

— អ្នកនាងទេ ! ... អញ្ជើញចូលចុះ. អញ្ជើញអ្នកនាង ។ ខ្ញុំស្មានតែនរណាផ្សេងទៀតទេតើ ។ អ្នកនាងមកតាមផ្លូវនោះមានប្រទះឃើញមនុស្សម្នាក់ ស្លៀកពាក់ខ្មៅជិះសេះរត់ដែរ ឬទេ ?

— មនុស្សខ្មៅ ?

— ប្របាទ ! មនុស្សខ្មៅជាឃាតករ ដែលខ្ញុំរកចាប់ហើយ ឥឡូវវាភៀសខ្លួនចេញទៅបាត់. ទៅតាមផ្លូវនោះឯង ។

— ខ្ញុំគ្មានឃើញនរណាម្នាក់សោះទេ ... ឥឡូវខ្ញុំត្រូវការចូលទៅក្នុងមើលហេតុការណ៍ ។ ពុំនឹកស្មានថាអស់លោកធ្វើការប្រហែសដល់ថ្នាក់ហ្នឹងសោះ ។

— គ្នាវាតែម្នាក់ ...

— តែម្នាក់ទេ ? រួចវាធ្វើឱ្យជ្រួលច្របល់ពេញវិមាន. រួចវាធ្វើឃាត លោកមេទ័ពបានទៀត. គួរឱ្យខ្មាសវាមែន ! ...

ថាហើយនាងស្រីវាយសេះឱ្យទៅមុខ ... ។ នាយកតនិយាយថា ÷

— អ្នកនាង ...

នាងជិះសេះឈប់ ...

— មានការអី ...

— មុនពេលវាចេញទៅ. ឃាតករបានបោះសំបុត្រនេះទុក ...

— ឯណា ?

នាយកតបន្ទន់កាយហុចសំបុត្រទៅនាង ... នាងក៏ចូលទៅក្នុង ដោយមានទាហានមួយចំនួនជូនដំណើរទៅផង ។ គឺនាងមាលាដែលក្នុង ពេលឥឡូវ ក្លាយជានារីមានទេពកោសលចម្បងក្នុងការកាប់ដាវ ។ នាងជា នាយរងត្រួតពលសេះទាំងអស់នៅនាក្រុងទ្រាសនេះ ។

ក្រោយពីបានពិនិត្យមើលហេតុការណ៍សព្វគ្រប់ ដែលមានឡើងក្នុង រាត្រីនោះ នាងមាលាបានលាតសំបុត្រឃាតករសសរទុក មើលខ្លាំងៗ ចំពោះ មុខទាហាននឹងមនុស្សនៅក្នុងវិមាននោះ ...

មនុស្សដែលដាច់កនេះ. គឺដំណាងអំពើពុករលួយដែលត្រូវតែបះដើង ជានិច្ច នៅចំពោះមុខយុត្តិធម៌ ដែលជាឆន្ទះពិស្ដាររបស់រាស្ត្រ ។

ជាមនុស្សពុករលួយពីជំនាន់ចាស់ ហើយរហូតមកទល់សម័យនេះ គ្មានវិធីកែប្រែបាន. ខ្ញុំឃាតករអនាមឹក ជាដំណាងយុត្តិធម៌ សូមធ្វើការ

ជម្រះសង្គមចាស់ចោលចេញ. ហើយនឹងធ្វើឃាតកម្មលើអស់មន្ត្រីធំៗ ជាច្រើនទៀតនៅនគរទ្រាសនេះ ... ដែលពុករលួយ. ស៊ីសំណូក ... មានមន្ត្រីនៅក្នុងកងទ័ព. ក្នុងហិរញ្ញវត្ថុតុលាការជាដើម ។ ដើម្បីកុំឱ្យឃាតកម្មអានាធិបតេយ្យនេះកើតឡើងទៀត. សូមតុលាការ ចាប់ធ្វើសកម្មភាពឡើងសើរើវែកមុខមនុស្សប្លន់ជាតិ. បើច្បាប់ថាកាត់ក គឺត្រូវតែកាត់ក. បើថាត្រូវហូតងារ គឺត្រូវហូតងារ ... ។

រដ្ឋាភិបាលដែលជាទីបង្អែកពុំនាក់របស់រាស្ត្រ ត្រូវប៊ានអារកាត់ចំពោះមុខប្រជារាស្ត្រ ត្រូវប៊ានដោះស្រាយអំពើពុករលួយ. បញ្ហារាស្ត្រអត់បាយ. បញ្ហាសិទ្ធិសេរីភាព. នឹងបញ្ហាបូរណភាពទឹកដី ។

រយះពេលពីអាទិត្យនេះ គឺជាពេលវេលាដែលរដ្ឋាភិបាលត្រូវធ្វើការបើពុំនោះសោតទេវិបត្តិនយោបាយនៅនគរទ្រាសនេះ រិតតែធ្លាក់ចុះទៅក្នុងភាពអាប់អួរដ៏ធ្ងន់ធ្ងរមួយ ...

ហត្ថលេខា **ឃាតករ**

នាងមាលាបត់សំបុត្រដាក់ក្នុងហោប៉ៅ ញញឹមបន្តិចដៀងភ្នែកមើលមនុស្សខ្លះក្នុងទីប្រជុំនោះ ។ សម្លេងអ៊ូ រកើតឡើងបញ្ចេញយោបល់ពីលិខិតរបស់ឃាតករ ... ។

ពេញមួយយប់ គ្មាននរណាបានដេកពួនអ្វីឡើយ ។ គេរៀបចំពិធីដិកលស់សព ទម្រាំព្រលឹមឡើងអាជ្ញាធរ មកធ្វើវិធីកត់ហេតុ ... ។

ព្រឹកនោះ. នៅភូមិភ្លៀតមានសកម្មភាពអ៊ូ អរ ប្លែកពីធម្មតា ។

មនុស្សម្នាមហាជនជាច្រើនពាន់នាក់ ឈរមីដេរដាសនៅមុខទីផ្សារ ដែលនៅម្ខាងនេះ កងរក្សាស្រុកប្រដាប់ដោយឯកសណ្ឋាន មើលទៅឃើញ ស្វាហាប់ក្រៃលែង ។ បុរសជាមេកាន់ក្រដាសមួយសន្លឹក ប្រកាសលាន់ឮ ខ្លាំងៗ ថា ÷

— បងប្អូនជាទីស្នេហាទាំងឡាយ ដោយស្ថានភាពស្រុកទេសយើង ពុំទាន់មានជំហររឹងប៉ឹង. រដ្ឋាភិបាលសូមអង្វរចិត្តបងប្អូនឱ្យរក្សារបៀបរៀប រយ កុំគប្បីឱ្យមានការប្រកាន់បក្សប្រកាន់ពួក កុំគប្បីប្រព្រឹត្តអំពើណាដែល ផ្ទុយ នឹងច្បាប់សម្រាប់រដ្ឋ ។

បុរសនេះប្រកាសចប់ហើយ. អ្នកស្តាប់ម្នាក់ក៏ឡើងតវ៉ាថា ÷

— ក្នុងចំណោមរាស្ត្រ ឃើញថារាស្ត្របានបំពេញភារកិច្ចមួយដ៏មុត មាំណាស់ ចំពោះជាតិមាតុភូមិ គឺបានកាន់អាវុធកំចាត់ខ្មាំងដ៏អង់អាច រហូត ដល់សត្រូវបាក់បបខ្លបខ្លាចដោយអន្លើទៅហើយ. តែក្នុងចំណោមនាម៉ឺន. យើងខ្ញុំសង្កេតឃើញថា នាម៉ឺនបានប្រព្រឹត្តអំពើពុករលួយច្រើនណាស់ ដោយ ប្លន់ជាតិ ដោយជិះជាន់រាស្ត្រ ដោយទុករាស្ត្រជាសំរាម ដោយរកស៊ីបំបិទ ភ្នែករាស្ត្រ ។ បើផ្ទៃក្នុងនៃសង្គមខ្មែរនៅតែរលួយបែបនេះ ឃើញថាខ្មែរ យើងត្រូវតែរលាយនៅពេលខាងមុខនេះហើយ ។ ដូច្នេះមុនអស់លោកមក ឃោសនាទីនេះនៅចំពោះមុខរាស្ត្រ ត្រូវលោករៀបចំផ្ទៃក្នុងឱ្យបានស្រួល បួលសិន ... មែនទេលោកពូ ?

ឃោសកៈភាំងបន្តិច ទើបឆ្លើយតបទៅថា ÷

— រដ្ឋាភិបាលបានគ្រោងជានិច្ច ដើម្បីធ្វើឱ្យរាស្ត្របានសុខបានសប្បាយ. ហើយបំរុងនឹងរកសន្ដោ ប្រយោជន៍ឱ្យមានយុត្តិធម៌ក្នុងសង្គម ... ជូនបងប្អូនជាទីស្នេហា ...

— ហ៊ូ ! ហ៊ូ ៗ ៗ ៗ ? គ្រោង ? រកសន្ដោឱ្យមានយុត្តិធម៌ ? ក្រែងមិនមែនទេដឹងហ្ន៎លោកពូ ? តើគ្រោងនោះឆ្នាំណានឹងចាប់អនុវត្ត ? មួយឆ្នាំហើយដែលយើងកែក្រេរបបនេះដោយទម្លាក់ព្រះនរិន្ទវង្ស តែម្ដេចក៏យកមនុស្សរបស់ព្រះហរិវង្ស មកប្រើការទៀត ? យើងខ្ញុំជារាស្ត្រស្អប់ខ្ពើមអំពើជិះជាន់មនុស្សដែលក្រុមព្រះនរិន្ទវង្សប្រព្រឹត្ត. ហើយសម័យឥឡូវ ម្ដេចក៏នៅតែមាននាម៉ឺនហុតឈាមរាស្ត្រនោះដដែល ។ អស់លោកប្រកាសថាគ្រោង ! គ្រោង ! គ្រោង ! តែរាស្ត្រជិតដាច់ខ្យល់ស្លាប់ទៅហើយ. ដីខ្មែរត្រូវខ្មាំងបរទេសលេប បន្តិចខ្លះៗ ទៅហើយ ម្ដេចក៏នាម៉ឺនទាំងឡាយប្រជែងគ្នាធ្វើមហាសេដ្ឋីដល់ណាទៀត ?

— ហាស ៗ ៗ !

គឺសម្លេងសើចរបស់បណ្ដាជនដែលនៅជិតនោះ. រួចសំណើចនេះ មហាជនសើចបន្តៗ គ្នាជាសញ្ញាកាន់ជើងមិត្តខ្លួន ធ្វើឱ្យឃោសកជនល្ងឹងមុខ ។

នៅឆ្ងាយដាច់ពីគេបន្តិច ក្រោមដើមស្វាយនោះ បុរសម្នាក់នៅក្មេងដុះពុកមាត់ស្រមូវដែលគេមើលពុំដឹងជានរណា ។ មនុស្សនេះសើចមករកមនុស្សម្នាក់ទៀតដែលចាស់ជាង ។ គឺវិសេសភក្ដី និងរាហុល ដែលយើងបំភ្លេចចោលយូរមកហើយៗ បុរសពុតមាត់ស្រមូម នោះគឺវិសេសភក្ដីនោះឯង វិសេសភក្ដីនិយាយថា ÷

— ចំនួនបីខែដែលយើងចេញទៅធ្វើការនោះ គឺប្រាកដជាមិនខាតទេ. បងមើលចុះ រាស្ត្រឥឡូវចាប់មានកំណើតឡើងវិញហើយ ដោយយល់សិទ្ធិរបស់ខ្លួន ចេះតវ៉ាចេះឆ្លើយតបរកខុសត្រូវ ហើយព្រមទាំងចេះឪដងឱ្យគេទៀតផង ។ មានអី ! ឱ្យតែរាស្ត្រយើងយល់សិទ្ធិរបស់ខ្លួនច្បាស់ទៅ ស្រុកយើងនឹងថ្កើងថ្កានទៅហើយ ។

រាហុលផ្អែកស្មាទៅនឹងដើមឈើ ច្រត់ដៃនៅចង្កេះហើយញញឹមឆ្លើយថា ÷

— មកទល់ពេលនេះ ទើបខ្ញុំបានយល់ច្បាស់ថា សិទ្ធិជាវត្ថុពិសេសលេខមួយ របស់ប្រជាជន រួចសិទ្ធិរបស់ប្រជាជននេះ អាចមានជាបន្ទាត់តូចមួយ បំភ្លឺដល់សម្បជញ្ញៈ អ្នកកាន់ការរដ្ឋឱ្យដើរទៅតាមផ្លូវត្រូវ ផ្លូវចំរើនផ្លូវថ្លៃថ្នូរ ... ការដែលយើងធ្វើក្នុងរយៈពេលបីខែនេះ ក៏បានផលធូនល្មមក្នុងចិត្តដែរមែនទេ ?

— មើល ! រាហុលឯងបានបង្រៀនអីខ្លះ ជាប្រយោជន៍ដល់រាស្ត្រយើង ?

— ច្រើនណាស់លោកគ្រូ ! ... មានបង្រៀនពីសិទ្ធិពីសេរីភាព ពីបញ្ហាខ្មែរ. បញ្ហាខ្មាំង. បញ្ហាបូរណភាពទឹកដី បញ្ហាសេដ្ឋកិច្ចជាដើម ។

— ហ៎ា ! ហ៎ា ! រាហុលឯងគ្រាន់បើមែន ។ រួចប៉ុន្មានថ្ងៃនេះបាត់ដំណឹងពីចន្ថា និងមហាកាលឈឹង មិនដឹងការដែលខ្ញុំឱ្យបំពេញនោះយ៉ាងណាទៅហើយ ។ អើមើលនុះ ! រាហុលឯងចាំស្តាប់គេឃោសនាអីទៀតហើយ ?

រាហុលងាកទៅឃើញ ឃោសកជនលើកដៃទាំងពីរឡើងលើ ...

— ឈប់មួយស្របក់សិនបងប្អូន ... ឈប់ស្ងៀមសិន ...

មហាជនក៏ឈប់ស្ងៀមឈឹង ... ឃោសកជនបន្តថា ÷

— តាមលិទ្ធិប្រជាធិបតេយ្យ យោបល់រាស្ត្រទុកជាយោបល់បានការ ។ ដូច្នេះបងប្អូនណាមានយោបល់អីក៏សូមថ្លែងមកចុះ បើឃើញថាយោបល់នោះគួរអនុវត្តទៅបានយើងខ្ញុំនឹងសូមយកយោបល់ នោះជាបានការ ។ ឥឡូវអញ្ជើញ ...

តាចាស់ម្នាក់ឡើងលើក្បាលដំបូកស្រែកមកថា ÷

— មុនអ្វីៗ ទាំងអស់ ត្រូវរដ្ឋាភិបាលហ៊ានជំរះ បញ្ជីចាស់ចោលមួយសាសិន ... បើអាចធ្វើដូច្នេះបានរាស្ត្រ យើងខ្ញុំមានការកក់ក្ដៅជាអតិបរមា ហើយសូមបូជាកាយ បូជាចិត្តតស៊ូ យកជ័យជំនះឱ្យបានមកជាស្ថាពរ ... បើពុំនោះសោតទេ . គឺខ្មែរមួយចំនួនធំប្រាកដជាលង់ខ្លួនក្នុងនយោបាយបោកប្រាស់របស់ក្រុមស្ដេចវង្វេងរាជ្យហើយ ...

ស្នូរគ្រេវនៃអ្នកស្ដាប់ លាន់ឮឡើងស្ទើរហែកមេឃតែពាក្យថា ÷

— ត្រូវហើយ ! ត្រូវហើយ ! ត្រូវជម្រះបញ្ជីសង្គមចាស់ចោលសិន ...

— បាន ! បាន ! ខ្ញុំនឹងនាំយោបល់បងប្អូនទៅចាត់ការឱ្យបានសម្រេច ដើម្បីវឌ្ឍនភាពនៃនគរយើង ។ សូមបងប្អូនកុំមើលបំណាំ បើឃើញថាយើងខ្ញុំក្បត់រាស្ត្រ សូមបងប្អូនវិនិច្ឆ័យតាមទោស បើឃើញថាយើងខ្ញុំបំរើរាស្ត្រមែនសូមជួយយើងខ្ញុំផង ...

— ជយោ! ជយោ! ...

ប្រជាជនស្រែកជយោពេញរំពងមាត់គ្រប់គ្នា នៅពីមុខសេចក្ដីសម្រេចដ៏ជាទីពេញចិត្តនេះ ។ រាស្ត្រទាំងឡាយបានកត់សំគាល់ក្នុងចិត្តថា បើរដ្ឋាចាប់អនុវត្តផែនការចុងក្រោយ ដែលជាឆន្ទៈពិស្ដាររបស់រាស្ត្រនេះ គឺជាតិខ្មែរប្រាកដជារស់ ហើយជាកិត្តិយសមួយយ៉ាងធំសំបើមសម្រាប់អ្នកដឹកនាំរដ្ឋ ។ បើប្រសិនការនេះគ្រាន់តែនិយាយឱ្យរួចពីមាត់ទេ ពោលបើសិនជនពុករលួយទាំងឡាយ ពុំបានបញ្ជូនខ្លួនទៅតុលាការវិនិច្ឆ័យតាមទោសទេនោះ រាស្ត្រមុខជារវាតចិត្តចេញពីរដ្ឋាភិបាលយ៉ាងច្រើនឥតគណនា. ស្ដេចពាលដែលជាប់ទ្រុងឯស្យាមប្រទេសក៏បានលេសឃោសនា ពន្លិចពន្លង់ខ្មែរថែមមួយកម្រិតទៀត ។ ទីបំផុតបរិយាកាសនយោបាយនៅក្រុងនគរទ្រាសយើងចេះតែធ្លាក់ទៅក្នុងអន្លង់មួយដ៏សែនជ្រៅ ហើយអាចធ្វើឱ្យកម្ពុជាទាំងមូល រលប់បាត់ពីផែនទីសលកលោក ។

វិសេសភក្ដិនិងរាហុលញញឹមជានិច្ច ចំពោះសេចក្ដីសម្រេចចិត្តដ៏ក្លាហានរបស់ឃោសកជន ដែលទើបមានជាលើកដំបូងបង្អស់ ហើយគេបានទន្ទេញជាប់មាត់ថា មានតែឆន្ទះប្រជាជនទេ ដែលមានជីវិតរស់នៅជានិច្ចគ្រប់ កាលៈទេសៈ ហើយមានតែឆន្ទះប្រជាជនេះឯងដែលធ្វើឱ្យដំណើរជាតិអាចមានប្រសិទ្ធិភាព ក្នុងការស្វែងរកសេចក្ដីចំរើន. សមភាព ភាតរភាព យុត្តិធម៌ ... សន្តិភាព ...

# យើងជួបគ្នា

**មួយ**អាទិត្យមកហើយ ដែលនៅក្នុងដែននគរក្រុងទ្រាស បានជួបនូវហេតុចម្លែកមួយកើតឡើង ...

គឺគេបានប្រទះមនុស្សមួយក្រុម ដើរបិទប្រកាសតាមទីជនបទដាច់ស្រយាល ទៅស្រុកស្រែចំការនានា នាំឱ្យបណ្ដាជនផ្អើលមើលភ្លូកទឹកភ្លូកដី ហើយព្រួយបារម្ភដល់វាសនាខ្លួននឹងវាសនាប្រទេសជាតិរកអ្វីផ្ទឹមពុំបាន ។ ម្នាក់ៗ ដណ្ដឹងសួរគ្នាពីមាត់មួយទៅមាត់មួយថា "តើខ្មែរនឹងត្រូវរលាយនៅពេលខាងមុខនេះឬអ្វី ?"

ប្រកាសនោះគេអាចឃើញសេចក្ដីថា ÷

**ក្រុមចោរប្លន់រាជ្យ ដែលវាអំរើលរាជបល្ល័ង្កនោះ វាមិនអាចគ្រប់គ្រងប្រទេសជាតិបានទេ ព្រោះភាន់ការពុំទាន់បានអ្វីផង ធ្វើឱ្យអ្នកវេទនាដោយអំពើជិះជាន់របស់មន្ត្រី, មានអំពើពុករលួយក្នុងសង្គម, មានទុរ្ភិក្ស ។ល។**

**ដូច្នេះ សូមបងប្អូនកុំបង្អង់យូរ ចូរព្ធួតដៃគ្នាឡើង វាយកំទាត់ពួកវា ...**

វាស្ត្រដែលត្រចៀកទន់ ហើយធ្លាប់លង់ក្នុងការឃោសនារបស់ព្រះនិរន្ទវង្ស គឺដោយឃើញមន្ត្រីភាគតិចរឡេមរឡឹមពុករលួយដូច្នោះមែន ក៏ទោរចិត្តទៅខាងក្រុមស្ដេចពាលបន្តិចម្ដងៗ ... ទប់មិនចង់ឈ្នះ ។ ឯអ្នក

ដែលដឹងរឿងពិតនោះវិញងាកមុខទៅគៀនជញ្ជាំងសម្រក់ទឹកភ្នែក អាសូរដល់មាតុភូមិខ្លួន រអ៊ូរពាលម្នាក់ឯងថា ទ័ពព្រះនរិន្ទវង្សដែលប្រុងចូលវាយលុកដណ្តើម អាណាចក្រក្រុងទ្រាសជាថ្មីទៀតនេះ គឺជាទ័ពសៀម ឧបមាថាបើទ័ពនេះឈ្នះ. ដីខ្មែរ ត្រូវបេះទៅលើកណ្តាប់ដៃសៀមគ្មានសល់មួយដុំ ទេ ... ឯក្រុមស្តេច ទោះស្រុកខ្ញុំគេ រាស្ត្រតោកយ៉ាកយ៉ាងណាក៏ធ្វើពុំឮ គឺពិតយ៉ាងណាឱ្យតែបានទូលមកុដរាជបុំណ្ណោះ ។

នេះជាព្រឹត្តការណ៍ថ្មីមួយគួរបារម្ភ បោកបក់មកលើផ្ទៃនយោបាយនគរក្រុងទ្រាស ធ្វើឱ្យលោកក្រឡាហោមវង្សាកើតក្តីព្រួយហួសប្រមាណ ។ បានដំណឹងពីក្រុមឃោសនានៅទីជនបទ ដែលប្រជាជនសម្តែងសេចក្តីមិនពេញចិត្តនឹងក្រុមនាម៉ឺនថ្មីនោះផង ក៏រឹងរិតឱ្យលោកក្រឡាហោមយើងអន្ទះអន្ទែងក្រៃពេក ។

លុះចនោះលោកក្រឡាហោមបានអញ្ជើញដំបូកពេជ្យ នាងសាភ័ណទេវី នឹងនាងមាលា ព្រមទាំងគណៈរដ្ឋមន្ត្រីទៅប្រជុំការ ដោះស្រាយវិបត្តិក្នុងនគរ ។ លោកមានភក្ត្រាស្រពាប់ស្រពោនក្រៃលែង ថ្លែងដោយស្ងប់ស្ងៀមទៅកាន់អង្គប្រជុំថា ÷

— វេលាចុងក្រោយរបស់ខ្ញុំខ្មែរដល់ហើយ ! ក្នុងខណៈនេះថ្វីបើខ្លួនខ្ញុំចាស់ ពុំចង់ចងកម្មចងពៀរជាមួយនរណាសោះនោះ ក៏ខ្ញុំត្រូវតែលះបង់គំនិតនោះមួយពេលសិនដែរ ...

អង្គប្រជុំនៅស្ងាត់ឈឹង ពុំមាននរណាមាត់កថា ដូចម្តេចឡើង ពុំមាននរណាដកដង្ហើមឱ្យឮឡើយ ។ ពាក្យលោកក្រឡាហោមដែលនិយាយចេញ

មួយម៉ាត់ៗ មានន័យទូលាយឆ្ងាយ ដែលទាំងអស់គ្នាអង្គុយរួញខ្លួនក្នុងកៅអី ហើយប្លែកក្នុងចិត្តថា "ថ្ងៃនេះបែបមិនស្រួល..." ។

លោកក្រឡាហោមបន្តទៅទៀត យ៉ាងច្បាស់ៗ ថា ÷

— ... ក្នុងចំណោមមន្ត្រីយើង ខ្លះកំពុងវីវក់តែនឹកអំពើពុករលួយ ... អើចាប់តាំងពីថ្ងៃនេះទៅខ្ញុំប្រគល់កិច្ចការនគរទាំងអស់ឱ្យទៅកំហែងពេជ្រ ជាអ្នកចាត់ការ តាមតែធ្លាក់ឆ្នៃ យ៉ាងណាក៏ឆ្លាក់ឆ្នៃទៅចុះ ធ្វើម៉េចឱ្យតែខ្មែររស់. ហើយដើម្បីខ្មែររស់ ត្រូវហ៊ានសម្លាប់ខ្មែរភាគតិចដែលសម្លាប់ខ្មែរគ្នាឯង ...

លោកក្រឡាហោមទាញក្រដាសមួយរមូរ ពីក្នុងអាវហើយលាចេញមួយសន្ទឹកម្តងៗ ។

— ... ទាំងនេះជាលិខិតផ្ទេរអំណាច. អស់លោកធ្លាប់ស្គាល់ថ្វីដៃកំហែងពេជ្រហើយ កាលនៅនគរតាង៉ិល. គឺលោកគ្មានស្គាល់យោគយល់នរណាជាញាតិ នរណាមិត្តអ្វីទេ. បំណងលោកគឺភ្ជាប់ខ្មែរទាំងមូលនៅជាខ្មែរវិញភ្ជាប់នគរតាង៉ិល នគរទ្រាស ទាំងដីខ្មែរបែកខាងជើង ខាងត្បូង ខាងលិចខាងកើត ... មកជាខ្មែរតែមួយមុខ ... ។ ខ្ញុំសូមជាស់សម្បជញ្ញៈអស់លោកថា ស្ថានការណ៍ស្រុកទេសសព្វថ្ងៃបានធ្លាក់ដុនដាបណាស់ទៅហើយ ដោយណាមួយមានវិបត្តិគណៈរដ្ឋមន្ត្រី. វិបត្តិសេដ្ឋកិច្ចហេរិញ្ញវត្ថុដោយណាមួយទៀត នាម៉ឺនខ្លះឥតគិតនឹកនាដល់រឿង ជាតិសោះ គឺស៊ីសំណូក. លួចជាតិ ... ដីខ្មែរនៅខេត្តម្លូព្រៃ. ទន្លេពៅ. វ៉ុនសៃ ចោរសៀមនឹងលាវកំពុងប្រវេះយក ដោយវាមកនៅតាំងទីពាសពេញ ។ នៅខេត្តព្រះត្រពាំង ក្រមួនស

មាត់ជ្រូក យួនកំពុងធ្វើបាបខ្មែរនៅទីនោះយ៉ាងព្រៃផ្សៃអស្ចារ្យ ។ ឃើញទេអស់លោក ជាតិសាសន៍ខ្មែរជាជាតិរងកម្មខ្លាំងណាស់ ព្រោះតែស្ដេចក្នុងរាជ្យមុនទើបកម្ពុជាក្រោមយើងវេទនារហូតដល់សព្វថ្ងៃ. ខាងកម្ពុជាកណ្ដាលព្រោះតែ ព្រោះនរិន្ទវង្ស ដែលបង្កឱ្យមានហេតុអាក្រក់កើតឡើងរហូតមកដល់សព្វថ្ងៃ ...

មានប្រសាសន៍ចប់ហើយ លោកតាក្រឡាហាមទម្រេតកាយទៅលើកៅអីមួយវែង រង់ចាំពាក្យឆ្លើយរបស់អង្គប្រជុំ ។ សមាជិកទាំងអស់នៅស្ងៀមឈឹង ដូចគេចុកមាត់ ។ គ្មាននរណាមួយហ៊ានកម្រើកដៃបន្តិចណាឡើយលោកក្រឡាហោមងើបភក្ត្រឡើង ។

— មើលឥឡូវ ! អ្នកណាមួយមានយោបល់អ្វីក្នុងរឿងប្រគល់អំណាចនេះទេ ? សូមបញ្ចេញយោបល់មកចុះ

នាងមាលាងើបឡើងមានវាចាដោយស្រងូតស្រងាត់ថា ÷

— នាងខ្ញុំខំរិះរកឧសថ គ្រប់បែបយ៉ាងអស់ហើយដើម្បីព្យាបាលជម្ងឺខ្មែរ តែហាក់ដូចជាពុំបានកាក់កបបន្តិចសោះ ហើយណាមួយឃាតករអនាមិកបានបង្កើតបរិយាកាសអាប់អួ រអនាធិបតេយ្យក្នុងនគរយើងនេះទៀត ... វិបត្តិនេះជាវិបត្តិនយោបាយសង្គមកិច្ច. បើរដ្ឋាភិបាលពុំបានរកនាដោះស្រាយឱ្យឆាប់រហ័សទេនោះ ជាតិយើងនឹងត្រូវរលាយក្នុងពេលខាងមុខហើយ ។ ... លោកគ្រូកំហែងពេជ្រធ្លាប់មានស្នាដៃយ៉ាងច្រើនក្នុងការ

បង្ក្រាបជនពុករលួយ [១] . ក្នុងកាលៈទេសៈនេះជាតិត្រូវការជាចាំបាច់. នាងខ្ញុំចង់បានយោបល់ថាតើ លោកគ្រូមានតម្រេះយ៉ាងណាក្នុងរឿងនេះ ?

កំហែងពេជ្យងើបឡើង និយាយមួយៗ ច្បាស់សេចក្ដីថា ÷

— ជាតិខ្មែរទើបផ្លាស់របបគ្រប់គ្រងថ្មីៗ ឃើញថាខ្មែរស្រុតសម្បើមណាស់ ស្ទើរតែគ្មាននរណាហ៊ានមកកាន់ការបន្តទៅទៀតទេ គឺប្រៀបដូចគ្រូពេទ្យដែលមកព្យាបាលអ្នកជំងឺដែលដកចង្កាមាន់ហើយដូច្នោះ ពេលនេះបើខ្ញុំប្រកែកប្រណាំងទៅក៏ជាការឥតប្រយោជន៍ យើងមិនត្រូវជជែកគ្នាឱ្យហួសព្រះដែនវែងឆ្ងាយមិនបានការនោះទេ. តែខ្ញុំសូមធ្វើសហប្រតិបត្តិការជាមួយអស់លោកជាមួយខ្មែរទាំងអស់ ទើបការនេះអាចរកច្រកចេញរួច ។

សម្លេងទះដៃប្រាវមកមួយរំពេច ។ លោកក្រឡាហោមស្ទុះមក ...

— អគុណណាស់ ! អគុណណាស់ កម្រមាននរណា មានចិត្តថ្លើមដូចលោកណាស់ ...

— ជនអ្នកស្រឡាញ់អំណាច គឺអរព្រោះតែអំណាចនេះ តែបើជនដែលធ្លាប់កាន់អំណាចនោះទើបបានដឹងថា អំណាចនេះក្បៀបកខ្លាំងណាស់ ហើយដើម្បីអំណាច ត្រូវធ្វើការបំរើគេយ៉ាងឥតគណនា ។ មនុស្សសេរីមិនចង់បានអំណាចទេ ហើយក៏ពុំចង់ត្រួតនរណា. ពុំចង់ឱ្យនរណាគោរពកោតខ្លាចទេ ...

---

[១] សូមមើលសកម្មភាពមនុស្សនេះក្នុងរឿង "កំហែងពេជ្រ"

— លោកពិតជាមានឧត្តមគតិល្អណាស់ ... ឥឡូវខ្ញុំប្តិតមេដៃលើសំបុត្រប្រគល់អំណាចទៅលោក ព្រោះថាអ្នកដឹកនាំរដ្ឋត្រូវហ៊ានចេញពីកៅអីខ្លួន កាលបើដឹងថាខ្លួនធ្វើការមិនកើត ... មែន ! មែន ! ខ្ញុំចាស់ហើយ ...

— ទេ ! ទេ ! ... លោកគ្រូកុំមានប្រសាសន៍យ៉ាងដូច្នេះ លោកគ្រូមុតមាំណាស់ គឺព្រោះតែនាម៉ឺនមួយជំពូកនោះទេ ដែលវាកក្លូរកកាយមិនឱ្យលោកគ្រូធ្វើការកើត ...

អឺ ! អឺ ! ... លោកដឹងពុតត្បុតនាម៉ឺនអស់នោះហើយ តាមតែលោកធ្លាក់ឆ្នោទៅចុះ ត្រូវជម្រះបែបណាក៏ជម្រះទៅចុះឱ្យតែខ្មែរបានរស់ ...

កំហែងពេជ្រនៅទីទៃរយ៉ាង ព្រោះពុំនឹកស្មានថា កន្លែងប្រជុំការក្លាយជាវេទិការប្រគល់តំណែងដោយតែព្រៀងទុកដូច្នេះសោះ ...

អំណាចថ្មី ដែលកំហែងពេជ្រកាន់ជាប់នៅដៃក្នុងវេលាស្រុកទេសកំពុងលិចលង់នេះ គួរចាត់ថាជាអំណាចក្តៅហើយមានតែរាស្រ្ត នឹងជនដែលមានចិត្តស្រឡាញ់ជាតិស្រឡាញ់ខ្មែរពិតៗ ទេ ដែលគាំទ្រអំណាចនេះ ...

នាម៉ឺននឹងជនពុករលួយមួយជំពូកទៀតដែលជក់ចិត្តនឹង អំពើពុករលួយដកខ្លួនពុំរួចនោះ ក៏បានបង្កើតបរិយាកាសអាបអួរមួយទៀត ក្នុងផ្ទៃរដ្ឋាភិបាលថ្មី ដោយចាក់ដោតឯនាយ ចាក់ដោតឯអាយបណ្តាលឱ្យមានកង្វល់សឹងតែអ្នកកាន់ការទ្រាំទ្រនៅពុំបាន ។

តែអ្នកផងតែថា កំហែងពេជ្រជាកំពូលខ្មែរ ដែលទោះជួបហេតុភេទបែបណាក៏ដោយ ក៏ទ្រាំដោះស្រាយរឿងខ្មែរឱ្យបានធូរស្រាលជានិច្ច ។ គឺ

ដោយឆន្ទៈដ៏មុតមាំនេះហើយ ដែលបណ្ដុះចិត្តសង្ឃឹមរបស់យើងឱ្យមានជានិច្ចនិរន្តរ៍ ។

កំហែងពេជ្យ បានចាត់តាំងតុលាការមួយជាពិសេសសម្រាប់កាត់ទោស ជនជាប់ចោទពីបទប្រស្រ័យទាក់ទងនឹងបរទេសដើម្បីវាយប្រហារខ្មែរ. ព្រមទាំងវរជនពុករលួយ. នាម៉ឺនស៊ីសំណូក ... ។ល។

ដូច្នេះហើយ ទើបយើងឃើញបញ្ជីរាយនាមជនជាប់ចោទច្រើនឥតគណនា មានអស់មុខមន្ត្រីជាវរជនធំៗ អស់ទាំងមេទ័ពខ្លះៗទៀតផង ។ តុលាការបានសម្រេចទោសជាឯកច្ឆ័នថា "កាត់ក" នៅចំពោះមុខមហាជន ។ ដំណឹងនោះនាំមកនូវក្ដីរំភើបដល់អ្នកផង ព្រោះជារឿងចម្លែក ពុំដែលមានសោះក្នុងសាវតានគរទ្រាស ។ គេអាចស្គាល់បានថា អស់វរជនដែលជាប់ទោសកំបុតកពេលនោះ គឺជាវរជនដែលគ្មាននរណាហ៊ានប៉ះពាល់ដល់ឡើយ ពោលគឺវរជនដែលមានចង្កូមស្រួច មានទឹកមាត់ប្រៃ ។

សម្រាប់ថ្ងៃព្រឹកស្អែក ...

គេបានរៀបចំកន្លែងធ្វើឃាតជនក្បត់ទាំងឡាយ នៅកណ្ដាលផ្លាមួយស្រឡះ ពីខាងមុខព្រះរាជវាំងក្រុងនគរទ្រាស ។ ជុំវិញផ្លានេះ មានដើមគគីរដុះស្រោងជុំវិញចោលម្លប់ត្រឈឹងត្រឈៃ ។ គឺជាបរិវេណទូលាយស្អាតដែលគេមានរៀបចំ ជើងតាំងប្រកបដោយឃ្នាប កម្ទួយសំរាប់ពិធីឃាតកម្ម ។ នៅតាមដើមគគីរ គេមានបិទបញ្ជីរាយនាមជនទោសឧក្រិដ្ឋទាំងឡាយ ដែលគេអាចរាប់បានជាអាទិ ÷

— លោកឧត្តមប្រឹក្សាបូរាភជ ងួន កាលមើលជាចាងហ្វាងពិធីការក្នុងវាំងក្រុងនគរទ្រាស ដែលឥឡូវជាប់ចោទពីបទដឹកនាំ ផលិតផលទៅលក់ឱ្យខ្មាំង ។ ជនជាប់ចោទត្រូវកាត់ក្បាលដោតដងទង់ រឹបយកទ្រព្យសម្បត្តិទាំងប៉ុន្មានមកជារបស់រដ្ឋ

— លោកឧត្តមប្រឹក្សាសេនាបតី ឡេង

— លោកឧកញ៉ាសេនា និត្យ ហ៊ុល

— លោកឧកញ៉ាភក្តីភាជា សូ

— លោកពញាសេនាតេជោ នី.

— លោកពញា រង្គឫទ្ធិ ព្រឿង

នឹងអស់មន្ត្រីជាច្រើនទៀត ។

វេលាចុងក្រោយបំផុតនៃជនក្បត់អភ័ព្វមកដល់ ។ ព្រះអាទិត្យរះឡើងក្រឡង់ល្អស្វារ្យ ។ បក្សីហើរឆ្វៀងឆ្វៃលយំទ្រហឹងអឹងអាប់លើដើមគគីរ មានស្មោញ ក្អែកទឹក ននាល ទុង ជាដើម ។

តម្រួតនាំអ្នកទោសអស់អាយុទាំងឡាយ មកឈរមួយជុំ ដោយមានច្រវាក់នៅជើង ខ្នោះនៅដៃជាប់ក្រញោន១ ។ តម្រួតមួយកងធំកាន់អាវុធយ៉ាងមាំមួនដើរក្រវែល ប្រយ័ត្នមិនឱ្យអ្នកទេសរត់រួច ។ ... ភ្នាក់ងារគុកទាំងឡាយរត់ត្រង់ជើងត្រង់ដៃ រៀបចំតុកៅអីនៅពីមុខហ្វូងអ្នកទោស ព្រោះលោកព្រះអាជ្ញា និងលោកចាងហ្វាងគុកជិតអញ្ជើញមកដល់ហើយ ។

ព្រះអាទិត្យរះខ្ពស់ផុតពីចុងឈើ ...

ភ្ញៀវតូចធំបានអញ្ជើញមកមើលពិធីឃាតកម្មបន្តបន្ទាប់គ្នា ។ បណ្ដាជនរាប់ពាន់នាក់ក៏មកទស្សនាពិធីនេះដែរ ។ លោកចាងហ្វាងគុកអញ្ជើញមកដល់. គឺជាមនុស្សចាស់សក់ស្កូវព្រោង បានបញ្ជាឱ្យគេយកកម្រាលល្អៗមកក្រាលលើតុមួយ រួចឱ្យយកប៉ាន់តែ ពែង មកដាក់នៅកណ្ដាលតុ ។ នាម៉ឺនសព្វមុខ មន្ត្រីជាច្រើន បានមកអង្គុយតាម លំដាប់សក្តិត្រៀបត្រាក្នុងវេទិកាដែលសង់ឡើងលំអដោយស្លឹកទន្សៃ និង ស្លឹកជ្រៃក្រឹម ។

— លោកម្ចាស់អញ្ជើញមកហើយ ...

ពាក្យនេះបន្លឺយ៉ាងវែងនៅឯនាយ នាច្រកផ្លូវចូល ហើយត្រូវគេស្រែកប្រកូកបន្តៗ មកប្រយោជន៍ឱ្យបានឮគ្រប់ៗគ្នា ។ កងទាហានសេះឈរជាពីរជួរយ៉ាងរុងរឿងពីមុខវេទិកា ។

ស្នូរត្រែលាន់ឮយ៉ាងកងរំពង ។ បន្តិចក្រោយមកគេបានឃើញកំហែងពេជ្រ លោកក្រឡាហោមវង្សា. នាងសោភ័ណទេវី នាងមាលា បានមកជាអធិបតីក្នុងពិធីឃាតកម្មនេះ ។ មនុស្សដ៏ចំណានទាំងប៉ុន្មានខាងក្រោយនេះបានមកអង្គុយលើអសនៈដ៏ថ្កើងថ្កាន ។

បរិយាកាសនៃទិវានេះ មានគេទូងស្គរ មានភ្លេងភ្លាត់ គ្រប់បែប យ៉ាងប្រកបដោយភាពអ៊ឹកធឹកយ៉ាងក្រៃលែង ។

ភ្នាក់ងារម្នាក់ក្រោកឡើងសូត្រសំបុត្រថ្កោលទោស ជនជាប់ចោទដោយទាញយកមាត្រាច្បាប់មកបង្ហាញយ៉ាងជាក់ស្ដែងផង ។ ... រួចពីនោះគេឃើញជនជាប់ចោទខ្លះ ត្រូវគេចងព្យួរ ក ខ្លះទៀតត្រូវគេបាញ់ដោយធ្នូ ខ្លះត្រូវគេវះពោះនឹងកាំបិត ខ្លះត្រូវគេចងដៃ ចងជើងទម្លាក់ទឹក ។

ប្រជាជនដែលឈរមើល នាំគ្នាស្រែកហ៊ោរកញ្ច្រៀវសប្បាយ រួចឯគ្រួសារជនអភព្វនោះវិញ ក៏អោបជើងសពយំរហោមគួរឱ្យអាណិត ... "ចម្រើនរកលាភវែងបាត់ធនទៅ..."

**ការ**ចាប់អនុវត្តិផែនការណ៍ក្តៅរបស់កំហែងពេជ្រ ក្នុងពេលជាអវសាននេះ បង្កើតឱ្យមានសង្គ្រាមក្នុងស្រុកមួយបង្ករឡើងដោយមន្ត្រីភាគខ្លះ ដែលភៀសខ្លួនបន្សាត់ទៅឆ្ងាយ ព្រោះបើពុំនោះទេនឹងជាប់ទោសកំបុតកគឺជាជនពុករលួយ. ជាមេចោរកំបុតក ជាមហាចោរប្លន់រាស្ត្រ ប្លន់ខ្មែរ ដើម្បីធ្វើមានតែម្នាក់ឯង ។

តែ ... ក្នុងការសម្រេចសេចក្តីយុត្តិធម៌ ជូនជាតិមាតុភូមិនេះ គឺមានរាស្ត្រភាគច្រើនគាំទ្រ យើងជឿជាក់ថា កម្លាំងរាស្ត្រមានថាមពលក្រៃលែង លើសកម្លាំងអ្វីៗ ទាំងអស់ ។

ក្នុងពេលដែលខ្មែរនិងខ្មែរចាប់អាវុធប្រហារគ្នានេះ ព្រះនរិន្ទវង្សស្តេចវង្វេងរាជ្យ ក៏បានចាត់បញ្ជូនកងទ័ពបរទេសមកវាយលុកនគរទ្រាសយករាជសម្បត្តិវិញដែរ. ដូច្នេះយើងមានរណសិរ្សពីរ គឺច្បាំងនឹងខ្មែរពុករលួយក្បត់ជាតិផង នឹងខ្មាំងបរទេសចក្រពត្រនោះផង ។ ដោយបញ្ញាវាងវៃនៃមេទ័ពកំហែងពេជ្រ សង្គ្រាមនេះកើតឡើងបានរឹងប៉ឹងស្មើផ្ទុកម្លាំងពុំទាន់ ។ ... ថវិកាជាតិក៏អន់ថយ ទន់ខ្សោយគ្រឿងអាវុធក៏ពុំសម្បូរណ៍

ដូច្នេះបញ្ហារៀបចំកងយោធា ឃើញថាតែងតាងបន្តិច ។ តែនៅពីមុខស្ថានការណ៍ដ៏លំបាកនេះ រដ្ឋាភិបាលបានប្ដេជ្ញាយ៉ាងពេញទំហឹងថា នឹងតស៊ូ កំចាត់ខ្មាំងត្រាតែអស់ពីទឹកដី ទោះជួបហេតុអាក្រក់បែបណាក៏ដោយ ។ គឺដោយការប្ដេជ្ញាចិត្តដ៏មុតមាំនេះហើយ ដែលផ្ដុំជាកម្លាំងចិត្ត ពុះពារជ្រោះជ្រៅទាំងអម្បាលមាណ ដែលរាំងរាចលនាតស៊ូ កំចាត់ខ្មាំងនេះ ។

រូមមក. ទ័ពដែលកើតឡើងបានចំនួនច្រើនឥតគណនាព្រមទាំងវិជ្ជាចម្បាំងដ៏ថ្មីកដែលមានសព្វថ្ងៃនេះ គឺក្រោមកិច្ចបញ្ជាការមនុស្សដ៏ល្បីល្បាញជាកំពូលខ្មែរ ... ។ យើងឈ្នះសត្រូវមិនត្រឹមតែមកពីយើងមានចិត្តក្លាហាន អង់អាចគ្រប់ៗ គ្នានៅទេ គឺយើងឈ្នះដោយល្បិចយុទ្ធសាស្ត្រ ពូកែជាក់ស្តែង ត្រាតែបច្ចាមិត្ររបស់រាស្ត្រទ្រាំមិនបានបាក់ទ័ពរត់ថយទៅវិញគ្មានសល់ ។

នៅពេលរសៀលនោះ វេលាដែលកំហែងពេជ្រនឹងនាងសោភ័ណទេវីព្រមទាំងនារី មាលា កំពុងប្រមូលទ័ពចូលទៅកាន់នគរវិញ. ស្រាប់តែមានក្បួនទ័ពច្រើនឥតគណនា ធ្វើព្យូហយាត្រាសំដៅមក ។ លោកកំហែងងើបភក្ត្រឡើងយកហត្ថបាំងនេត្រា សម្លឹងព្រេចៗ ...

ពួកនេះលើកទង់ជ័យស ជាសញ្ញាចុះចូល. តើគេជាទ័ពអ្វីទៅហ្ន៎ !

សេះបួនបំផាយមកជិតដល់ហើយ ធ្វើឱ្យអ្នកទាំងអស់គ្នាស្រឡាំងកាំងព្រោះ ឃើញរូបចន្ទា. រាហុលនឹងមហាកាល ដែលគេស្មានថា ស្លាប់បាត់បង់ទៅហើយនោះនៅជាក់ស្តែងនឹងភ្នែក ។ ឯមនុស្សម្នាក់ពុកមាត់ស្រមូមនោះ គេពុំអាចមើលស្គាល់ឡើយ ។

— បងកាល !

— រាហុល !

— ចន្ទា !

គ្រប់មាត់ផ្ទុះតែពាក្យនេះ ហើយគេស្រែកហ៊ោរកញ្ជ្រៀវសប្បាយអ៊ឹងកង ។ តែនៅខាងនោះ ... គឺជាការគួរឱ្យរំភើបពេកណាស់ព្រោះលោកគ្រូវិសេសភក្តី នៅជ្រងោនឹងនេត្រា ។ នាងមាលាស្ទុះទៅអោបបុរសនេះ ។ ទឹកនេត្រកញ្ញាហូរ. កែវង៉ើបភក្ត្រឡើង ហត្ថទាំងពីរប្រណម ...

— អូនសម្លាញ់ ! បងមិនស្លាប់ទេ. គឺបងចេញទៅសាងសង្គមមួយថ្មីនៅតាមស្រុក តាមភូមិ ជនបទឆ្ងាយៗ ដើម្បីអនុភាពខ្មែរយើង ។ បងលាចេញទៅបង្រៀនខ្មែរគ្រប់ឋានៈ ដើម្បីឱ្យជាតិយើងបានចម្រើនលូតលាស់នឹងគេ ។

— បងមានពេលច្រើន ...

— បងមានល្ហមសាងសង្គមមួយថ្មីតាមបំណងរាស្ត្រពិតៗ

អស់ពលយោធាដែលស្រឡាំងកាំងជាយូរមកហើយ នោះបានភ្ញាក់ស្មារតីឡើង ដោយសម្លេងវិសេសភក្តីស្រែកខ្លាំងៗ ថា ÷

— សួស្តី មិត្រអ្នកតស៊ូជាទីស្នេហា ! ... មិត្រចេញមកច្បាំងនេះគឺចេញច្បាំងដើម្បីរាស្ត្រពិតៗ ។ មកទល់ពេលនេះ កម្លាំងសាមគ្គីរបស់យើងបានកំទេចអំពើពុករលួយដែលរួតរិតសង្គមយើងហើយ ។ នឹមដែកនេះខ្ចាត់ទើបជាតិមានពន្លឺ. ជាតិមានពន្លឺទើបមានសេរីភាព សិទ្ធិ មានពន្លឺផងដែរ ហើយទាល់តែ សិទ្ធិសេរីភាពមានពន្លឺទើបរាស្ត្រយើងមានសុភមង្គលក្នុង

ជីវិត ។ រយៈកាលដែលខ្ញុំចេញចាក់ដំណែងការដ៏ខ្ពង់ខ្ពស់នេះ ខ្ញុំបានទៅរៀបចំទ័ពនៅទល់ដែនបានលួចបានមាសព្រះនរិន្ទវង្សជាច្រើនហាប ទៅលាក់ទុកមួយកន្លែងដើម្បីយកទៅចែកចាយជាប្រយោជន៍រាស្ត្រវិញ ។ កាលមុនហេតុដែលខ្ញុំពុំបានយកមាសទាំងនោះចូលក្នុងក្រុងនគរទ្រាសយើង ព្រោះខ្ញុំនឹកថាកាលណោះនាម៉ឺនយើងនៅពុករលួយមានដៃមានជើង វរ១ ពួកវាយកមាសរបស់រាស្ត្រនេះទៅស៊ីចាយសប្បាយឥតប្រយោជន៍ នាំឱ្យមានកង្វល់ធំថែមទៀត ។ មាសនៅគ្រប់ចំនួនទាំងអស់ សូមលោកអ្នកមើលចុះ ...

គេបើកឡាំងមាសនៅលើរទេះ ឃើញថាគ្រប់ចំនួនទាំងអស់ ។ កំហែងពេជ្រទះស្មាវិសេសភក្តិ ...

— ជាតិខ្មែររស់ដោយសារអ្នក ...

— ប្របាទ គឺដោយសារខ្មែររាប់សែននោះទេ ទានប្រោស ។ ខ្ញុំបានដើរតាមភូមិស្រុកឆ្ងាយ១ ទើបដឹងថាខ្មែរយើងមានចិត្តមុតមាំល្អណាស់. មានការស្មោះត្រង់ប្តូរផ្តាច់ឥតរុញរា ។ នៅទល់ដែន ខ្ញុំរៀបពលយោធាកំទេចទ័ពព្រះនរិន្ទវង្សធ្វើឱ្យពួកវាទន់ដៃ មកវាយលុកក្រុងទ្រាសយើងមិនកើត ។

— ជយោជាតិខ្មែរ ! ជយោវិសេសភក្តិ ជយោសេរីភាព ! ជយោជ័យជំនះរបស់រាស្ត្រ ...

លំដាប់នោះគេឮសូរតែមាត់ពលរេហ៍ ដែលស្រែកលាន់ឮរំពងធ្វើឱ្យរំភើបចិត្តយ៉ាងក្រៃលែង ។

វិសេសភក្តិឈរធ្ងឹងមួយកន្លែង លើកដៃទាំងពីរឡើងលើ បីដូចសាវគ្គព្រះដ៏មានបុណ្យ ។

គេបានរៀបចំរដ្ឋធម្មនុញ្ញថ្មីសម្រាប់នគរទ្រាស. គេជុំនុំគ្នាពិច្បាប់ថ្មីពីអាជ្ញាថ្មី ហើយសម្រេចមក គឺគេលើកសិទ្ធិសេរីភាពរបស់រាស្ត្រឱ្យដល់កំពូលមែនៗ ។

ឆន្ទៈរបស់វិសេសភក្តិនោះ គឺជាឆន្ទៈពិស្ដាររបស់រាស្ត្រ ជាឆន្ទៈដែលមានតម្លៃថ្លៃថ្លា សម្រាប់ប្រជាជាតិមួយដែលមានយុត្តិធម៌ជាគោល សម្រាប់មនុស្សដែលមានសមភាពជាអាទិ៍ ។

សង្គ្រាមស្ងប់ ...

តែនៅនគរក្រុងទ្រាស រដ្ឋាភិបាលថ្មីបានទិញគ្រឿងអាវុធច្រើនឥតគណនា ហ្វឹកហ្វឺន យោធា អប់រំប្រជាពលរដ្ឋឱ្យយល់កាលៈទេសៈវែងឆ្ងាយ. ឱ្យយល់ពីស្ថានភាពស្រុកទេស ប្លែកពីរបបគ្រប់គ្រងមុន ដែលមានតែការលាក់អាថ៌កំបាំង. ការចចើងមានៈ ដឹកនាំតាមតែឆន្ទៈមនុស្សម្នាក់ ...

ដូចនោះ របបរឡេមរឡឹម បុគ្គលនិយមក៏ត្រូវរលំគ្រេងលើចុងជើងរាស្ត្រជាអវសាន ...

ចប់

Hun Sen Library
K012521

CATALOGED IN ALEPH
No : 29910
Date : 25-06-13

12521

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ